# ថ្ងៃទី០១ ខែតុលា ឆ្នាំ២០២០

## ឯកឧត្តម ប៉ែន ពេជ្រសាលី អគ្គនាយកកិច្ចការអយ្យការ និងព្រហ្មទណ្ឌ នៃក្រសួងយុត្តិធម៌ និង ជាប្រធានក្រុមការងារបច្ចេកទេស នៃកម្មវិធីអាស៊ាន-អូស្រ្តាលី ដើម្បីប្រឆាំងការជួញដូរមនុស្ស នៅកម្ពុជា (ASEAN-ACT) អញ្ជើញដឹកនាំអង្គសិក្ខាសាលាផ្ទៀងផ្ទាត់បញ្ជាក់របកគំហើញ

http://moj.gov.kh/kh/ ៣០ កញ្ញា ២០២០

នាព្រឹកថ្ងៃពុធ ១៣កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ នេះ **ឯកឧត្តម ប៉ែន ពេជ្រសាលី អគ្គនាយកកិច្ចការអយ្យការ និងព្រហ្មទណ្ឌ នៃក្រសួងយុត្តិធម៌ និង ជាប្រធានក្រុមការងារបច្ចេកទេស នៃកម្មវិធីអាស៊ាន-អូស្ត្រាលី ដើម្បីប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា (ASEAN-ACT)** ដោយបានទទួលការឯកភាពដ៏ខ្ពង់ខ្ពស់ពី**ឯកឧត្តម កើត រិទ្ធ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌** បានអញ្ជើញដឹកនាំអង្គសិក្ខាសាលាផ្ទៀងផ្ទាត់បញ្ជាក់របកគំហើញ និងអនុសាសន៍ កំណត់ផែនទីភាគីពាក់ព័ន្ធ ផ្នែកសមភាព និងបរិយាប័ន នៅសណ្ឋាគារ កាំបូឌីយ៉ាណា រាជធានីភ្នំពេញ ដោយមានការអញ្ជើញចូលរួមពីសំណាក់ ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាសមាជិក សមាជិកា និងមន្ត្រីពាក់ព័ន្ធ នៃកម្មវិធីអាស៊ាន-អូស្ត្រាលី ដើម្បីប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា។ សិក្ខាសាលានេះមានគោលបំណងសំដៅបង្ហាញ និងប្រមូលធាតុចូល និងមតិកែលម្អពីភាគីពាក់ព័ន្ធផ្សេងៗ ក្នុងប្រទេសលើសេចក្តីព្រាងចុងក្រោយ នៃឯកសារ ដែលត្រូវបានផលិតក្នុងអំឡុងពេលធ្វើកំណត់ផែនទីដៃគូ។

## សិក្ខាសាលាពិគ្រោះយោបល់ និងការអនុវត្តគោលនយោបាយ និងបទដ្ឋានអប្បបរមា ស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស

https://www.facebook.com/mosvygov/ 01-10-2020

ភ្នំពេញ៖ ថ្ងៃទី១ ខែតុលា ឆ្នាំ២០២០ ឯកឧត្តម ញឹក វណ្ណារ៉ា រដ្ឋលេខាធិការ តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តម វង់ សូត រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អញ្ជើញក្នុងកម្មវិធីបើកសិក្ខាសាលាពិគ្រោះយោបល់ និងការអនុវត្តគោលនយោបាយ និងបទដ្ឋានអប្បបរមាស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅសណ្ឋាគារកាំបូឌីយ៉ាណាភ្នំពេញ។ នាឱកាសនោះ ឯកឧតម បានថ្លែងថា រាជរដ្ឋាភិបាលកម្ពុជាបាន នឹងកំពុងខិតខំប្រឹងប្រែង បង្កើតរៀបចំចងក្រង ផ្សព្វផ្សាយ និងអនុវត្តគោលនយោបាយយុទ្ធសាស្ត្រផែនការកិច្ចព្រមព្រៀងទ្វេភាគី និងពហុភាគី និងយន្តការនានា សំដៅប្រយុទ្ធប្រឆាំង និងកាត់បន្ថយឲ្យបានជាអតិបរមា នូវអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មលើមនុស្សទាំងក្នុងក្របខណ្ឌជាតិ អនុតំបន់ តំបន់ និងលើពិភពលោក។

ដោយឡែកក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលបានទទួលអាណត្តិពីរាជរដ្ឋាភិបាលក្នុងការការពារ និងការផ្តល់សេវាគាំទ្រដល់ជនរងគ្រោះ ក្រសួងបានបំពេញការងារយ៉ាងសកម្ម និងសម្រេចបាននូវសមិទ្ធផលជាច្រើនក្នុងកិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការងារកសាងគោលនយោបាយការបង្ការទប់ស្កាត់អំពើជួញដូរមនុស្សការពង្រឹងកិច្ចសហប្រតិបត្តិការ និងការបង្កើតភាពជាដៃគូ។ ឯកឧត្តមបានបន្តថា ទោះបីក្រសួងសម្រេចបានសមិទ្ធផលជាច្រើនយ៉ាងណាក៏ដោយ ក៏ការការពារជនរងគ្រោះដោយអំពើជួញដូរមនុស្សនៅមិនទាន់បានឆ្លើយតបទាំងស្រុងនៅឡើយទេ ជាពិសេសការផ្តល់សេវាគាំទ្រសំរាប់ជនរងគ្រោះនៅមានកម្រិតនៅឡើយ ។ បន្ទាប់ពីក្រសួង ស.អ.យ. បានដាក់ចេញនូវគោលនយោបាយ និងបទដ្ឋានអប្បបរមាស្តីពីកិច្ចការពារសិទ្ធិរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្សឆ្នាំ២០០៩ ក្រសួងបានធ្វើការផ្សព្វផ្សាយ និងបណ្តុះបណ្តាលជាច្រើនវគ្គសម្រាប់អនុវត្តទាំងនៅថ្នាក់ជាតិ និងក្រោមជាតិសំដៅពង្រឹងសមត្ថភាពជំនាញរបស់មន្ត្រីទទួលបន្ទុកការងារសង្គម

កិច្ចពាក់ព័ន្ធនានាទាំងស្ថាប័នរដ្ឋាភិបាល និងអង្គការដៃគូអភិវឌ្ឍន៍ ក្នុងការការពារ និងគាំទ្រដល់ជនរងគ្រោះប្រកបដោយសុវត្ថិភាព និងជាពិសេសធានាបាននូវជនរងគ្រោះទទួលបានផលប្រយោជន៍ពីលិខិតុបករណ៍ជាតិច្បាប់ជាតិ និងអន្តរជាតិព្រមទាំងទទួលបាននូវសិទ្ធិអំណាច និងមានលទ្ធភាពធ្វើសមាហរណកម្មទៅក្នុងគ្រួសារ និងសមាគមដោយជោគជ័យជាស្ថាពរទទួលបានការឧបត្ថម្ភទាំងផ្នែកសំភារៈ និងស្មារតីពិសេស សេវាសុខភាព ការអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ និងទទួលបាននូវកិច្ចការពារយ៉ាងល្អប្រសើរ ឆ្លងផុតពីភាពរងគ្រោះជាថ្មី និងការរើសអើង៕

## ស្ថានទូតកម្ពុជាប្រចាំវៀតណាម បានរំដោះនារីខ្មែរ ៣នាក់ ដែលចាញ់បោកមេខ្យល់ រួចធ្វើបែបបទបញ្ជូនទៅប្រទេសកម្ពុជាវិញ

http://nokorwatnews.com/ 30-09-2020

ភ្នំពេញ៖ ស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំសាធារណរដ្ឋសង្គមនិយមវៀតណាម នៅរសៀលថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ បានចេញសេចក្តីជូនព័ត៌មានឱ្យដឹងថា៖កាលពីថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២០ ស្ថានឯកអគ្គរាជទូតនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំ សាធារណរដ្ឋសង្គមនិយមវៀតណាម បានសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចខេត្តការវបាង -វៀតណាម សង្គ្រោះនារីរងគ្រោះខ្មែរ៣រូប ចាញ់បោកមេខ្យល់ និងបានបញ្ជូនទៅដាក់មជ្ឈមណ្ឌលដាច់ដោយឡែក រយៈពេល១៤ថ្ងៃ ព្រមទាំងបានរៀបចំបែបបទត្រឡប់ទៅកម្ពុជា តាមរថភ្លើងពីទីក្រុងហាណូយនៅថ្ងៃទី២៩ ខែកញ្ញា។ នារីទាំង៣ និងទៅដល់ទីក្រុងហូជីមិញ វេលាម៉ោង ០៥+០០ ព្រឹក ថ្ងៃទី០១ ខែតុលា ឆ្នាំ២០២០ នៅទីនោះស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំក្រុងហូជីមិញ នឹងជួយសម្រួលការធ្វើ ដំណើរបន្តទៅដល់ច្រកទ្វារព្រំដែនអន្តរជាតិបាវិត។

១- នារីរងគ្រោះទី១ កើតថ្ងៃទី០៨ ខែឧសភា ឆ្នាំ១៩៩៤។

២- នារីរងគ្រោះទី២ កើតថ្ងៃទី០៥ ខែកក្កដា ឆ្នាំ១៩៩៣។

៣- នារីរងគ្រោះទី៣ កើតថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦។

ស្ថានទូតបានជួយឧបត្ថម្ភថ្លៃធ្វើដំណើរ ការស្នាក់នៅ ហូបចុក និងឧបត្ថម្ភថវិកា ៥០ម៉ឺនដុងក្នុងម្នាក់។ ស្ថានទូតបានផ្តាំផ្ញើដល់នារីរងគ្រោះនោះ ពេលទៅដល់មាតុប្រទេសវិញខិតខំ ប្រកបមុខរបរតាមសមត្ថភាព៕

## ឃាត់មនុស្សជាង៤០០នាក់ ពាក់ព័ន្ធករណីជួញដូរផ្លូវភេទនិងប្រើប្រាស់គ្រឿងញៀននៅហាងខារ៉ាអូខេមួយ នាក្រុងព្រះសីហនុ

http://khmeread.com/ September 30, 2020 05:20PM

ព្រះសីហនុ ៖ កម្លាំងចម្រុះគណៈបញ្ជាការឯកភាពខេត្តព្រះសីហនុ បានចុះត្រួតពិនិត្យក្នុងទីតាំងខារ៉ាអូខេរបស់ជនជាតិចិនមួយកន្លែងឈ្មោះ «ចិនស៊ីនខាយ សៀនមិន» នៅម្តុំផ្ទះអូរឈើទាល ស្ថិតក្នុងភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ចាប់តាំងពីម៉ោងជាង២ រំលងអធ្រាត្រឈានចូលថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ ដោយឃាត់មនុស្សជាង៤០០នាក់ និងវត្ថុតាងមួយចំនួន។ យោងតាមរបាយការណ៍បឋមបញ្ជាក់ថា អាចនឹងមានការពាក់ព័ន្ធករណីជួញដូរផ្លូវភេទ និងប្រើប្រាស់គ្រឿងញៀនដែលមានជនជាតិចិនប្រុសស្រី ជាង៤០០ នាក់ ត្រូវបានឃាត់ខ្លួនបណ្តោះអាសន្ន នៅក្នុងទីតាំងខារ៉ាអូខេនេះដើម្បីត្រួតពិនិត្យនិងសាកសួរដោយសមត្ថកិច្ចជំនាញនិងរឹបអូសវត្ថុតាងមួយចំនួនសង្ស័យសារជាតុញៀន។ សេចក្តីរាយការណ៍ដដែលបានបញ្ជាក់ថា រហូតមកដល់ព្រឹកថ្ងៃទី៣០កញ្ញានេះ ការត្រួតពិនិត្យកំពុងធ្វើបន្ត ហើយមិនទាន់មានរបាយការណ៍ផ្លូវការពីសមត្ថកិច្ចថា មានបទល្មើសអ្វីខ្លះ និងមានមនុស្សប៉ុន្មាននាក់ដែលជាប់ពាក់ព័ន្ធនឹងបទល្មើសនោះឡើយ៕

## យោធាថៃដាក់វាយរបងលួសបន្លាដើម្បីទប់ស្កាត់ការលួចឆ្លងដែនខុសច្បាប់របស់ពលករខ្មែរ

http://ppt-news.net/ ចេញផ្សាយ ថ្ងៃទី 30/09/2020

ខេត្តបន្ទាយមានជ័យ ៖ កងកម្លាំងយោធាបូរផាថៃ១ក្រុមបានដាក់វាយរបងលួសបន្លាចំនួន៦គីឡូម៉ែត្រពីតាប្រាយ៉ា ដល់ទល់ដែនអារញ្ញ ដើម្បីធ្វើការទប់ស្កាត់ការលួចឆ្លងដែនខុសច្បាប់របស់ពលករខ្មែរ នៅវេលាម៉ោង ៣ រសៀល ថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ២០២០។តាមការអះអាងរបស់វរៈព្រំដែន ៨០៧ និងកំលាំងយោធាការពារព្រំដែនបានប្រាប់អ្នកយកព័ត៌មានឲ្យដឹងថានៅរសៀលម៉ោង៣នោះមានកម្លាំងយោធាបូរផាថៃ១ក្រុមបានដាក់វាយរបងលួសបន្លាចំនួន៦គីឡូម៉ែត្រចាប់ពីតាប្រាយ៉ា ដល់ទល់ដែនអារញ្ញ ដើម្បីធ្វើការទប់ស្កាត់ការលួចឆ្លងដែនខុសច្បាប់របស់ពលករចង់ឆ្លងដែនរកការងារធ្វើដោយខុសច្បាប់នៅប្រទេសថៃ ។

វរៈព្រំដែន៨០៧និងកំលាំងយោធាការពារព្រំដែនបានប្រាប់បញ្ជាក់ឲ្យដឹងបន្តទៀតថាកងកម្លាំងយោធាបូរផា ដោយមានកងកម្លាំងពិសេសតាប្រាយ៉ា រួមជាមួយកម្លាំងនគរបាលល្បាតព្រំដែន ១២ បានបន្ថែមការធ្វើរបងលួសបន្លាដែលទទួលបានការឧបត្ថម្ភពីមជ្ឈមណ្ឌលប្រតិបត្តិការកងទ័ពភូមិភាគ ១ ចំនួន ៣០០ ដុំ ក្នុងបរិវេណដែលទទួលខុសត្រូវដោយកងប្រចាំការពិសេសតាប្រាយ៉ា ដើម្បីទប់ស្កាត់ការលួចឆ្លងដែនតាមច្រកធម្មជាតិខុសច្បាប់ ព្រមទាំងការចុះល្បាត និងយាមកាមក្នុងពេលយប់ជាប្រចាំ ផងដែរ។កងកម្លាំងយោធាបូរផាថៃបានប្រាប់ឲ្យដឹងថាប្រទេសថៃដោយសារជម្ងឺ កូវីត .១៩រាតបាតពេញពិភពលោកពិសេសប្រទេថៃ ធ្វើឲ្យជនជាតិថៃ កើតជម្ងឺនេះមានស្លាប់ មានឆ្លង បង្ខំឲ្យនាយករដ្ឋមន្ត្រីថៃប្រកាសប្រទេសគ្រាមានអាសន្ន រោងចក្រត្រូវបិតទាំងស្រុង ពលករខ្មែរបង្ខំចិត្តចាកចេញពីស្រុក ថៃស្ងើរអស់ រហូតមកដល់សព្វថ្ងៃនេះប្រទេសថៃមិនទាន់ដំណើរការដូចមុននោះឡើយ ព្រោះសំអាងថាជំងឺកូវីដ. ១៩ មិនទាន់បានធូរស្បើយនៅឡើយ។ប្រជាជនថៃនៅតែមានការប្រុងប្រយ័ត្នទាំងអស់គ្នាជានិច្ចអ្វីៗមិនទាន់ដំណើរការនៅឡើយដូច្នេះពករខ្មែរទាំងអស់ចង់មកធ្វើការនៅថៃប្រយ័ត្នចាញ់បោកមេខ្យល់។

សព្វថ្ងៃនេះសមត្ថកិច្ចថៃធ្វើការទប់ស្កាត់ពលករខ្មែរដែលលបលួចចូលឆ្លងដែនទៅ ធ្វើការក្នុងប្រទេថៃខុសច្បាប់ខ្លាំងសំបើមណាស់ដើម្បីការពារទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីយ១៩ នេះ។គួរបញ្ជាក់ផងដែរថាប្រជាពលរដ្ឋខ្មែរជាច្រើនពាន់គ្រួសារក្នុងសម័យកូវីដ.១៩នេះពួកគេគ្មានការងារធ្វើ ហើយក្នុងគ្រួសារជួបប្រទះការខ្វះខាតបានបបួលគ្នាបង្ខំចិត្តលួចឆ្លងដែនខុសច្បាប់ ប្រុងទៅរកការងារធ្វើនៅប្រទេសថៃតាមរយៈមេខ្យល់ឆ្លងដែនខុសច្បាប់ បើមបើមិនជោគជ័យតាមបំណងទេត្រូវ ប្រឈមនឹងគេចាប់បញ្ជូនត្រឡប់មកវិញ ក៏នៅតែប្រថុយ អស់ទាំងប្រាក់ខាតទាំងពេលវេលាត្រូវសមត្ថកិច្ចថៃចាប់ដាក់គុកបន្តថែមទៀតផងនេះដោយសារក្រេពះ៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត បានទទួលពលករខ្មែរចំនួន ០៥នាក់ ដែលឆ្លងដែនខុសច្បាប់ ពីអាជ្ញាធរថៃ

https://www.facebook.com/GDIOfficial 30-09-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ មានពលករខ្មែរឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ០៥នាក់ ស្រី ០១នាក់ និងកុមារ ០៣នាក់។ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធន់ធំដំណើរការជាធម្មតា៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរចំនួន ០៣នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងករណីឆ្លងដែនខុសច្បាប់

https://www.facebook.com/GDIOfficial 30-09-2020

នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ វេលាម៉ោង ១៦និង០០នាទី ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរចំនួន ០៣នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងករណីឆ្លងដែនខុសច្បាប់។ នគរបាលប៉ុស្តិ៍បានឲ្យដឹងថា ពលករខ្មែរទាំង ០៣នាក់នេះ មាន ១. ឈ្មោះ ហាច សារុម ភេទប្រុស អាយុ ២៣ឆ្នាំ ភូមិព្រះស្រែ ឃុំអន្លង់រុន ស្រុកថ្មគោល ខេត្តបាត់ដំបង, ២. ឈ្មោះ រឿន រិន ភេទប្រុស អាយុ ២៥ឆ្នាំ ភូមិតាគរ ឃុំជ្រៃលស់ ស្រុកពញាឮ ខេត្តកណ្តាល, ៣. ឈ្មោះ លី ប៊ុនម៉ាយ ភេទប្រុស អាយុ ៦១ឆ្នាំ ភូមិ៣ ឃុំស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង និងបានធ្វើការសាកសួរ អប់រំណែនាំ ដោយមានការចូលរួមត្រួតពិនិត្យសុខភាព ពីមន្ត្រីចត្តាឡីស័កប្រចាំមាត់ច្រក នូវវិធានការរបស់ក្រសួងសុខាភិបាលផងដែរ៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៩១នាក់

https://www.facebook.com/GDIOfficial 30-09-2020

នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការនិងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៩១នាក់ ស្រី ៣៥នាក់ និងពលរដ្ឋថៃដែលបានចាកចេញមានចំនួន ០១នាក់ ដោយមានឯកសារចេញពីស្ថានទូតថៃ និងលិខិតបញ្ជាក់សុខភាព៕

# ថ្ងៃទី០២ ខែតុលា ឆ្នាំ២០២០

## វគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពស្តីពី ការអនុវត្តតួនាទីភារកិច្ច គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

https://www.facebook.com/deputygovernoryousophear/ 01-10-2020

ថ្ងៃពុធ ១៣កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ ក្រុមការងារលេខាធិការដ្ឋាន ដឹកនាំដោយឧត្តមសេនីយ៍ត្រី ដួង ថាវរី ស្នងការនគរបាលខេត្ត ជាអនុប្រធានលេខាធិការដ្ឋាន និងជាតំណាងលោកជំទាវប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ និងមានការអញ្ជើញចូលរួមសម្របសម្រួលពីវាយគ្មិន ពីតំណាងមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត មន្ទីរសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត មន្ទីរកិច្ចការនារីខេត្ត និងអង្គការមូលនិធិអេ២១ ក្នុងវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពស្តីពី ការអនុវត្តតួនាទីភារកិច្ច គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការបង្ការ ទប់ស្កាត់ អំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងកិច្ចការពារកុមារពីការរំលោភបំពានផ្សេងៗ ដល់ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅថ្នាក់ស្រុក និងថ្នាក់ឃុំដែលមានសមាសភាពអញ្ជើញចញលរួមពីលោកស្រី អភិបាលរង ស្រុកទទួលបន្ទុកអធិការស្រុក កងរាជអាវុធហត្ថស្រុក មេឃុំ អ.ក.ន.ក នាយករដ្ឋបាលស្រុក ប្រធានស្រុកប្រតិបត្តិ/មណ្ឌលសុខភាព

ប្រធានការិ.ជុំវិញស្រុក នាយប៉ុស្តិ៍ មេភូមិ អនុភូមិ និងជំនួយការភូមិ សរុប ៤៥នាក់ ស្រី១៩នាក់ នៅរដ្ឋបាលសាលាស្រុកវាំរិន។ វគ្គបណ្តុះបណ្តាលនេះប្រព្រឹត្តទៅរយៈពេលពេញមួយថ្ងៃ ដោយមានកិច្ចសហការពីរដ្ឋបាលស្រុកវាំរិន និងមានការគាំទ្រពីរដ្ឋបាលសាលាខេត្ត និងអង្គការមូលនិធិអេ២១ផងដែរ។

## មន្ត្រីជាន់ខ្ពស់សង្គមកិច្ចៈ រាជរដ្ឋាភិបាលកំពុងប្រឹងប្រែងកាត់បន្ថយជាអតិបរមានូវអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មលើមនុស្ស

http://www.freshnewsasia.com/ 2020-10-01 01:33pm

**(ភ្នំពេញ)៖** រាជរដ្ឋាភិបាលកម្ពុជា បាននឹងកំពុងខិតខំប្រឹងប្រែងបង្កើតរៀបចំចងក្រងផ្សព្វផ្សាយ និងអនុវត្តគោលនយោបាយយុទ្ធសាស្ត្រផែនការ កិច្ចព្រមព្រៀងទ្វេភាគី និងពហុភាគី និងយន្តការនានាសំដៅប្រយុទ្ធប្រឆាំង និងកាត់បន្ថយឱ្យបានជាអតិបរមានូវអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មលើមនុស្ស ទាំងក្នុងក្របខ័ណ្ឌជាតិ អនុតំបន់ តំបន់ និងលើពិភពលោក។ អំពើជួញដូរមនុស្ស បាននិងងកំពុងកើតឡើងគ្រប់ទីកន្លែង ក្នុងរូបភាពភាគច្រើនជាឧក្រិដ្ឋកម្មឆ្លងដែន និងក្នុងប្រទេស ដែលមានអង្គការចាត់តាំង ហើយឧក្រិដ្ឋកម្មនេះ បានជះឥទ្ធិពលជាអវិជ្ជមានដល់បុគ្គល គ្រួសារ និងសហគមន៍ ជាពិសេសទាំងនៅថ្នាក់ជាតិ តំបន់ និងពិភពលោក។ នេះជាការលើកឡើងរបស់លោក ញឹក វណ្ណារ៉ា រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា តំណាងលោក វង សូត រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ថ្លែងក្នុងឱកាស បើកសិក្ខាសាលាពិគ្រោះយោបល់ «ការអនុវត្តគោលនយោបាយ និងបទដ្ឋានអប្បបរមា ស្តីពី កិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស» នាថ្ងៃទី០១ ខែតុលា ២០២០ នៅសណ្ឋាគារកាំបូឌីយ៉ាណា រាជធានីភ្នំពេញ។

លោកបានបន្តថា ក្រសួងសង្គមកិច្ច បានបំពេញការងារយ៉ាងសកម្ម និងសម្រេចបាននូវសមិទ្ធផលជាច្រើនក្នុងកិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការងារកសាងគោលនយោបាយ ការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ការពង្រឹងកិច្ច សហប្រតិបត្តិការ និងការបង្កើនភាពជាដៃគូ។ ទោះបីក្រសួង សម្រេចបានសមិទ្ធផលជាច្រើន យ៉ាងណាក៏ដោយ ក៏ការការពារជនរងគ្រោះដោយអំពើជួញដូរ មនុស្សនៅមិនទាន់បានឆ្លើយតបបានទាំងស្រុងនៅឡើយទេ ជាពិសេស ការផ្តល់សេវាគាំទ្រសម្រាប់ជនរងគ្រោះនៅ មានកម្រិតនៅឡើយ។ លោក ញឹក វណ្ណារ៉ា បានបញ្ជាក់ទៀតថា ក្រសួងសង្គមកិច្ចយល់ឃើញថា គោលនយោបាយ និងបទដ្ឋានអប្បបរមា ស្តីពីកិច្ចការពារសិទ្ធិរបស់ ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ត្រូវបានដាក់ឱ្យអនុវត្តអស់រយៈពេលជាង១០ឆ្នាំរួចមក ក្រសួងបានសហការជាមួយអង្គការអន្តរជាតិទេសន្តរប្រវេសន៍ (IOM) អង្គការរតនៈអន្តរជាតិ (Ratanak International) និងសកម្មភាព អង្គការសហប្រជាជាតិ ដើម្បីសហប្រតិបត្តិការប្រឆាំងអំពើជួញដូរមនុស្ស (UN-ACT) និងអង្គការដៃគូពាក់ព័ន្ធ ក្នុងការពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពឯកសារនេះ ដើម្បីឱ្យឯកសារនេះមានសុគត្តិភាព និងឆ្លើយតបទៅនឹងស្ថានភាពបច្ចុប្បន្ន។

បន្ថែមពីលើនេះ លោក ញឹក វណ្ណារ៉ា បានឲ្យដឹងថា ដើម្បីពង្រឹងប្រសិទ្ធភាពថែមទៀ តនៃកិច្ចការពារសិទ្ធិ និងការគាំទ្រដល់ជនរងគ្រោះ យើងត្រូវពិនិត្យឡើងវិញនូវ គោលនយោបាយ និងបទដ្ឋានអប្បបរមា ស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដែលបានដាក់ឱ្យប្រើប្រាស់ចាប់តាំងពីឆ្នាំ២០០៩ ហេតុនេះ ក្រសួងត្រូវការមតិ និងយោបល់ដែលមានលក្ខណៈចូលរួម មានន័យថាការការកែសម្រួលឯកសារនេះត្រូវមានការចូលរួមពីអ្នកពាក់ព័ន្ធនានា ដោយរួមមាន ក្រសួង ស្ថាប័ន អង្គការជាតិ អន្តរជាតិ និងភ្នាក់ងារអង្គការសហប្រជាជាតិ នៅគ្រប់ដំណាក់កាលនៃការកែសម្រួល។ លោក ញឹក វណ្ណារ៉ា សង្ឃឹមថា ភាគីដែលបានចូលរួមនៅក្នុងថ្ងៃនេះ នឹងខិតខំអស់ពីកំលាំងកាយ កំលាំងចិត្ត ដើម្បីពិភាក្សា និងផ្តល់មតិ យោបល់ដ៏មានតម្លៃដល់សិក្ខាសាលានេះ ដើម្បីឲ្យក្រុមការងារបច្ចេកទេស បានកែសម្រួលលើគោលនយោបាយ និងបទដ្ឋានអប្បបរមា ស្តីពីកិច្ចការពារសិទ្ធិរបស់ជនរង

គ្រោះដោយអំពើជួញដូរមនុស្ស ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ និងបម្រើឧត្តមប្រយោជន៍ ដល់ជនរងគ្រោះរបស់យើង៕

## លោកស្រី ឧត្តមសេនីយ៍ត្រី ប្រាំង ធីតា ចូលរួមកិច្ចប្រជុំបូកសរុបលទ្ធផលការងារ ៩ខែ របស់លេខាធិការដ្ឋាន នៃគណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ) ឆ្នាំ២០២០ របស់ខេត្តព្រះវិហារ

http://cambodiapolice.com/policekh/ 11:08 am 1 តុលា 2020

**ព្រះវិហារ៖** កាលពីថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ លោកស្រី ឧត្តមសេនីយ៍ត្រី ប្រាំង ធីតា ស្នងការរងផែនការងារប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានចូលរួមកិច្ចប្រជុំបូកសរុបលទ្ធផលការងារ ៩ខែ របស់លេខាការដ្ឋាននៃគណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ) ឆ្នាំ២០២០ របស់ខេត្តព្រះវិហារ ក្រោមអធិបតីភាពលោកជំទាវ ចឹក ហេង អភិបាលរង នៃគណៈអភិបាលខេត្ត។ ដើម្បីពិនិត្យពីលទ្ធផលការងារ បញ្ហាប្រឈម និងទិសដៅអនុវត្តន៍បន្តក្នុងក្របខណ្ឌកិច្ចសហការលើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ព្រមទាំងលោក លោកស្រីក្រុមការងារជំនាញទាំង៦ អង្គការដៃ និងអ្នកពាក់ព័ន្ធជាច្រើនរូបទៀត។

ក្នុងកិច្ចប្រជុំ លោកជំទាវ ចឹក ហេង បានជំរុញឲ្យក្រុមការងារទាំង៦ យកចិត្តទុកដាក់ និងលើកកម្ពស់ប្រសិទ្ធភាព នៃការបង្ការទប់ស្កាត់រាល់បទល្មើសកុំឲ្យកើតមានឡើង និងបន្តអនុវត្តន៍សកម្មភាព ចុះផ្សព្វផ្សាយអំពីច្បាប់ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដល់ប្រជាពលរដ្ឋ សិស្សានុសិស្ស ឲ្យកាន់តែយល់ដឹង អំពីការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារ អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយខុសច្បាប់ ឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។

គួរបញ្ជាក់ផងដែរថា អំពើជួញដូរមនុស្សនៅតែបន្តកើតមាន ក្នុងចំណោមប្រជាជនចល័តចំណាកស្រុក ជាពិសេស ជនអន្តោប្រវេសន៍ មិនប្រក្រតី ឬមិនតាមប្រព័ន្ធច្បាប់ ដូចច្នេះចាំបាច់ត្រូវ ពង្រឹងការយល់ដឹង ការគ្រប់គ្រង ការអនុវត្តច្បាប់ និងពង្រឹងកិច្ចសហការរវាងអង្គភាព ស្ថាប័នគ្រប់លំដាប់ថ្នាក់ ទាំងនៅក្នុងស្រុក ឬតាមព្រំដែនក្នុងការអនុវត្តផែនការបង្ការទប់ស្កាត់ អនុវត្តច្បាប់ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់រូបភាព។

លោកជំទាវ ចឹក ហេង ក៏បានដាក់ទិសដៅអនុវត្តបន្ត ដើម្បីឲ្យសម្រេចគោលដៅនៃការប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្សសម្រាប់ឆ្នាំបន្ទាប់ ដោយបន្តពង្រឹងកិច្ចសហការក្នុងការបង្ការទប់ស្កាត់ អំពើជួញដូរមនុស្សគ្រប់រូបភាព ពង្រឹងការអនុវត្តច្បាប់ និងវិធានការនានា បន្តការផ្សព្វផ្សាយអប់រំដល់ប្រជាពលរដ្ឋ សិស្សានុសិស្សឲ្យយល់ដឹងអំពីល្បិចកល បោកប្រាស់ របស់ជនខិលខូច ដូចជាមេខ្យល់ដើរឃោសនាលួងលោមអូសទាញឲ្យទៅរកការងារធ្វើនៅក្រៅប្រទេស ជាពិសេសស៊ើបអង្កេតជាប្រចាំនៅតាមបណ្តាកន្លែងកំសាន្តសប្បាយ សប្បាយដ្ឋាន ខារ៉ាអូខេ ផ្ទះសំណាក់ រកបទល្មើសអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ លើស្ត្រីនិងកុមារ និងចូលរួមយ៉ាងសកម្មក្នុងគោលនយោបាយភូមិ/ឃុំមានសុវត្ថិភាព បន្តសហការជាមួយអាជ្ញាធរគ្រប់លំដាប់ថ្នាក់។

## ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី ស្នើឯកអគ្គរាជទូតជប៉ុនបន្តជួយគាំទ្រថែមទៀត លើការអភិវឌ្ឍធនធានមនុស្ស និងលើកទឹកចិត្តអ្នកវិនិយោគជប៉ុនមកវិនិយោគនៅកម្ពុជា ព្រមទាំងពង្រីកទីផ្សារនៅជប៉ុន

http://www.mlvt.gov.kh/ Thursday, 01 October 2020 12:15

ទីស្តីការក្រសួង៖ ឯកឧត្តមបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានស្នើឱ្យឯកអគ្គរាជទូតជប៉ុនប្រចាំកម្ពុជាឯកឧត្តម មីកាមិ ម៉ាសាហ៊ីរ៉ូ បន្តជួយគាំទ្រថែមទៀតលើការអភិវឌ្ឍធនធាន

មនុស្សនិងជំរុញលើកទឹកចិត្តដល់អ្នកវិនិយោគជប៉ុនឱ្យបង្កើនការវិនិយោគនៅកម្ពុជាបន្ថែមនិងពង្រីកទីផ្សារនៅជប៉ុន។ ការស្នើយ៉ាងដូច្នេះ ត្រូវបានធ្វើឡើងក្នុងជំនួបពិភាក្សារវាងឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី អ៊ិត សំហេង ជាមួយឯកឧត្តម ឯកអគ្គរាជទូត មីកាមិ ម៉ាសាហ៊ីរ៉ូ នៅទីស្តីការក្រសួងការងារ នាថ្ងៃទី០១ ខែតុលា ឆ្នាំ២០២០។ នាឱកាសនោះ ភាគីទាំងពីរបានវាយតម្លៃខ្ពស់ចំពោះកិច្ចសហប្រតិបត្តិការដ៏ល្អរវាងកម្ពុជាជប៉ុន លើគ្រប់វិស័យ ដោយឡែកវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក៏ជាក្របខណ្ឌកិច្ចសហប្រតិបត្តិការ ដែលភាគីទាំងពីរកំពុងបន្តជំរុញយកចិត្តទុកដាក់ និងពង្រីកនូវកិច្ចសហប្រតិបត្តិការថ្មីៗថែមទៀត។ រដ្ឋាភិបាលនៃប្រទេសទាំងពីរសុទ្ធតែបានដាក់ចេញនូវវិធានការប្រកបដោយប្រសិទ្ធភាពក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩។

ឯកឧត្តមឯកអគ្គរាជទូតជប៉ុន បានកោតសរសើរចំពោះវិធានការដ៏មានប្រសិទ្ធភាពរបស់រាជរដ្ឋាភិបាលកម្ពុជាលើបញ្ហាកូវីដ-១៩ និងវិធានការដោះស្រាយផលប៉ះពាល់ដោយជំងឺរាតត្បាតនេះ ព្រោះថាបានជួយដោះស្រាយទាំងបញ្ហាសង្គម និងសេដ្ឋកិច្ច។ លើក្របខណ្ឌកិច្ចសហប្រតិបត្តិការវិស័យការងារ កម្ពុជា-ជប៉ុន បានចុះអនុស្សរណៈនៃការយោគយល់គ្នានៅឆ្នាំ២០០៧ ដើម្បីទទួលកម្មសិក្សាការីកម្ពុជាទៅធ្វើការនៅប្រទេសជប៉ុន និងអនុស្សរណៈនៃការយោគយល់គ្នានៅឆ្នាំ២០១៩ ដើម្បីទទួលយកពលករជំនាញទៅធ្វើការនៅប្រទេសជប៉ុន ខណៈបច្ចុប្បន្នមានកម្មសិក្សាការី និងពលករជំនាញកម្ពុជាដែលកំពុងបម្រើការនៅប្រទេសជប៉ុនមានជាង ១០,០០០នាក់។

ឯកឧត្តមរដ្ឋមន្ត្រីបានបន្តថា ដោយសារបច្ចុប្បន្នពិភពលោកទាំងមូល រួមទាំងកម្ពុជាផងនោះ កំពុងជួបប្រទះនូវវិបត្តិជំងឺកូវីដ-១៩ បានធ្វើឱ្យវិស័យការងារ វិស័យទេសចរណ៍ និងវិស័យមួយចំនួនទៀតនៅកម្ពុជាជួបប្រទះនូវវិបត្តិមួយចំនួន ក្នុងនោះរាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវកញ្ចប់វិធានការ ដែលមកដល់ពេលនេះ បានទម្លាក់កញ្ចប់វិធានការទី៦ហើយ ដើម្បីដោះស្រាយផលប៉ះពាល់ជូនកម្មករនិយោជិត និយោជក និងប្រជាពលរដ្ឋ ជាពិសេសកម្មករនិយោជិតដែលព្យួរការងារ និងបាត់បង់ការងារ ដើម្បីពួកគាត់អាចដោះស្រាយបាននូវបញ្ហាជីវភាព និងស្វែងរកបាននូវឱកាសការងារថ្មី។ ឯកឧត្តមរដ្ឋមន្ត្រីក៏បានថ្លែងអំណរគុណចំពោះភាគីជប៉ុន ដែលបានយកចិត្តទុកដាក់ដល់សិក្ខាកាម និងកម្មករជំនាញកម្ពុជា ព្រមទាំងអនុញ្ញាតឱ្យចេញចូលជប៉ុនតាមរយៈវិធានការធ្វើចត្តាឡីស័កនៅផ្ទះ។ តាមគ្រោងទុកកម្ពុជានឹងបញ្ជូនសិក្ខាកាម និងកម្មករជំនាញដែលបានបណ្តុះបណ្តាលរួចទៅជប៉ុនបន្ថែមទៀតក្នុងពេលឆាប់ៗ នៅពេលដែលភាគីទាំងពីរឯកភាពនូវមធ្យោបាយនិងនីតិវិធីក្នុងការធានាឱ្យបាន នូវការឆ្លងវីរ៉ុសកូវីដ-១៩។

នៅក្នុងការជំរុញការអភិវឌ្ឍធនធានមនុស្ស ឯកឧត្តមរដ្ឋមន្ត្រីបានបញ្ជាក់ជូនថា រាជរដ្ឋាភិបាលកម្ពុជាកំពុងជំរុញការអនុវត្តគោលនយោបាយអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដើម្បីឆ្លើយតបទៅនឹងការអភិវឌ្ឍវិស័យឧស្សាហកម្ម និងការធានាបាននូវភាពប្រកួតប្រជែងរបស់កម្ពុជា។ គោលនយោបាយនេះ ក៏កំពុងត្រូវការការចូលរួមជួយពីសំណាក់ដៃគូជាច្រើនទៀត ហើយអង្គការ JICA របស់ជប៉ុនក៏បានជួយដល់ការបណ្តុះបណ្តាលលើជំនាញអគ្គិសនីផងដែរ។ ឯកឧត្តមរដ្ឋមន្ត្រី អ៊ិត សំហេង បានជម្រាបថា ថ្មីៗនេះ ក្រសួងបានស្នើទៅកាន់អង្គការ JICA ដើម្បីសុំឱ្យមានគ្រូបច្ចេកទេសផ្នែកអគ្គិសនីនេះមកជួយបង្រៀនបន្ថែម ហើយសង្ឃឹមថាជប៉ុននឹងយល់ព្រមចំពោះសំណើនេះ។

ឯកឧត្តម មីកាមិ ក៏ដូចជាឯកឧត្តម អ៊ិត សំហេង សុទ្ធតែបានបង្ហាញពីការមើលឃើញថា ក្រុមអ្នកវិនិយោគទុនជប៉ុន ពិតជាបានរួមវិភាគទានយ៉ាងខ្លាំង ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជាឲ្យមានការលូតលាស់រីកចម្រើន ជាបន្តបន្ទាប់។ ឧស្សាហកម្មដែលវិនិយោគដោយជនជាតិជប៉ុនមិនបានបិទនូវខ្សែសង្វាក់ផលិតកម្មរបស់ខ្លួននោះឡើយ មានតែបន្តបង្កើនវិនិយោគបន្ថែមទៀត ជាក់ស្តែងដូចជាក្រុមហ៊ុន Minibear ដែលជាក្រុមហ៊ុនឈានមុខមួយរបស់ជប៉ុនដែលផលិតគ្រឿងបង្គុំ ម៉ូទ័រតូចៗជាដើម។ ភាគីទាំងពីរ បានលើកឡើងទៀតថា សុខដុមនីយកម្មទំនាក់ទំនងវិជ្ជាជីវៈ គឺជាធាតុផ្សំមិនអាចខ្វះបានសម្រាប់អ្នកវិនិយោគទុន ។ កន្លងមកនេះ ទំនាក់ទំនាក់ដ៏ល្អរវាងកម្មករនិយោជិត

របស់កម្ពុជា និងថៅកែជាជនជាតិជប៉ុនមានភាពស្និទ្ធស្នាល ចេះយោគយល់អធ្យាស្រ័យគ្នា ដែលជាកត្តាដ៏សំខាន់ក្នុងការទាក់ទាញអ្នកវិនិយោគជប៉ុនមកកាន់កម្ពុជាកាន់តែច្រើនផងដែរ៕

## ការស្រាវជ្រាវមួយរកឃើញថា ពលករចំណាកស្រុកប្រឈមបញ្ហាផ្លូវចិត្តធ្ងន់ធ្ងរ

https://khmer.voanews.com/ 01 តុលា 2020 ហ៊ាន សុជាតា ខាន់ សុគុំមនោ

ភ្នំពេញ៖ មួយភាគបីនៃពលករខ្មែរចំណាកស្រុកធ្វើការនៅប្រទេសថៃមានគុណភាពជីវិតទាបដោយសារបញ្ហា stress (ជំងឺផ្នែកផ្លូវអារម្មណ៍) ខ្លាំងមានអាការៈជំងឺធ្លាក់ទឹកចិត្ត(de•pression)និងបរិស្ថានរស់នៅមានស្តង់ដារទាប។ នេះបើយោងតាមអត្ថបទស្រាវជ្រាវមួយអំពី«ស្ថានភាពសុខភាពផ្លូវចិត្តនិងគុណភាពជីវិតក្នុងចំណោមពលករកម្ពុជាចំណាកស្រុកនៅប្រទេសថៃ»។ អត្ថបទស្រាវជ្រាវនេះត្រូវបានបោះពុម្ពផ្សាយ ក្នុងខែកញ្ញាឆ្នាំ ២០២០។ អត្ថបទនេះសិក្សាក្នុងចំណោមពលករកម្ពុជាចំណាកស្រុកចំនួនជាង១២០០នាក់ នៅក្នុងខេត្តសាកែវ និងខេត្តសូរិន្ទប្រទេសថៃ។ ពលករកម្ពុជាប្រមាណ ២៥០០០ នាក់ ធ្វើការនៅខេត្តនេះ កាលពីឆ្នាំ ២០១៨ នៅអំឡុងពេលដែលអ្នកស្រាវជ្រាវចុះសិក្សា។

លោក ប៉ាល់ ចំរើន អ្នកស្រាវជ្រាវជាន់ខ្ពស់នៃអង្គការខាណា ដែលធ្វើការលើផ្នែកសុខភាពនិងជាអ្នកដឹកនាំការស្រាវជ្រាវនេះ លើកឡើងថា បញ្ហាច្រើនដូចជាសុខភាពផ្លូវចិត្ត ការរំលោភបំពានកម្លាំងពលកម្ម និងបរិស្ថានរស់នៅស្តង់ដារទាប បានធ្វើឲ្យគុណភាពជីវិតរបស់ពួកគេធ្លាក់ចុះ។ អ្នកស្រាវជ្រាវរូបនេះ បានប្រាប់វីអូអេថា៖ «ទាក់ទងនឹងគុណភាពជីវិតឬសេចក្តីសុខរបស់កម្មករហ្នឹងឃើញថា ៣៤ ជិត ៣៥ ភាគរយ (មួយភាគបី) នៃកម្មករដែលធ្វើការនៅថៃហ្នឹង គុណភាពជីវិតគាត់តិចតួច មានន័យថា គុណភាពជីវិតរបស់គាត់នៅក្នុងកម្រិតខ្សោយ ដោយសារកត្តាមួយចំនួនពាក់ព័ន្ធដូចជាគាត់មានកម្រិតស្ត្រេស កម្រិតភាពធុញថប់ និងជំងឺធ្លាក់ទឹកចិត្តជាដើម»។

បណ្ឌិតផ្នែកសុខភាពសាធារណៈនៃសាកលវិទ្យាល័យ Khon Kaen ប្រទេសថៃរូបនេះ បន្តថា៖ «ហ្នឹងដែលខ្ញុំទៅឃើញផ្ទាល់គឺឃើញថា ពួកគាត់ភាគច្រើនដែលនៅតាមចម្ការអំពៅ ចម្ការដំឡូងអីជាលក្ខណៈតូបតូចៗ ដែលនិយោជកគ្រាន់តែផ្តល់ជាឈើ ឬសម្ភារៈតិចតួច ដែលគាត់ត្រូវយកមកសាងសង់ខ្លួនឯង។ អ៊ីចឹងគុណភាពសំណង់ខ្ទម ដែលគាត់ធ្វើហ្នឹងគឺត្រឹមតែបានប្រក់ការពារខ្យល់ភ្លៀងតិចតួចអីតែប៉ុណ្ណឹង។ សហគមន៍គាត់នៅឆ្ងាយដាច់ពីជនជាតិថៃ ដែលគេរស់នៅភូមិស្រុករបស់គេ»។ គុណភាពជីវិតល្អសំដៅដល់កម្រិតស្តង់ដារសុខភាព សេចក្តីសុខសុភមង្គលរបស់បុគ្គលម្នាក់ៗ ដែលកើតចេញពីសុខភាពរាងកាយ សុខភាពផ្លូវចិត្ត ទំនាក់ទំនងសង្គម និងបរិស្ថានជុំវិញខ្លួន។ នេះបើតាមការកំណត់របស់អង្គការសុខភាពពិភពលោក (WHO)។

អត្ថបទស្រាវជ្រាវដែលត្រូវបានបោះពុម្ពផ្សាយនៅក្នុងព្រឹត្តិបត្រ F1000Research មានទីស្នាក់ការនៅក្នុងប្រទេសអង់គ្លេសនេះ សរសេរថា៖ «អត្រាប្រេវ៉ាឡង់(ទូទៅ)នៃភាព stress (ជំងឺផ្នែកផ្លូវអារម្មណ៍) មធ្យមនិងខ្លាំងក្នុងចំណោមពលករទាំងនោះ មានដល់ជិត ៦៨ ភាគរយ ហើយរោគសញ្ញានៃជំងឺធ្លាក់ទឹកចិត្ត (depression) មានដល់ជិត ៧០ ភាគរយ»។ នេះមានន័យថា ក្នុងចំណោមពលករ ១០០ នាក់ មានជិត ៧០ នាក់ ប្រឈមនឹងការធ្លាក់ទឹកចិត្ត (depression)។ ការសិក្សានេះក៏បានប្រៀបធៀបជាមួយនឹងការសិក្សាស្រដៀងគ្នាធ្វើឡើងនៅបណ្តាប្រទេសក្នុងតំបន់អឺរ៉ុប ដែលគេរាយការណ៍ថា ក្នុងចំណោមពលករចំណាកស្រុក ១០០ នាក់ ដែលមានជំនាញទាបនោះមាន ៦៣ នាក់ប្រឈមនឹងបញ្ហាផ្លូវចិត្ត។ ពលករចំណាកស្រុកខ្មែរនៅប្រទេសថៃធ្វើការក្នុងវិស័យកសិកម្ម សំណង់អ្នកបម្រើតាមផ្ទះសេវាកម្មឧស្សាហកម្មផលិតវកម្ម និងចិញ្ចឹមសត្វ។ ពួកគេភាគច្រើនទទួលបានប្រាក់ចំណូលមិនគ្រប់គ្រាន់ហើយជាប់បំណុលធនាគារ។ នេះបើយោងតាមការស្រាវជ្រាវដដែលនេះ។ អត្ថបទស្រាវជ្រាវនេះបន្ថែមទៀតថា បញ្ហាផ្លូវចិត្តមានទំនាក់ទំនងជិតស្និទ្ធទៅនឹងគុណភាពជីវិតទាប។ នៅពេលប្រឈមនឹងបញ្ហាផ្លូវ

ចិត្ត ពលករភាគច្រើនបានជ្រើសរើសយកការផឹកបារីនិងសេពសុរា។ការណ៍នេះបង្កឲ្យមានការរំខានដល់ការបំពេញការងារ បន្ថែមបន្ទុកសេដ្ឋកិច្ចបង្កអំពើហិង្សាក្នុងគ្រួសារនិងអាចឈានដល់ការលេងល្បែងស៊ីសងថែមទៀតផង។

លោក ប៉ាល់ ចំរើន ជាអ្នកសិក្សាការស្រាវជ្រាវនេះបន្តថា ពលករចំណាកស្រុកទាំងនោះត្រូវការជាចាំបាច់នូវការអន្តរាគមន៍ពីរដ្ឋាភិបាលនិងស្ថាប័នពាក់ព័ន្ធ ទៅលើការគាំទ្រផ្នែកសេវាអប់រំការប្រឹក្សាផ្នែកសុខភាពផ្លូវចិត្ត និងការកែលម្អស្ថានភាពរស់នៅរបស់ពលករទាំងនោះ។ លោក ប៉ាល់ ចំរើន បារម្ភថា វិបត្តិសេដ្ឋកិច្ចដែលបង្កឡើងដោយជំងឺរាតត្បាតកូវីដ១៩ ជាបន្ទុកបន្ថែមដល់ស្ថានភាពរស់នៅដល់ពលករទាំងនោះ។ ត្រឹមចុងខែកញ្ញានេះ ពលករកម្ពុជាបន្តស្នាក់នៅនិងធ្វើការនៅក្នុងប្រទេសថៃមានចំនួនប្រមាណ ១ លាន ១សែននាក់។ នេះបើតាមស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ។

លោក ញឹប ដា អាយុ ៤៤ ឆ្នាំ ជាពលករមួយរូបដែលធ្វើការនៅប្រទេសថៃជាង ៦ ឆ្នាំមកហើយ។ ដោយសារការអូសបន្លាយនៃជំងឺកូវីដ១៩ លោក ញឹប ដា និងភរិយារួមទាំងកូនស្រី អាយុ ១៩ ឆ្នាំ បានបាត់បង់ការងារធ្វើនៅខេត្តឈុនបុរីប្រទេសថៃ។ លោកបានឲ្យដឹងថា លោកនៅបន្តចាំរកការងារធ្វើ ព្រោះលោក និងគ្រួសាររបស់លោកមិនត្រឡប់មកស្រុកវិញទេ ដរាបណាលោកនៅមិនទាន់មានចំណូល ដើម្បីដោះបំណុលធនាគារជាង ៣០០០ ដុល្លារ ដែលលោកខ្ចីដើម្បីធ្វើផ្ទះឲ្យកូនស្រី នៅឯស្រុកបរសេដ្ឋខេត្តកំពង់ស្ពឺ។ លោកនិយាយថា៖ «យើងនៅខ្មែរយើងក្រលំបាក។ យើងរកការងារអត់បានធ្វើ។ យើងមានតែមកស្រុកថៃ។ យើងមិនសូវចេះ។ យើងមកថៃសម្បូរការងារធ្វើ»។ ដើម្បីកាត់បន្ថយការចំណាយ លោក ញឹប ដា និងក្រុមគ្រួសារសុំស្នាក់អាស្រ័យបណ្ដោះអាសន្ននៅការិយាល័យរបស់មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស ហៅកាត់ថា សង់ត្រាល់។ លោកបន្តទៀតថា៖ «ចំណូលយើងអត់មានផង យើងអត់ហ៊ានហូបច្រើន ហើយរកការងារអត់ទាន់បានទៀត»។

លោក លឹង សុផុន មន្ត្រីគម្រោងពលករចំណាកស្រុកនៃអង្គការសង់ត្រាល់ប្រចាំប្រទេសថៃ ឲ្យដឹងថា ពលករភាគច្រើនមានក្ដីបារម្ភខ្លាំង ដោយសារអស្ថិរភាពការងារ ជាពិសេសក្នុងអំឡុងពេលកូវីដ១៩នេះ។ លោកប្រាប់វីអូអេថា៖ «កន្លែងខ្លះ គាត់មានការងារបណ្ដោះអាសន្ន។ គេហៅទៅធ្វើទៅ ក៏ទៅ អត់មាន ក៏អត់ធ្វើ។ អត់សូវមានការងារអ៊ីចឹង ពួកគាត់នៅតែព្រួយបារម្ភ»។ លោកបន្តថា៖ «គាត់លំបាករឿងជីវភាពប្រចាំថ្ងៃរបស់គាត់ រហូតសម្រេចចិត្តត្រឡប់ទៅខ្មែរវិញ...នៅក៏គ្មានការងារធ្វើ»។

លោក ហេង សួរ អ្នកនាំពាក្យក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ មិនផ្ដល់ការអត្ថាធិប្បាយមកកាន់វីអូអេទេ លើបញ្ហាទាំងនេះ។

លោក ហឿ សេធុល ប្រធានសមាគមអ្នកប្រឹក្សាយោបល់ និងអប់រំផ្លូវចិត្ត ថ្លែងថា ជាទូទៅពលករចំណាកស្រុកប្រឈមនឹងការលំបាកផ្នែកផ្លូវចិត្តហើយស្ថានភាពកូវីដ១៩ បង្កឲ្យភាពតានតឹងអារម្មណ៍កាន់តែខ្លាំងជាងមុន។ លោកប្រាប់វីអូអេថា៖ «អ៊ីចឹងនៅពេលដែលមានស្ថានភាពកូវីដ១៩ កើតឡើង គាត់អាចប្រឈមនឹងស្ថានភាពហិរញ្ញវត្ថុរបស់គាត់។ អ៊ីចឹងធ្វើឲ្យប៉ះពាល់ដល់ជីវភាពរស់នៅប្រចាំថ្ងៃរបស់គាត់ ការហូបចុកមិនបានគ្រប់គ្រាន់សម្លាធ ទាក់ទងនឹងការទទួលខុសត្រូវក្នុងគ្រួសារ ហើយការបាត់បង់ការងារក៏អាចធ្វើឲ្យពួកគាត់មានបញ្ហា[ផ្លូវចិត្ត] ហ្នឹងដែរ»។ លោកបន្តថា ការជួយគាំទ្រដល់ពលករចំណាកស្រុកភាគច្រើនផ្ដោតសំខាន់លើផ្នែកសេដ្ឋកិច្ច និងសុខភាពផ្លូវកាយ ប៉ុន្តែមានការអន្តរាគមន៍ផ្នែកសុខភាពផ្លូវចិត្តនៅមានតិចតួចនៅឡើយ។

កាលពីខែឧសភា ឆ្នាំ ២០២០ អង្គការសិទ្ធិមនុស្សលីកាដូ បានចេញផ្សាយរបាយការណ៍សិក្សាមួយ ដោយលើកឡើងថា ការជំពាក់បំណុលមីក្រូហិរញ្ញវត្ថុជំរុញឲ្យប្រជាពលរដ្ឋក្នុងភូមិមួយ នៅខេត្តបន្ទាយមានជ័យ បង្ខំចិត្តធ្វើចំណាកស្រុកទៅប្រទេសថៃ ដើម្បីរកលុយសងគ្រឹះស្ថានហិរញ្ញវត្ថុទាំងនោះ។ ចាប់តាំងពីចុងខែមីនា នៅពេលជំងឺកូវីដ១៩ កាន់តែតានតឹងពលករខ្មែរជាង ១១ ម៉ឺននាក់ បានវិលត្រឡប់ពីក្រៅប្រទេស ជាពិសេសពីប្រទេសថៃចូលប្រទេសកម្ពុជាវិញ ហើយពួកគេប្រឈមអត់ការងារធ្វើ បាត់បង់ចំណូល និងជំពាក់បំណុលគេថែមទៀត៕

## ប្រជាពលរដ្ឋខ្មែរចំនួន ១២នាក់ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង

https://www.facebook.com/GDIOfficial 01-10-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី០១ ខែតុលា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារមិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ១២នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

## ភាគីថៃបានបញ្ជូនពលរដ្ឋខ្មែរចំនួន ០១នាក់ ឲ្យមកប៉ុស្តិ៍នគរបាលច្រកទ្វារថ្មព្រំដែនអន្តរជាតិដាំពីបទឆ្លងដែនខុសច្បាប់

https://www.facebook.com/GDIOfficial 01-10-2020

នៅថ្ងៃទី០១ ខែតុលា ឆ្នាំ២០២០ ខាងភាគីថៃបានបញ្ជូនពលរដ្ឋខ្មែរចំនួន ០១នាក់ ឲ្យមកប៉ុស្តិ៍នគរបាលច្រកទ្វារថ្មព្រំដែនអន្តរជាតិដាំ ពីបទឆ្លងដែនខុសច្បាប់ ទៅកាប់ឈើនៅប្រទេសថៃ ដែលចេញតាមច្រកអូរចាក ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១២៦នាក់

https://www.facebook.com/GDIOfficial 01-10-2020

នៅថ្ងៃទី០១ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការនិងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបរយានយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១២៦នាក់ ស្រី ៥៥នាក់ និងពលរដ្ឋថៃដែលបានចាកចេញមានចំនួន ០៦នាក់ ស្រី ០១នាក់ ដោយមានឯកសារចេញពីស្ថានទូតថៃ និងលិខិតបញ្ជាក់សុខភាព៕

# ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២០

## លោក ប្រាក់ សុខុន ស្នើថៃ អនុញ្ញាតឲ្យពលករខ្មែរ អាចត្រឡប់ទៅធ្វើការវិញ និងសុំឲ្យបញ្ចុះតម្លៃធ្វើចត្តាឡីស័ក

https://thmeythmey.com/ 04, Oct 2020 , 6:19 pm

លោក ប្រាក់ សុខុន រដ្ឋមន្ត្រីក្រសួងការបរទេសកម្ពុជា និងលោក ដុន ប្រាមុដវិណៃ រដ្ឋមន្ត្រីក្រសួងការបរទេសថៃ បានពិភាក្សាគ្នា តាមប្រព័ន្ធវីដេអូ (Video Conference) កាលពីថ្ងៃទី២ ខែតុលា ឆ្នាំ២០២០ ដោយផ្តោតសំខាន់លើកិច្ចសហប្រតិបត្តិការ ពិសេសរម្លឹកខួបអនុស្សាវរីយ៍លើកទី៧០ នៃការបង្កើតទំនាក់ទំនងការទូតកម្ពុជា-ថៃ រួមទាំងផ្លាស់ប្តូរយោបល់គ្នាពីការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ផងដែរ។ ខ្លឹមសារនៃកិច្ចពិភាក្សារបស់ប្រមុខការទូតទាំងពីរ ត្រូវបានស្រង់យកទៅផ្សព្វផ្សាយក្នុងសេចក្តីប្រកាសព័ត៌មានរបស់ក្រសួងការបរទេសកម្ពុជា។ បើតាមសេចក្តីប្រកាសព័ត៌មានលោក ប្រាក់ សុខុន បានស្នើភាគីថៃឲ្យអនុញ្ញាតពលករកម្ពុជាដែលកាន់បណ្ណព្រំដែន និងពលករកម្ពុជា ដែលចុះឈ្មោះធ្វើការតាមអនុស្សារណៈស្តីពីការយោគយល់គ្នា អាចវិលត្រឡប់ទៅធ្វើការនៅថៃវិញ និងស្នើឲ្យបញ្ចុះតម្លៃលើការធ្វើចត្តាឡីស័ករយៈពេល១៤ថ្ងៃ។ តម្លៃជាទូទៅនៃការធ្វើចត្តាឡីស័ករយៈពេល១៤ថ្ងៃ នៅថៃ គឺប្រមាណជាង៤៤០ដុល្លារ។ ដោយសារតែជំងឺកូវីដ-១៩ អាជីវកម្ម និងកន្លែងធ្វើការនានា ក្នុងប្រទេសថៃ ត្រូវបានផ្អាក ដែលបណ្តាលឲ្យពលករខ្មែរ គ្មានការងារធ្វើ ហើយក៏សម្រុកមកកម្ពុជាវិញ។ របាយការណ៍ពីក្រសួងមហាផ្ទៃ បានឲ្យដឹងថា គិតត្រឹមខែកក្កដា ឆ្នាំ២០២០ មានពលរដ្ឋខ្មែរជាង១សែននាក់ បានត្រឡប់មកពីបរទេស ជាពិសេសពីប្រទេសថៃ។ ទន្ទឹមនឹងនេះ ក៏មានពលរដ្ឋខ្មែរ វិលត្រឡប់ចូលទៅទឹកដីថៃវិញដែរ តាមខេត្ត ដែលនៅជាប់ប្រទេសថៃ។ ដោយសារតែកម្ពុជានិងថៃ នៅតែបន្តបិទព្រំដែន ដូច្នេះ ពលរដ្ឋខ្មែរទាំងនោះ ត្រូវបង្ខំលបលួចចូលប្រទេសថៃ តាមច្រកផ្សេងៗ ដែលគ្មានសមត្ថកិច្ចឈរជើង ដើម្បីទៅស្វែងរកការងារធ្វើវិញ។ ពេលខ្លះពលរដ្ឋខ្មែរដែលលួចឆ្លងដែនទាំងនោះ ត្រូវសមត្ថកិច្ចកម្ពុជា ប្រទះឃើញ ហើយក៏រាំង ហើយពេលខ្លះ បានចូលទៅដល់ទឹកដីថៃ ក៏ត្រូវសមត្ថកិច្ចថៃ ចាប់បញ្ជូនមកវិញ។ បច្ចុប្បន្ន នៅតែមានពលរដ្ឋខ្មែរ បន្តលួចឆ្លងដែន ចូលទៅថៃ។

គេ ពុំដឹងថា រដ្ឋមន្ត្រីការបរទេសថៃ ឆ្លើយតបយ៉ាងណា ឬក៏មិនឆ្លើយតបនោះទេ ចំពោះសំណើរបស់រដ្ឋមន្ត្រីការបរទេសកម្ពុជា ដែលសុំភាគីថៃ ជួយសម្រួលឲ្យពលករកម្ពុជាបានទៅធ្វើការនៅថៃវិញ និងជួយបញ្ចុះតម្លៃនៃការធ្វើចត្តាឡីស័ក ដោយសារតែសេចក្តីប្រកាសព័ត៌មាន ពុំបានសរសេរ។

បើតាមសេចក្តីប្រកាសព័ត៌មានដដែល លោក ប្រាក់ សុខុន បានអរគុណភាគីថៃ ចំពោះការពន្យារសុពលភាពទិដ្ឋាការស្នាក់នៅ និងបណ្ណអនុញ្ញាតឲ្យធ្វើការ ដល់ពលករកម្ពុជា ព្រមទាំងបង្កើតអត្ថប្រយោជន៍សម្រាប់អ្នកបាត់បង់ការងារនិងអត្ថប្រយោជន៍ផ្នែកសង្គមនានា ដល់ពលករ ដែលត្រូវបានព្យួរការងារ។ ជាមួយគ្នានេះ លោក បានសង្កត់ធ្ងន់ពីសារសំខាន់នៃការផ្លាស់ប្តូរព័ត៌មាន និងកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធ ដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ហើយសង្ឃឹមថា វ៉ាក់សាំងរបស់ថៃ នឹងត្រូវបានផលិតដោយជោគជ័យនិងដាក់ឲ្យប្រើប្រាស់ក្នុងពេលឆាប់ៗ។

បន្ថែមពីនេះ ប្រមុខការទូតកម្ពុជា បានអរគុណរដ្ឋាភិបាលថៃ ដែលបានផ្តល់ជំនួយថវិកានិងបរិក្ខារពេទ្យដល់កម្ពុជា ដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩។ សេចក្តីប្រកាសព័ត៌មាន សរសេរថា ប្រមុខការទូតថៃ បានអរគុណរដ្ឋាភិបាលកម្ពុជាវិញ ចំពោះការជួយសម្រួលដល់ការធ្វើមាតុភូមិនិវត្តរបស់ពលរដ្ឋថៃ ក្នុងអំឡុងកូវីដ-១៩។ ប្រមុខការទូតទាំងពីរ បានសរសើរគ្នាទៅវិញទៅមក លើកិច្ចការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩។ លើសពីនេះ លោក ប្រាក់ សុខុន និង លោក ដុន ប្រាមុដវិណៃ បង្ហាញក្តីរីករាយ ចំពោះពាណិជ្ជកម្មដ៏រឹងមាំនៃប្រទេសពីរ បើទោះបីជាមានការរាលដាលជំងឺកូវីដ-១៩ក្តី។ សេចក្តីប្រកាសព័ត៌មាន បានឲ្យដឹងថា ភាគីកម្ពុជា បានស្នើភាគីថៃ ឲ្យជួយសម្រួលការដឹកជញ្ជូនទំនិញឆ្លងដែន បង្កើនការនាំចូលកសិផលរបស់កម្ពុជា ព្រមទាំងពន្លឿនការចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នាស្តីពីការដឹកជញ្ជូនឆ្លងដែន និងការងារសំខាន់ៗដទៃទៀត៕

## ទូតខ្មែរប្រចាំប្រទេសថៃ ស្នើសុំ៤ចំណុច ទៅភាគីថៃ ដើម្បីនាំប្រយោជន៍ និងជួយដល់ពលករខ្មែរ ក្នុងកំឡុង ការរីករាលដាលជំងឺកូវីដ១៩

https://dap-news.com/ ByVNT108 Posted on October 2, 2020

ភ្នំពេញ៖ ស្របពេលដែល រាជរដ្ឋាភិបាលថៃបាន ប្រកាសដាក់ប្រទេសក្នុងភាពអាសន្ន រយៈពេលមួយខែទៀត លោក អ៊ុក សោភ័ណ ឯកអគ្គរាជទូតកម្ពុជា ប្រចាំប្រទេសថៃ បានស្នើសុំ៤ចំណុច ទៅកាន់លោក សុធាត ឈុំគ្លិន រដ្ឋមន្ត្រីក្រសួងការងារថៃ ដើម្បីនាំប្រយោជន៍ និងជួយដល់ពលករខ្មែរ ក្នុងកំឡុងការរីករាលដាលជំងឺកូវីដ១៩។ ក្នុងជំនួបពិភាក្សាការងារ ជាមួយ លោក សុធាត ឈុំគ្លិន រដ្ឋមន្ត្រីក្រសួងការងារថៃ នៅថ្ងៃទី២ ខែតុលា ឆ្នាំ២០២០ លោក អ៊ុក សោភ័ណ បានស្នើសុំ៤ចំណុច ទៅរដ្ឋមន្ត្រីក្រសួងការងារថៃ ដូចខាងក្រោម៖

១-ស្នើសុំភាគីថៃជួយសម្រួល ដល់ពលករកម្ពុជា ដែលបានដំណើរការចូល មកធ្វើការក្នុងប្រទេសថៃ តាមប្រពន្ធ័ MoU ប៉ុន្តែមិនទាន់បានដំណើរការ ឯកសាររួចរាល់ ដោយសារតែបញ្ហាវិបត្តជំងឺកូវីដ១៩ អាចស្នាក់នៅ និងធ្វើការបណ្តោះអាសន្ន នៅថៃសិន និងរង់ចាំក្រសួងការងារថៃ បើកឲ្យដំណើរការឯកសារ MoU ឡើងវិញ ។

២-ស្នើសុំបញ្ចុះតម្លៃទិដ្ឋាការ ស្នាក់នៅ ពី១, ៩០០បាត ក្នុង១ឆ្នាំ ទៅតម្លៃ៥០០បាត សម្រាប់រយៈពេល២ឆ្នាំ ដល់ពលករខ្មែរ។

៣-ស្នើសុំសម្រួលបើកឱ្យ នាំចូលពលករបរទេស ចូលមកធ្វើការក្នុងប្រទេសថៃ តាមប្រព័ន្ធ MOU ដោយបន្ធូរបន្ថយការចំណាយ លើថ្លៃចត្តាឡីស័កចំនួន ១៤ថ្ងៃ។

៤-ស្នើសុំការនាំពលករចូលមកធ្វើការ នៅខេត្តចាន់ថាក់បុរី ដើម្បីប្រមូលផលផ្លែមៀន ដោយឱ្យសមាគមន៍ និងនិយោជក ជាអ្នកទទួលបន្ទុកលើចំណាយ ក្នុងការចត្តាឡីស័ក ១៤ថ្ងៃ ដោយវគ្គដំបូងនឹងនាំពលករចំនួន ១,០០០នាក់ ដែលប្រើប្រាស់ប័ណ្ណព្រំដែន (border pass)។

ជាការឆ្លើយតប ភាគីថៃបានឆ្លើយតប និងស្នើចំនួនពីរចំណុចដូចខាងក្រោម:

-ភាគីថៃនឹងពិភាក្សាផ្ទៃក្នុង បន្ទាន់លើចំនុចទាំង៤ ខាងលើ និងជម្រាបមកភាគីកម្ពុជា វិញឲ្យបានឆាប់ ។

-ស្នើឲភាគីកម្ពុជា ជួយពន្លឿនបញ្ជូនពលករចំនួន ១,០០០នាក់ ដែលប្រើប័ណ្ណព្រំដែន ចូលតាមច្រកបានឡែម ខេត្តចាន់ថាក់បុរី និងច្រកដូង ខេត្តបាត់ដំបង៕

## យោធាថៃចាប់ពលករខ្មែរចំណាកស្រុក ៧ នាក់ឆ្លងដែនខុសច្បាប់ទៅរកការងារធ្វើ ក្នុងស្ថានភាព កូវីដ-១៩មិនទាន់ធូរស្បើយ

http://nokorwatnews.com/ 04-10-2020

ក្រុងប៉ោយប៉ែត៖ ពលករខ្មែរឆ្លងដែនខុសច្បាប់ចំនួន៧នាក់ ត្រូវសមត្ថកិច្ចថៃចាប់បានជាបន្តបន្ទាប់កាលពីថ្ងៃទី៣ ខែតុលា ឆ្នាំ២០២០ នេះខណៈស្ថានការណ៍នៃការរាតត្បាតជំងឺកូវីដ-១៩មិនទាន់ធូរស្បើយនៅតាមបន្ទាត់ព្រំដែនថៃ-កម្ពុជា ខេត្តស្រះកែវ។ ប្រភពពីព្រំដែនខ្មែរថៃបានឲ្យដឹងថា នៅថ្ងៃ៣តុលានេះ សមត្ថកិច្ចកងរយទាហានប្រាណទី1205 កងកម្លាំងបូរផា បានចាត់កម្លាំងល្បាតនិងតាមឃ្លាំមើលក្នុងតំបន់ទទួលខុសត្រូវ ហើយបានពិនិត្យឃើញពលរដ្ឋខ្មែរ កំពុងដើរចំនួន៣នាក់ ក្នុងនោះមានប្រុស២នាក់ស្រី១នាក់ នៅបរិវេណភូមិប៉ារ៉ៃ ឃុំប៉ារ៉ៃ ស្រុកអារញ្ញ ខេត្តស្រះកែវ ក៏ឃាត់ខ្លួន។ពលករខ្មែរទាំង៣នាក់ នោះមានឈ្មោះ

១/ឈ្មោះប៊ុន ឌី ប្រុស អាយុ៣៧ឆ្នាំ។

២/ឈ្មោះ ខែម ឡា ប្រុស អាយុ២០ឆ្នាំ ។

៣/ឈ្មោះ ម៉ានី ស្រី អាយុ៤០ឆ្នាំ ។ អ្នកទាំង៣រស់នៅសង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ មិនមានឯកសារធ្វើដំណើរត្រឹមត្រូវ ហើយចូលទៅប្រទេសថៃ ដើម្បីរកការងារធ្វើ ស៊ីឈ្នួលទូទៅផ្នែកកសិកម្ម នៅទឹកដីឃុំប៉ារ៉ៃ ស្រុកអារញ្ញ ដោយសារខាងកម្ពុជា មិនមានការងារធ្វើ ។

ពលករទាំងនោះនិយាយថា ពួកគាត់អ្នកខ្លះធ្លាប់ចូល-ចេញថៃ ២០លើកហើយ។ ទើបតែម្តងនេះសមត្ថកិច្ចថៃចាប់ខ្លួនពួកគាត់នាំខ្លួនទៅឲ្យកងរយទី127 ក្នុងភូមិ ណូន ម៉ាកមុន ដើម្បីឲ្យត្រឡប់ទៅប្រទេសកម្ពុជាវិញ។

ប្រភពមួយទៀតបានឲ្យដឹងថាថា ប៉ុន្មានម៉ោងមុននេះ អំឡុងពេលសមត្ថកិច្ចទាហានចេញល្បាត ក៏បានប្រទះឃើញបុគ្គលគួរឲ្យសង្ស័យចំនួន៤នាក់ទៀត ក្នុងនោះប្រុស២នាក់ ស្រី១នាក់និងក្មេងប្រុស១នាក់កំពុងដើរមកតាមផ្លូវក្នុងទឹកដីថៃ ព្រមទាំងស្ពាយសម្ភារៈផង ឆ្លងកាត់បរិវេណភូមិណង ញ៉ាផ្លុង ឃុំប៉ារ៉ៃ ។ពលករទាំងនេះបានព្យាយាមរត់ឆ្លងដែនទៅប្រទេសកម្ពុជា ដើម្បីធ្វើដំណើរត្រឡប់ទៅភូមិលំនៅឋានវិញ ទើបសមត្ថកិច្ចថៃចាប់ឃាត់ខ្លួននាំមកសួរចម្លើយ ក្នុងនោះមានឈ្មោះដូចខាងក្រោម៖

១/ឈ្មោះ អ៊ាន ណោត ប្រុស អាយុ២៤ឆ្នាំ

២/ឈ្មោះអ៊ាន មេក ប្រុស អាយុ២៧ឆ្នាំ

៣/ឈ្មោះ គួង សាឡេន ស្រី អាយុ២០ឆ្នាំ និងក្មេងប្រុសម្នាក់ទៀត។

អ្នកទាំង៤រស់នៅខេត្តបាត់ដំបង ចូល-ចេញ ប្រទេសថៃ២០-២២ លើកមកហើយ ដោយមិនមានឯកសារធ្វើដំណើរ ។ក្រោយពីសមត្ថកិច្ចសួរចម្លើយនឹងចុះក្នុងកំណត់ហេតុ ទើបនាំខ្លួនបញ្ជូនទៅឲ្យកងរយទី127 ក្នុងភូមិ ណូន ម៉ាកមុន ដើម្បីបញ្ជូនត្រឡប់មកប្រទេសកម្ពុជាវិញ ៕**ដោយៈវណ្ណា**

## ពលករខ្មែរឆ្លងដែនខុសច្បាប់ មានចំនួន ៦៤នាក់ ត្រូវ អាជ្ញាធរថៃបញ្ជូនមកស្រុកកំណើតវិញ, ឯ ១៣៧នាក់ទៀត បន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់

https://www.cen.com.kh/ October 5, 2020

ប៉ោយប៉ែត៖ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី៤ ខែតុលា ឆ្នាំ២០២០ មានពលករខ្មែរឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ៦៤នាក់ ស្រី ១៦នាក់ និងកុមារ ៣នាក់។ ចំពោះពលករខាងលើត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធន់ធំដំណើរការជាធម្មតា។

ចំណែកនៅថ្ងៃទី៤ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការនិងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៣៧នាក់ ស្រី ៦៣នាក់ និងពលរដ្ឋថៃដែលបានចាកចេញមានចំនួន ៣នាក់ ស្រី ១នាក់ ដោយមានឯកសារចេញពីស្ថានទូតថៃ និងលិខិតបញ្ជាក់សុខភាព៕ **ដោយ៖កូឡាប**

## ពលករខ្មែរលួចឆ្លងដែនចូលប្រទេសថៃ៥នាក់ត្រូវទាហានថៃចាប់បញ្ជូនមកកម្ពុជាវិញ

http://nokorwatnews.com/ 04-10-2020

ខេត្តបន្ទាយមានជ័យ៖យោងតាមការចុះផ្សាយសระแก้ว-77 ข่าวเด็ด-កាលពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០២០ នេះថា កងកម្លាំងការពារព្រំដែនថៃកំពុងធ្វើការរឹតបន្តឹង បញ្ហាលបលួចចូលប្រទេសថៃដោយខុសច្បាប់ ជាពិសេសតាមច្រករបៀង អំឡុងពេលបិទព្រំដែន ដើម្បីទប់ទល់ការរាតត្បាតជំងឺកូវីដ-19 តាមបន្ទាត់ព្រំដែនកម្ពុជា ថៃខេត្តស្រះកែវ យ៉ាងតឹងរ៉ឹង ។ ចុងក្រោយ សមត្ថកិច្ចទាហានប្រាណកងវរយទី1205 បានត្រួតពិនិត្យឃើញពលករខ្មែរចំនួន៥នាក់ខណៈកំពុងធ្វើដំណើរជិតព្រំដែនថៃក្នុងនោះមានប្រុស៣ ស្រី២ នៅត្រង់បរិវេណភូមិណា ឃ្លៀង ឃុំប៉ាវ៉ៃ ស្រុកអារញ្ញ ទើបឃាត់ខ្លួនយកទៅសាកសួរ នៅទីបញ្ជាការកងវរយទាហានប្រាណទី1205។

សមត្ថកិច្ចថៃបានឲ្យដឹងថា បន្ទាប់ពីបានសួរនាំ ទើបដឹងថា ពលរដ្ឋខ្មែរខាងលើនេះបាន ធ្វើដំណើរចូលមកប្រទេសថៃដើម្បីរកការងារធ្វើ ស៊ីឈ្នួលទូទៅខាងផ្នែកកសិកម្ម ដាំអំពៅ,ដំឡូង នៅក្នុងទឹកដីឃុំប៉ាវ៉ៃ ស្រុកអារញ្ញ ដោយសារនៅខាងប្រទេសកម្ពុជាមិនមានការងារធ្វើ និងដោយធ្លាប់ចូល-ចេញប្រទេសថៃជាច្រើនលើក តាមច្រកព្រំដែនអន្តរជាតិខ្លងលឹក-ប៉ោយប៉ែត។ តែដោយសារប្រទេសទាំង២បិទព្រំដែន ទើបលួចចូលប្រទេសថៃតាមច្រករបៀង ដើម្បីរកការទូទៅធ្វើតែប៉ុណ្ណោះ។ក្រោយពីសមត្ថកិច្ចសួរនាំ ពិនិត្យវាស់កម្តៅរាងកាយនឹងសរសេរកំណត់ហេតុរួចរាល់ សមត្ថកិច្ចក៏បញ្ជូនពលរដ្ឋខ្មែរទាំងនេះប្រគល់តម្រួតការពារព្រំដែនទី127 ភូមិណួន ម៉ាកមុន ដើម្បីទំនាក់ទំនងភាគីកម្ពុជាឲ្យត្រឡប់ទៅស្រុកកំណើតវិញ តាមច្រករបៀងត្រួតពិនិត្យភូមិអូរបីជាន់ឃុំអូរបីជាន់ស្រុកអូរជ្រៅឈមនឹងភូមិ-ណួន ម៉ាកមុន ប្រទេសថៃ៕ **ដោយ ៖ វណ្ណា**

## ស្ត្រី ខ្មែរ ២រូបបម្រើការងារ នៅម៉ាឡេស៊ី ត្រូវបាននិយោជក វាយធ្វើបាប និងមិនបើកប្រាក់ខែឲ្យ

https://dap-news.com/national/ ByPH104 Posted on October 4, 2020

ភ្នំពេញ ៖ ស្ថានទូត នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅប្រទេសម៉ាឡេស៊ី បានជួយដល់ពលការិនីចំនួន ២រូប ដែលបម្រើការងារ នៅប្រទេសម៉ាឡេស៊ី ត្រូវបាននិយោជក វាយធ្វើបាប និងមិនបើកប្រាក់ខែឲ្យ ។ ពលការិនីទាំង២នាក់នោះរួមមាន ៖

១-ពលការិនី ងួន រ៉ាន់ អាយុ ៣១ឆ្នាំ មកពីភូមិចារ ឃុំកណ្តៀង ស្រុកកណ្តៀង ខេត្តពោធិ៍សាត់ បានមកធ្វើការងារផ្ទះ ដោយស្របច្បាប់ ជាមួយនិយោជក ឈ្មោះ Wing SaiLoong នៅទីក្រុងកូឡាឡាំពួរ តាមរយៈក្រុមហ៊ុនឈ្មោះ CECH កាលពីឆ្នាំ 2010 ។ ដោយចង់ត្រឡប់ទៅកម្ពុជាវិញ ពលការិនីបានរត់ចេញពីផ្ទះនិយោជក និងបានមកដល់ស្ថានទូត នៅថ្ងៃទី ៣១ ខែកញ្ញាឆ្នាំ ២០២០ ស្ថានទូតបានជួយសម្របសម្រួល ទាមទារប្រាក់ខែ នៅខ្វះពីនិយោជក ចំនួន ៣៨៨០០រីងហ្គីត ប្រមាណ ៩ពាន់ដុល្លារអាមេរិក និងស្នើនិយោជករៀបចំ ឯកសារពាក់ព័ន្ធទៅអគ្គនាយកដ្ឋាន អន្តោប្រវេសន៍ម៉ាឡេស៊ី ដើម្បីពលការិនី អាចត្រឡប់ទៅកម្ពុជាបាន ។ ក្នុងអំឡុងពេលរង់ចាំត្រឡប់ទៅកម្ពុជាវិញ ស្ថានទូតបានផ្តល់កន្លែងស្នាក់នៅ និងម្ហូបអាហារបរិភោគ ព្រមទាំងចាត់មន្ត្រីជូនពលការិនី ខាងលើទៅអាកាសយានដ្ឋានអន្តរជាតិ KLAI ផងដែរ ។

២-ពលការិនី ឯល ម៉ារី អាយុ ៣២ឆ្នាំ មកពីខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ បានមកធ្វើការងារផ្ទះ ដោយខុសច្បាប់ នៅBentong រដ្ឋPahang កាលពីខែមីនា ឆ្នាំ ២០១៨ តាមរយៈមេខ្យល់ឈ្មោះហាសាណាស់ ។ ពលការិនីត្រូវនិយោជកប្រើឲ្យធ្វើការងារផ្ទះ និងជួយលក់ខោអាវ គ្មានពេលសម្រាក និងមិនផ្តល់ការហូបចុកគ្រប់គ្រាន់ ។ ពលការិនីបានរត់ចេញពីផ្ទះ និយោជកនៅថ្ងៃទី២ ខែឧសភា ឆ្នាំ ២០២០ ព្រោះត្រូវនិយោជក បានវាយធ្វើបាប ជា

ប្រចាំមានស្នាមពេញដៃជើង ហើយជាចុងក្រោយត្រូវ វាយបាក់ធ្មេញមុខពីរ ។ នៅតាមផ្លូវពលការិនី បានរត់ទៅជួប អ្នកទទួលខុសត្រូវ មជ្ឈមណ្ឌលសាសនា ឈ្មោះមហាម៉េត អាសាំអាស៊ីមូត និងបានសូមឲ្យគាត់ជួយ។

អ្នកទទួលខុសត្រូវ នៅមជ្ឈមណ្ឌល បាននាំពលការិនី ទៅប្ដឹងប៉ូលិស នៅតំបន់នោះ ហើយនិយោជក ត្រូវប៉ូលីសចាប់ប្រកាន់ពីបទ ប្រើប្រាស់ការងារ ដោយបង្ខំនិងកំពុងដំណើរការក្ដីនៅតុលាការ។ បច្ចុប្បន្នពលការិនីកំពុងស្នាក់នៅ ក្នុងមជ្ឈមណ្ឌលស្នាក់នៅ របស់រដ្ឋាភិបាលម៉ាឡេស៊ី ចំពោះប្រាក់ខែ និងសំណងផ្សេងៗ អាជ្ញាធរម៉ាលេស៊ីនឹងរៀបចំទៅតាមការសម្រេច របស់តុលាការ នៅពេលបញ្ចប់ការកាត់ក្ដី នៅថ្ងៃទី ២៥ខែវិច្ឆិកាឆ្នាំ ២០២០ ។ ដោយពលការិនីនិងគ្រួសារ នៅកម្ពុជាមានជីវភាពក្រីក្រខ្លាំង អង្គការសម្ព័ន្ធចាប់ដៃនៅកម្ពុជា ក៏បានជួយទិញសំបុត្រ យន្តហោះជូនផងដែរ៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៩៧នាក់

https://www.facebook.com/GDIOfficial 02-10-2020

នៅថ្ងៃទី០២ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្ដោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការនិងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៩៧នាក់ ស្រី ៧៨នាក់៕

## ប្រជាពលរដ្ឋខ្មែរចំនួន ០៧នាក់ បានធ្វើដំណើរតាមច្រករបៀងស្លាបធ្វេង-ស្លាបស្ដាំ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង

https://www.facebook.com/GDIOfficial 02-10-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី០២ ខែតុលា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារមិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបធ្វេង-ស្លាបស្ដាំចំនួន ០៧នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត បានពលករខ្មែរឆ្លងដែនខុសច្បាប់ ចំនួន ១២នាក់ ពីអាជ្ញាធរថៃ

https://www.facebook.com/GDIOfficial 02-10-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី០២ ខែតុលា ឆ្នាំ២០២០ មានពលករខ្មែរឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ១២នាក់ ស្រី ០៣នាក់។ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធន់ធំ ដំណើរការជាធម្មតា៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១១២នាក់

https://www.facebook.com/GDIOfficial 03-10-2020

នៅថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការនិងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១១២នាក់ ស្រី ៤២នាក់៕

## ភាគីថៃបានបញ្ជូនពលរដ្ឋខ្មែរចំនួន ០៧នាក់ ឲ្យមកប៉ុស្តិ៍នគរបាលច្រកទ្វារបព្រំដែនអន្តរជាតិដាំ ពីបទឆ្លងដែនខុសច្បាប់

https://www.facebook.com/GDIOfficial 03-10-2020

នៅថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២០ ខាងភាគីថៃបានបញ្ជូនពលរដ្ឋខ្មែរចំនួន ០៧នាក់ ឲ្យមកប៉ុស្តិ៍នគរបាលច្រកទ្វារបព្រំដែនអន្តរជាតិដាំ ពីបទឆ្លងដែនខុសច្បាប់ ទៅកាប់ឈើនៅប្រទេសថៃ ដែលចេញតាមច្រកអូរស្វាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ៕

## ថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២០

### អភិបាលរងខេត្តក្រចេះ និងអង្គភាពពាក់ព័ន្ធជុំវិញស្រុកចូលរួមផ្សព្វផ្សាយលក្ខណៈសម្បត្តិទាំង៩យ៉ាង

http://cambodiapolice.com/policekh/ 2:13 pm 5 តុលា 2020

ខេត្តក្រចេះ ៖ ឯកឧត្តម លី ផល្លា និង ឯកឧត្តម គង់ គឹមនី អភិបាលរងខេត្តក្រចេះ បានអញ្ជើញអធិបតីបើកវេទិកាសាធារណៈថ្នាក់ជាតិ នៅសាលាឃុំស្រែចារ និងមានអង្គភាពពាក់ពន្ធ័ជុំវិញស្រុកចូលរួម ក្នុងនោះដែរកម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាលបានធ្វើការផ្សព្វផ្សាយ ផ្សព្វផ្សាយ លក្ខណៈសម្បត្តិទាំង៩យ៉ាង ជូនដល់ប្រជាពលរដ្ឋនៅថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង០៨និង០០នាទី ។ លក្ខណសម្បត្តិ៩យ៉ាងរួមមាន ៖

១.ផ្សព្វផ្សាយសេចក្តីចូលរួមអំពាវនាវចូលរួមគាំទ្រយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់នៅកម្ពុជា ។
២.ផ្សព្វផ្សាយ រួមគ្នាបង្ការទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីត( ១៩ )។
៣.ចែក សារសម្រាប់អប់រំអំពីផល់ប៉ះពាល់គ្រោះថ្នាក់នៃគ្រឿងញៀន ។
៤.ផ្សព្វផ្សាយច្បាប់ចរាចរណ៍ផ្លូវគោកថ្មី រួមគ្នាបង្ការទប់ស្កាត់បទល្មើសបញ្ហាចោរកម្ម គ្រប់ប្រភេទ ។
៥.ផ្សព្វផ្សាយ រួមគ្នាបង្ការការប្រើអំពើហឹង្សាទាក់ទងនឹងយេនឌ័រ,អំពើជួញដូរស្ត្រីនិងកុមារ ។
៦.ផ្សព្វផ្សាយគ្រោះថ្នាក់ដោយសារយុទ្ធភ័ណ្ឌគ្រាប់មិនទាន់ផ្ទុះ។
៧.ផ្សព្វផ្សាយ អំពីការលេងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ ។
៨.ផ្សព្វផ្សាយអំពីគ្រោះអគ្គីភ័យ។

នៅក្នុងនោះកម្លាំងបានធ្វើការផ្សព្វផ្សាយនូវលក្ខណៈសម្បត្តិទាំង៩យ៉ាង របស់គោលនយោបាយភូមិឃុំមានសុវត្ថិភាព ដែលមានប្រជាពលរដ្ឋចូលរួមចំនួន១៦៦នាក់ ស្រី២៥នាក់៕

# ថៃចាប់ផ្សឹកព្រះសង្ឃខ្មែរ១០អង្គ ក្រោយឆ្លងដែនខុសច្បាប់

https://kohsantepheapdaily.com.kh/ ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០២០ ម៉ោង ០៩:០៣ មុំត សារុន

ខេត្តបន្ទាយមានជ័យ ៖ ព្រះសង្ឃខ្មែរចំនួន១០អង្គត្រូវបានសមត្ថកិច្ចថៃចាប់ផ្សឹកនៅស្រុកគោកឃ្សូង ខេត្តស្រះកែវ ប្រទេសថៃ នេះបើយោងតាមការចេញផ្សាយលើគេហទំព័រនិងកាសែតក្នុងស្រុកថៃមួយកាលពីថ្ងៃទី៤ តុលា ឆ្នាំ២០២០។ គេពុំដឹងថាព្រះសង្ឃទាំង១០អង្គខាងលើនោះជាសង្ឃពិតប្រាកដ ឬក្លែងក្លាយនោះទេ ប៉ុន្តែកន្លងមកភាគីថៃតែងចាប់បានសង្ឃក្លែងក្លាយបញ្ជូនឲ្យមន្ត្រី និងសមត្ថកិច្ចកម្ពុជាតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែតថែមទាំងដឹកក្នុងរថយន្តទ្រុងដូចជាគ្រហស្ថទៀតផង។ យោងតាមការសាកសួរ ព្រះសង្ឃទាំង១០អង្គខាងលើ ក្រោយឆ្លងព្រំដែនបានជិះម៉ូតូឌុបទៅរករថយន្តជិះប្រុងឆ្ពោះទៅវត្តមួយនៅក្រុងបាងកកដើម្បីបិណ្ឌបាតរកប្រាក់និងទេសចរ ។

ទោះជាយ៉ាងណា ករណីនេះសមត្ថកិច្ចថៃក៏បានឃាត់ខ្លួនជនជាតិថៃ៣នាក់ ដែលយករថយន្តមកចាំទទួលព្រះសង្ឃទាំងអស់នៅចំណុចកើតហេតុផងដែរ ។ ព្រះសង្ឃទាំង១០អង្គខាងលើត្រូវបានសមត្ថកិច្ចថៃប្រគល់ឲ្យមន្ត្រីជំនាញក្នុងស្រុកគោកឃ្សូងផ្សឹកដើម្បីចាត់ការបន្ត ។ ចំណែកជនជាតិថៃ៣នាក់ត្រូវបញ្ជូនឲ្យសមត្ថកិច្ចជំនាញចាត់ការតាមផ្លូវច្បាប់៕ (កែសម្រួលដោយ ៖ ធីតា)

# ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១២៨នាក់

https://www.facebook.com/GDIOfficial 05-10-2020

នៅថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្ដោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការនិងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១២៨នាក់ ស្រី ៥៤នាក់៕

# ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត បានពលករខ្មែរឆ្លងដែនខុសច្បាប់ ចំនួន ៦៤នាក់ ពីអាជ្ញាធរថៃ

https://www.facebook.com/GDIOfficial 04-10-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២០ មានពលករខ្មែរឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ៦៤នាក់ ស្រី ១៦នាក់ និងកុមារ ០៣នាក់។ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធន់ធំដំណើរការជាធម្មតា៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៣៧នាក់

https://www.facebook.com/GDIOfficial 04-10-2020

នៅថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការនិងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៣៧នាក់ ស្រី ៦៣នាក់ និងពលរដ្ឋថៃដែលបានចាកចេញមានចំនួន ០៣នាក់ ស្រី ០១នាក់ ដោយមានឯកសារចេញពីស្ថានទូតថៃ និងលិខិតបញ្ជាក់សុខភាព៕

## រដ្ឋាភិបាលកម្ពុជា ស្នើសុំថៃឱ្យទទួលយកពលករខ្មែរទៅធ្វើការវិញ និងសុំបញ្ចុះថ្លៃធ្វើចត្តាឡីស័ក

https://www.rfa.org/khmer/ 2020-10-05

មន្ត្រីសង្គមស៊ីវិល ជំរុញឲ្យរដ្ឋាភិបាល ខិតខំបង្កើនមុខរបរក្នុងស្រុក ឲ្យពលរដ្ឋធ្វើ ប្រសើរជាង បញ្ជូនពលរដ្ឋទៅធ្វើការជាពលករ។ ការលើកឡើងនេះ ក្រោយពេលរដ្ឋាភិបាលកម្ពុជា បន្តស្នើសុំរដ្ឋាភិបាលថៃជាថ្មី ឲ្យទទួលយកពលរដ្ឋខ្មែរ ទៅធ្វើការនៅប្រទេសថៃវិញ និងស្នើសុំឲ្យបញ្ចុះថ្លៃចត្តាឡីស័កសម្រាប់ពួកគេ ប៉ុន្តែមកទល់ពេលនេះ រដ្ឋាភិបាលថៃ មិនទាន់ឆ្លើយតបសំណើកម្ពុជានៅឡើយទេ។

មន្ត្រីកម្មវិធីផ្នែកទេសន្តរប្រវេសក៍ នៃមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស ហៅកាត់ថា អង្គការសង់ត្រាល់ លោក ឌី ថេហូយ៉ា សោកស្តាយចំពោះរដ្ឋាភិបាល ដែលធ្លាប់បានប្រកាស ពីកិច្ចខិតខំប្រឹងប្រែង បង្កើនមុខរបរក្នុងស្រុក ឲ្យពលករ ដែលបាត់បង់ការងារធ្វើក្នុងសម័យកាលផ្ទុះជំងឺកូវីដ១៩ (Covid-19) តែពលរដ្ឋ នៅតែប្រថុយប្រថានលួចឆ្លងដែនខុសច្បាប់ ទៅរកការងារធ្វើនៅប្រទេសថៃដដែល។ អ្នកឃ្លាំមើលសិទ្ធិពលកររូបនេះ ជំរុញឲ្យរដ្ឋាភិបាល ខិតខំបង្កើនមុខរបរក្នុងស្រុកបន្ថែមទៀត ដើម្បីធានាឲ្យបានថា ពលរដ្ឋពិតជាមានការងារធ្វើ និងប្រាក់ចំណូលសមរម្យ៖ «កត្តាក្នុងស្រុក វាមិនមានការគ្រប់គ្រាន់ ប្រាក់ឈ្នួលទាបជាងអ្វីអ៊ីចឹង វាជាជម្រើសគាត់ទៅក្រៅហើយ។ បើដឹងថា គាត់ទៅក្រៅហើយ ត្រូវតែបង្កើតគោលនយោបាយ យន្តការ គាំពារ ធ្វើម្តេច ការពារផលប្រយោជន៍ ការពារសិទ្ធិរបស់ពួកគាត់ហ្នឹង ឲ្យបានល្អ។ កុំឲ្យចំណាកស្រុក ក្នុងន័យបង្ខំ(ចិត្ត) ក្នុងន័យជំពាក់បំណុលគេ ព្រោះយើងមើលភាពជាក់ស្តែង ដែលយើងធ្វើការជាមួយពលករហ្នឹង ហេតុផលអ្វី បានមក(ធ្វើការ) ស្រុកគេ? ហេតុផល ដែលជំពាក់លុយគេហ្នឹង ៧០ភាគរយ ហើយ៧០ភាគរយហ្នឹង សួរថា មក (ស្រុកគេ) ហ្នឹងមានលុយ (ធ្វើដំណើរ) ខ្លួនឯង ឬខ្ចីគេ ហើយភាគច្រើនគឺខ្ចីគេ។ ដល់អ៊ីចឹងទៅ វាថែមបំណុលទៀត»។

កាលពីថ្ងៃទី២ ខែតុលា ក្រសួងការបរទេស និងស្ថានទូតខ្មែរប្រចាំទីក្រុងបាងកក បានស្នើសុំជាថ្មីទៀត ទៅភាគីថៃ ក្នុងជំនួបដាច់ដោយឡែកគ្នា សុំឲ្យរដ្ឋាភិបាលថៃ ទទួលយក**ពលករកម្ពុជា ដែលកាន់ប័ណ្ណឆ្លងព្រំដែន (border passes) និង ពលករ ដែលចុះឈ្មោះធ្វើការតាមប្រព័ន្ធអនុស្សរណៈយោគយល់គ្នា (MOU) អាចវិលត្រឡប់ចូលទៅធ្វើការនៅប្រទេសថៃវិញ និងសុំឲ្យបញ្ចុះថ្លៃទិដ្ឋាការ និងថ្លៃធ្វើចត្តាឡីស័កជាដើម។**

អាស៊ីសេរី មិនអាចសុំការបញ្ជាក់បន្ថែមពីឯកអគ្គរាជទូតប្រចាំទីក្រុងបាងកក លោក អ៊ុក សោភ័ណ បានទេ នៅថ្ងៃទី៤ តុលា ដោយសារទូរស័ព្ទពេទ៍គ្មានអ្នកទទួល។ ប៉ុន្តែស្ថានទូតបានសរសេរក្នុងបណ្តាញសង្គម

(facebook) ថា ភាគីថៃបានទទួលយកសំណើទាំងអស់ ទៅពិភាក្សាផ្ទៃក្នុង និងប្រាប់ឲ្យ ត្រៀមបញ្ជូនពលករចំនួន ១.០០០នាក់ តាមច្រកទ្វែម និងច្រកដូង ចូលខេត្តចាន់ថាក់បូរី (Chanthaburi)។

ពលករម្នាក់ កំពុងធ្វើការនៅប្រទេសថៃ លោក នូវ ប៊ុនរ័ត្ន ប្រាប់ថា ថៃបន្តបិទប្រទេសបន្តទៀត ដូច្នេះ ជាគោលការណ៍ គឺថៃលែងទទួលយកពលករទាំងអស់ចូលធ្វើការ។ ប៉ុន្តែពលរដ្ឋខ្មែរនៅតែបន្តប្រថុយលួចឆ្លងដែនខុសច្បាប់រត់កាត់ព្រៃ ឆ្លងភ្នំ ស្ទឹង អូរ ចូលប្រទេសថៃ រាល់ថ្ងៃរាល់យប់ ដោយសារ គ្មានការងារធ្វើនៅស្រុកកំណើត។ ពលកររូបនេះឲ្យដឹងថា ការប្រថុយលួចឆ្លងដែនខុសច្បាប់ ទៅរកការងារធ្វើ ទាំងស្ថានភាពថៃកំពុងបិទប្រទេសនៅឡើយនេះ បណ្ដាលឲ្យពលករខ្មែរ ត្រូវចំណាយលុយ អស់ច្រើនជាងការឆ្លងដែនស្របច្បាប់ គឺច្រើនជាងប្រហែលគុណនឹង ១០ដង ដោយសារឈ្នួញ ឬមេខ្យល់ នាំដើរផ្លូវវៀងឆ្ងាយ លុកព្រៃជ្រៅ ឡើងភ្នំ ដើម្បីរត់គេចពីប៉ូលិសថៃ ហើយពេលខ្លះ មានករណីគ្រោះថ្នាក់ចរាចរណ៍កើតឡើង ចំពោះឡានដឹកពលករឆ្លងដែនខុសច្បាប់ ជាដើម។ លោក បន្តថា អ្នកដែលអាចលួចឆ្លងដែនខុសច្បាប់នេះ ប្រឈមនឹងប៉ូលិសចាប់ខ្លួនបានយកទៅឃុំ ហើយបញ្ជូនចេញ ទៅប្រទេសកំណើតវិញ។ ឯអ្នកលួចឆ្លងដែនជោគជ័យ ចូលដល់ភាគកណ្ដាលប្រទេសថៃបាន ក៏នៅតែប្រឈមការអត់ការងារធ្វើដែរ ដោយសារ រោងចក្រខ្លះ ក្ស័យធន ឯរោងចក្រខ្លះ មិនត្រូវការរើសកម្លាំងពលកម្មបន្ថែម និងនិយោជកខ្លះ មិនយកអ្នកឆ្លងដែនខុសច្បាប់ជាដើម៖ «ប៉ុន្តែចំពោះម្យ៉ាងទៀត រឿងការងារនៅតែជាបញ្ហាសម្រាប់ពលករខ្មែរយើងដដែល ដោយសារអ្វី រោងចក្រខ្លះក្ស័យធន ត្រូវបិទទ្វារចោល។ រោងចក្រខ្លះ ក៏គេយក អ្នកចាស់។ ប៉ុន្តែ អ្នកថ្មី ដែលគាត់មកដាក់ពាក្យ ដាក់ CV រកការងារហ្នឹង គេអត់ទទួលយក។ អ៊ីចឹង ធ្វើឲ្យពួកគាត់ហ្នឹង អត់ការងារដដែល»។

របាយការណ៍របស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ គិតត្រឹមឆ្នាំ២០១៩ បង្ហាញថា ពលករខ្មែរធ្វើការនៅប្រទេសថៃ មានប្រហែលមួយលាន (១.០០០.០០០) នាក់។

លោក ឌី ថេហូយ៉ា ឲ្យដឹងថា ស្ថានភាពជាក់ស្ដែង ពលករខ្មែរធ្វើការ ទាំងមានច្បាប់ និងខុសច្បាប់ នៅប្រទេសថៃ មានខ្ទង់ពីរលាន (២.០០០.០០០) នាក់ ភាគច្រើនក្នុងវិស័យសំណង់ និងកសិកម្ម។ លោក ប្រាប់ថា តាំងពីប្រទេសថៃ បិទប្រទេសដាក់ក្នុងភាពអាសន្ន ចាប់ពីខែមីនាមក ពលករខ្មែរ ជាងមួយម៉ឺន (១០.០០០) បានលួចឆ្លងដែន ចូលទៅប្រទេសថៃ រកការងារធ្វើជាបន្តបន្ទាប់ តែភាគច្រើន ត្រូវថៃចាប់បាន ហើយបញ្ជូនត្រឡប់មកវិញ៕

## ថ្ងៃទី០៧ ខែតុលា ឆ្នាំ២០២០

## នាយឧត្តមសេនីយ៍ គៀត ច័ន្ទថារិទ្ធ ៖ បង្កើនកិច្ចការងារគ្រប់គ្រងជនអន្តោប្រវេសន៍ ឆ្លងដែនដោយខុសច្បាប់ និងពលរដ្ឋខ្មែរ លួចឆ្លងដោយខុសច្បាប់ ជាពិសេសប្រទេសថៃ

https://www.cen.com.kh/archives/ October 6, 2020

ភ្នំពេញ៖ នាព្រឹកថ្ងៃអង្គារ ទី៦ ខែតុលា ឆ្នាំ២០២០ ឯកឧត្តម នាយឧត្តមសេនីយ៍ គៀត ច័ន្ទថារិទ្ធ អគ្គនាយកអន្តោប្រវេសន៍ បានអញ្ជើញដឹកនាំកិច្ចប្រជុំ លទ្ធផលការងារប្រចាំខែកញ្ញា និងទិសដៅការងារខែតុលា ឆ្នាំ២០២០ របស់អគ្គនាយកដ្ឋានអន្តោប្រវេសន៍។ ក្នុងកិច្ចប្រជុំនេះ ក៏មានការអញ្ជើញចូលរួមពី ឯកឧត្តម នាយឧត្តមសេនីយ៍ ឧត្តមសេនីយ៍ឯក ឧត្តមសេនីយ៍ទោ អគ្គនាយករង, ប្រធាននាយកដ្ឋានទាំងអស់ រួមជាមួយលោកស្នងការរងទទួលបន្ទុកអន្តោប្រវេសន៍ រាជធានី-ខេត្ត និងមន្ត្រីជំនាញដែលពាក់ព័ន្ធ។

បន្ទាប់ពីបានទទួលស្ដាប់របាយការណ៍ ដែលអានដោយឯកឧត្តម ឧត្តមសេនីយ៍ឯក ពុំ វិត្យា ប្រធាននាយកដ្ឋានរដ្ឋបាលសរុប និងមតិយោបល់ចូលរួម របស់ឯកឧត្តម អគ្គនាយករង ប្រធាននាយកដ្ឋាន និងស្នងការរង រាជធានី-ខេត្ត រួចមក ឯកឧត្តម នាយឧត្តមសេនីយ៍ គៀត ច័ន្ទថារិទ្ធ បានមានប្រសាសន៍ បូកសរុបដែរថា ដោយស្ថានភាពនៃជំងឺកូវីដ-១៩ បានបណ្ដាលឲ្យអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ខកខានការប្រជុំប្រចាំខែជាច្រើនខែដែរ ដូចនេះកិច្ចប្រជុំពេលនេះដើម្បី ត្រួតពិនិត្យលើលទ្ធផលការងារ បញ្ហាប្រឈម ក្នុងរយៈពេលកន្លងមក។

ឯកឧត្តម អគ្គនាយកដ្ឋានអន្តោប្រវេសន៍ ក៏បានណែនាំទៅដល់មន្ត្រីនៅតាមច្រកព្រំដែនទាំងអស់ ត្រូវបង្កើនការគ្រប់គ្រងពលរដ្ឋឆ្លងដែនដោយខុសច្បាប់ ដើម្បីធានាឲ្យបាននូវសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ នៅតាមច្រកទ្វារព្រំដែន និងទប់ស្កាត់ការចំណាកស្រុកដោយខុសច្បាប់ ជៀសផុតពីជំងឺឆ្លងកូវីដ-១៩។ ឯកឧត្តម នាយឧត្តមសេនីយ៍ គៀត ច័ន្ទថារិទ្ធ អគ្គនាយក នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ បានណែនាំទៅដល់មន្ត្រីនគរបាលអន្តោប្រវេសន៍ទាំងអស់ ត្រូវបង្កើនកិច្ចសហការជាមួយ មន្ត្រីពាក់ព័ន្ធទាំងអស់ ដើម្បីបម្រើសេវាសាធារណៈជូនភ្ញៀវជាតិ និងអន្តរជាតិ ឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់បន្ថែមទៀត ជាពិសេសត្រូវបង្កើនកិច្ចការងារគ្រប់គ្រងជនអន្តោប្រវេសន៍ឆ្លងដែនដោយខុសច្បាប់ និងពលរដ្ឋខ្មែរ លួចឆ្លងដោយខុសច្បាប់ ជាពិសេសប្រទេសថៃ ខណៈរាជរដ្ឋាភិបាលថៃបានប្រកាសដាក់ប្រទេសស្ថិតនៅក្នុងគ្រាអាសន្នមួយខែបន្ថែមទៀត។ ការណែនាំបែបនេះ ធ្វើបន្ទាប់ពីពិនិត្យឃើញថា បើទោះបីជាជំងឺកូវីដ-១៩ នៅតែបន្តរាតត្បាតជាសកល ប៉ុន្តែពលករខ្មែរនៅតែព្យាយាមឆ្លងដែនខុសច្បាប់ តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ កើតមានជារៀងរាល់ថ្ងៃ ដោយសារតែកត្តាជីវភាព និងតាមការអូសទាញពីសំណាកមេខ្យល់ ដើម្បីចេញទៅធ្វើការងារ ខណៈក្នុងខែកញ្ញាកន្លងទៅនេះ ភាគីថៃ បានចាប់បញ្ជូនត្រឡប់មកវិញ ចំនួន ៣៦លើក ស្មើនឹង ៩៩៥នាក់ ក្នុងនោះស្រី ១៦៩នាក់ និងកុមារ ៦០នាក់។

ថ្លែងនៅក្នុងកិច្ចប្រជុំបូកសរុប លទ្ធផលការងារប្រចាំខែកញ្ញា និងលើកទិសដៅការងារបន្តខែតុលា ឆ្នាំ ២០២០ របស់អគ្គនាយកដ្ឋានអន្តោប្រវេសន៍ នាព្រឹកថ្ងៃទី ៦ តុលានេះ នៅអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ឯកឧត្តម នាយឧត្តមសេនីយ៍ ក៏បានជំរុញទៅមន្ត្រីនគរបាលអន្តោប្រវេសន៍ទាំងអស់ ត្រូវមានស្មារតីទទួលខុសត្រូវខ្ពស់ មានវិន័យ សេចក្តីថ្លៃថ្នូរ ចេះគោរព និងឲ្យតម្លៃគ្នាទៅវិញទៅមក ដើម្បីប្រយោជន៍ជាតិ និងប្រជាជន និងជៀសវាងដាច់ខាតនូវការប្រើប្រាស់មុខងារ និងសិទ្ធិអំណាចរបស់ខ្លួន ដើម្បីប្រព្រឹត្តអំពើមិនគប្បី ការប្រព្រឹត្តអំពើពុករលួយ ការប្រកាន់បក្ខពួក និងត្រូវប្រកាន់ខ្ជាប់នូវគុណសម្បត្តិ ៤យ៉ាង គឺ ឆន្ទៈម្ចាស់ការ មនសិការវិជ្ជាជីវៈ ភក្តីភាព និងវប្បធម៌សេវាសាធារណៈ៕**ដោយ : បញ្ញាស័ក្តិ**

## ១ថ្ងៃពលករខ្មែរតាមច្រកអូរបើជាន់ជិត300នាក់ តម្រូវឱ្យធ្វើចត្តាឡីស័ក

https://kohsantepheapdaily.com.kh/ ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០២០ ម៉ោង ២០:២៥ ប៊ុន ធឿន

ខេត្តបន្ទាយមានជ័យ ៖ ពលករខ្មែរដែលអាជ្ញាធរថៃចាប់បញ្ជូនមកវិញតាមច្រកអូរបើជាន់ជិត៣០០នាក់ នៅថ្ងៃទី៥ ខែតុលា ឆ្នាំ២០២០ ត្រូវបានតម្រូវឲ្យធ្វើចត្តាឡីស័ក ។ លោក លី សុវណ្ណារិទ្ធ អភិបាលស្រុកអូរជ្រៅបានឲ្យដឹងថា ពលករខ្មែរដែលអាជ្ញាធរថៃចាប់បញ្ជូនតាមច្រកអូរបើជាន់ ស្រុកអូរជ្រៅ ចាប់ពីម៉ោង៤រសៀល ថ្ងៃទី៤ ខែតុលា ដល់ម៉ោង៤រសៀល ថ្ងៃទី៥ ខែតុលា ឆ្នាំ២០២០ មានចំនួន២៩៣នាក់ ក្នុងនោះស្រី១៣៣នាក់ ។ លោកអភិបាលស្រុកបញ្ជាក់ថា ក្រោយពេលរាជរដ្ឋាភិបាលថៃបិទច្រកទ្វារព្រំដែនកម្ពុជា-ថៃ ដើម្បីបង្ការទប់ស្កាត់ជំងឺកូវីដ-១៩ ពលករខ្មែរដែលភាគីថៃចាប់បញ្ជូនមកវិញតាមច្រកអូរបើជាន់ ឃុំអូរបើជាន់ ស្រុកអូរជ្រៅ មកដល់ថ្ងៃទី៥ ខែតុលា ឆ្នាំ២០២០ មានចំនួនសរុប៤១.២៦៩នាក់ ក្នុងនោះស្រី១៨.៦៨៦នាក់ ។

ប្រជាពលរដ្ឋទាំងនោះភាគច្រើនមកពី ខេត្តបន្ទាយមានជ័យ១៦.២០៣នាក់(ស្រី៧.៧២៦នាក់) ខេត្តបាត់ដំបង៧.០៦០នាក់(ស្រី៣.២៦៤នាក់) ខេត្តសៀមរាប៤.៤៣១នាក់(ស្រី១.៩៥៥នាក់) ខេត្តព្រៃវែង២.១៩៨នាក់(ស្រី៩៥៣នាក់) និងខេត្តកំពង់ធំ២.១៧៦នាក់(ស្រី៨៥៤នាក់) ៕

## ថៃបញ្ជូនខ្មែរ ពីរនាក់ អោយមកស្រុកវិញ បន្ទាប់ពីដោះលែងពីពន្ធនាគារ

https://www.rasmeinews.com/ October 6, 2020, 5:53 PM

ដោយៈ បាយ័ន / ឧត្តរមានជ័យៈ ប្រជាពលរដ្ឋខ្មែរ ចំនួនពីរនាក់ ត្រូវបានអាជ្ញាធរថៃ បញ្ជូនមកកាន់ស្រុកកំណើតវិញ បន្ទាប់ពីបានដោះលែង ពីពន្ធនាគារ ពីបទឆ្លងដែនខុសច្បាប់ កាប់ឈើគ្រញូង ក្នុងទឹកដីថៃរួចមក។ ការប្រគល់ និងទទួលប្រជាពលរដ្ឋខ្មែរនេះ បានធ្វើឡើង នៅវេលាម៉ោង ៣និង១៥នាទី រសៀលថ្ងៃទី៦ ខែតុលា ឆ្នាំ២០២០ នេះ ស្ថិតនៅច្រកអន្តរជាតិ ជាំស្រងាំ ក្នុងទឹកដីស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។

សមត្ថកិច្ចនគរបាល ប្រចាំច្រកអន្តរជាតិជាំស្រងាំ បាននិយាយថាៈ ប្រជាពលរដ្ឋខ្មែរទាំង ពីរនាក់ ដែលត្រូវបានអាជ្ញាធរថៃ បានបញ្ជូនមកកាន់ ស្រុកកំណើតវិញនោះ គឺមាន ឈ្មោះ ម៉ន ពិសី ភេទប្រុស អាយុ ២៨ឆ្នាំ រស់នៅភូមិក្បាលស្ពាន ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ហើយត្រូវបានថៃចាប់ខ្លួន នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៦ កន្លងទៅនេះ ដោយចូលតាមច្រកកូនដំរី, និងម្នាក់ទៀតឈ្មោះ ប៊ុន ថាត ភេទប្រុស អាយុ ៣៥ ឆ្នាំ រស់នៅភូមិស្រយ៉ង ឃុំស្រយ៉ង ស្រុកគូលែន ខេត្តព្រះវិហារ ត្រូវបានថៃចាប់ខ្លួនថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៥ កន្លងទៅនេះ ដោយចូលតាមច្រកបឹងត្រកួន ។ ក្រោយពីចាប់ខ្លួន អ្នកទាំងពីរ ត្រូវបានយកទៅដាក់ពន្ធនាគារ នៅខេត្តអំណាចារើន ប្រទេសថៃ ពីបទឆ្លងដែនខុសច្បាប់ កាប់ឈើគ្រញូង ក្នុងទឹកដីថៃ៕ទ/

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៣២នាក់

https://www.facebook.com/GDIOfficial 06-10-2020

នៅថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្ដោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការនិងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៣២នាក់ ស្រី ៥១នាក់៕

## ថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២០

## ឯកអគ្គរដ្ឋទូតអាមេរិក៖ មាតុភូមិនិវត្តន៍របស់ពលរដ្ឋខ្មែរ នៅសហរដ្ឋអមេរិក មកកាន់ កម្ពុជាវិញ ត្រូវបានផ្អាកមួយរយៈ ដោយសារស្ថានភាពនៃជំងឺកូវីដ១៩

https://www.cen.com.kh/ October 8, 2020

ភ្នំពេញ៖ ឯកឧត្តមឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំកម្ពុជា បានជជែកពិភាក្សាផ្លាស់ប្តូរយោបល់ជាមួយសម្តេចកឡាហោម ពាក់ព័ន្ធនឹងការងារជាច្រើន ក្នុងនោះការងារមាតុភូមិនិវត្តន៍របស់ពលរដ្ឋខ្មែរនៅសហរដ្ឋអមេរិកមកកាន់កម្ពុជាវិញ ត្រូវបានផ្អាកមួយរយៈ ដោយសារស្ថានភាពនៃជំងឺកូវីដ១៩។

នៅរសៀល ថ្ងៃទី៧ ខែតុលា ឆ្នាំ២០២០នេះ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអនុញ្ញាតជូនឯកឧត្តម W. Patrick Murphy ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា ព្រមទាំងសហការីចូលជួបពិភាក្សាការងារនៅទីស្តីការក្រសួងមហាផ្ទៃ។ជាកិច្ចចាប់ផ្តើមសម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី បានថ្លែងអំណរគុណឯកឧត្តមឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកចំពោះកិច្ចខិតខំប្រឹងប្រែងក្នុងតួ

នាទីជាឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់សហរដ្ឋអាមេរិកប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ឯកឧត្តមបានចូលរួមពូនជ្រុំធ្វើឱ្យទំនាក់ទំនងប្រទេសទាំងពីរកាន់តែមានភាពប្រសើរឡើង។ សម្តេចក្រឡាហោម បានអរគុណចំពោះរដ្ឋាភិបាលសហរដ្ឋអាមេរិក ដែលបានផ្តល់ជំនួយផ្សេងៗមកកាន់ព្រះរាជាណាចក្រកម្ពុជានៅក្នុងការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងជំងឺកូវីដ១៩ ទោះបីជាសហរដ្ឋអាមេរិកកំពុងតែជួបនូវបញ្ហានេះដែរ។ សម្តេចក៏បានសម្តែងការអបអរសាទរចំពោះលទ្ធផលដ៏ល្អប្រសើរជាច្រើន និងសមិទ្ធផលជាច្រើនដែលកម្លាំងអនុវត្តច្បាប់នៃប្រទេសទាំងពីរខិតខំរួមគ្នាសម្រេចបាន។

ជាការឆ្លើយតប ឯកឧត្តម W. Patrick Murphy ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក បានឯកភាពចំពោះការលើកឡើងរបស់សម្តេច ពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការលើការងារអនុវត្តច្បាប់។ ឯកឧត្តមបានជម្រាបជូនសម្តេចថានៅក្នុងឆ្នាំនេះ ដែលជាខួប៧០ឆ្នាំនៃទំនាក់ទំនងការទូតកម្ពុជា និងអាមេរិក ការងារកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់នេះ ក៏ជាប្រធានបទមួយដែលត្រូវបានដាក់បញ្ចូលសម្រាប់អបអរសាទរខួបនៃចំណងការទូតនេះដែរ។ ឯកឧត្តមឯកអគ្គរដ្ឋទូតក៏បានថ្លែងអំណរគុណប្រទេសកម្ពុជា សម្រាប់ការរួមចំណែកពង្រឹងនូវការអនុវត្តច្បាប់នៅកម្ពុជា ដែលមិនត្រឹមតែរួមចំណែករវាងព្រះរាជាណាចក្រកម្ពុជា និងសហរដ្ឋអាមេរិកប៉ុណ្ណោះទេ ក៏ប៉ុន្តែក៏ជាការរួមចំណែកថែរក្សាសន្តិសុខសាកលផងដែរ។ ឯកឧត្តមក៏បានណែនាំសមាសភាពក្រុមការងារទទួលបន្ទុកផ្នែកអនុវត្តច្បាប់ប្រចាំនៅស្ថានទូតសហរដ្ឋអាមេរិកនៅព្រះរាជាណាចក្រកម្ពុជា ជូនសម្តេច ដោយបានបន្តថាក្រុមការងារឯកឧត្តម នឹងបន្តធ្វើកិច្ចសហការជាមួយសមភាគីកម្ពុជាទៅតាមជំនាញរៀងៗខ្លួន ក្នុងការជំរុញកិច្ចសហប្រតិបត្តិការលើការងារអនុវត្តច្បាប់ឱ្យកាន់តែជិតស្និតថែមទៀត។

នៅក្នុងជំនួបនោះដែរ ឯកឧត្តមក៏បានលើកឡើងនូវការងារធំៗមួយចំនួន ដើម្បីជជែកពិភាក្សាផ្លាស់ប្តូរយោបល់ជាមួយសម្តេចក្រឡាហោម ទីមួយគឺពាក់ព័ន្ធនឹងការងារមាតុភូមិនិវត្តន៍របស់ពលរដ្ឋខ្មែរនៅសហរដ្ឋអាមេរិកមកកាន់ព្រះរាជាណាចក្រកម្ពុជា ដោយចំណុចនេះឯកឧត្តមបានជម្រាបជូនសម្តេចថា ឯកឧត្តមបានយល់ពីស្ថានភាពនៃជំងឺកូវីដ១៩ ដែលធ្វើឱ្យការអនុវត្តការងារមាតុភូមិនិវត្តន៍ត្រូវបានផ្អាកមួយរយៈ ហើយឯកឧត្តមក៏បានស្នើភាគីព្រះរាជាណាចក្រកម្ពុជា និងសម្តេចក្រឡាហោម ពិនិត្យលទ្ធភាពរិះរកវិធីសាស្ត្រក្នុងការបន្តជំរុញអនុវត្តការងារនេះឱ្យមានវឌ្ឍនភាពបន្តទៅមុខទៀតដែរ។

ពាក់ព័ន្ធនឹងបញ្ហានេះ សម្តេចក្រឡាហោម ស ខេង បានជម្រាបជូនឯកឧត្តមវិញថា ជាគោលការណ៍ និងជាឆន្ទៈនយោបាយ គឺព្រះរាជាណាចក្រកម្ពុជាមិនមានអ្វីប្រែប្រួលនោះទេ គឺនៅតែបន្តអនុវត្តនូវអ្វីដែលរដ្ឋាភិបាលប្រទេសទាំងពីរបានឯកភាពព្រមព្រៀងគ្នានារយៈពេលកន្លងមក ដោយសម្តេចបានអះអាងទៀតថា ទោះបីជាមានការខកខានដោយសារកូវីដ១៩ ប៉ុន្តែគោលការណ៍ និងឆន្ទៈនយោបាយមិនមានអ្វីប្រែប្រួលនោះទេ។ សម្តេចក្រឡាហោម ក៏បានឯកភាពជាគោលការណ៍ផ្តល់លទ្ធភាពដល់មន្ត្រីជំនាញនៃប្រទេសទាំងពីរក្នុងការជជែកដើម្បីពិនិត្យលទ្ធភាពរិះរកនូវវិធីសាស្ត្រសមស្រប និងមានប្រសិទ្ធភាពក្នុងការបន្តជំរុញការងារនេះជាបន្តទៀតដែរ។

ដោយឡែកកិច្ចការមួយទៀតដែលឯកឧត្តមឯកអគ្គរដ្ឋទូតអាមេរិកបានលើកឡើង គឺពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការគាំពារកុមារ ។ ឯកឧត្តមបានស្នើសុំក្រសួងមហាផ្ទៃ បន្តកិច្ចសហការការងារនេះឱ្យកាន់តែជិតស្និតបន្ថែមទៀត ជាពិសេសរវាងកម្លាំងអនុវត្តច្បាប់នៃប្រទេសទាំងពីរ ដើម្បីធ្វើឱ្យកាន់តែមានប្រសិទ្ធភាពលើការងារពាក់ព័ន្ធនឹងកិច្ចសហការស្រាវជ្រាវ ស៊ើបអង្កេត ព្រមទាំងការងារពាក់ព័ន្ធមួយចំនួនទៀតដូចជាការងារចុះធ្វើអធិការកិច្ច ការត្រួតពិនិត្យគោលដៅនានា ដើម្បីជួយដល់ជនរងគ្រោះជាដើម។

ជាការឆ្លើយតបចំពោះបញ្ហានេះ សម្តេចក្រឡាហោម ស ខេង បានសម្តែងការគាំទ្រ និងរីករាយក្នុងការបន្តកិច្ចសហការជាមួយគ្នាឱ្យកាន់តែជិតស្និទ្ធ បន្ថែមទៀតដូចដែលបានធ្វើកន្លងមក។ សម្តេចក៏បានជម្រាបជូនដែរថារាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់បញ្ហានេះ ដោយមានយន្តការមួយ គឺគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង

នឹងការជួញដូរមនុស្សដែលជាយន្តការជាតិមួយធ្វើកិច្ចការងារប្រឆាំការជួញដូរមនុស្ស។ សម្តេចក៏សូមគាំទ្រឱ្យមានកិច្ចសហការរវាងកម្លាំងអនុវត្តច្បាប់ នៃប្រទេសទាំងពីរ លើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងកិច្ចគាំពារដល់កុមារ ហើយមិនត្រឹមតែកិច្ចការទាំងពីនេះទេ សម្តេចក៏បានសម្តែងការលើកទឹកចិត្តឱ្យមានកិច្ចសហប្រតិបត្តិការលើការងារសំខាន់ៗមួយចំនួនទៀតពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើភេរវកម្មនិងបទល្មើសឆ្លងដែនផ្សេងៗទៀត។

ឆ្លៀតនៅក្នុងឱកាសនៃជំនួបនោះដែរ សម្តេចក្រឡាហោមក៏បានថ្លែងអំណរគុណ ដែលតាមរយៈកិច្ចសម្របសម្រួលរបស់ស្ថានទូតសហរដ្ឋអាមេរិកប្រចាំនៅព្រះរាជាណាកម្ពុជា ក្រុមការងាររៀបចំសេចក្តីព្រាងច្បាប់ប្រឆាំងបទល្មើសបច្ចេកវិទ្យារបស់ក្រសួងមហាផ្ទៃក៏បានជួបពិភាក្សាតាមប្រព័ន្ធវីដេអូ និងបានទទួលនូវការចូលរួមផ្នែកបច្ចេកទេសពីអ្នកជំនាញច្បាប់នៃក្រសួងយុត្តិធម៌សហរដ្ឋអាមេរិក និងទទួលបានជាតុចូលសំខាន់ៗពីតំណាងក្រុមហ៊ុនបច្ចេកវិទ្យាធំៗរបស់សហរដ្ឋអាមេរិក។ សម្តេចក៏សូមយកឱកាសនេះស្នើដល់ឯកឧត្តមឯកអគ្គរដ្ឋទូតបន្តជួយគាំទ្របច្ចេកទេសដល់កិច្ចការនេះបន្តទៀត។

ពាក់ព័ន្ធនឹងការងារនេះដែរ ឯកឧត្តមឯកអគ្គរដ្ឋទូតក៏បានសម្តែងកោតសរសើរ និងអបអរសាទរចំពោះលទ្ធផលនៃជំនួបពិភាក្សាការងាររវាងភាគីព្រះរាជាណាចក្រកម្ពុជា គឺក្រុមការងាររៀបចំសេចក្តីព្រាងច្បាប់ជាមួយនឹងអ្នកជំនាញសហរដ្ឋអាមេរិក រួមទាំងក្រុមហ៊ុនបច្ចេកវិទ្យាធំៗរបស់អាមេរិក។ ឯកឧត្តមបានបង្ហាញការលើកទឹកចិត្ត នឹងគាំទ្រកិច្ចការងារនេះទៀត។ នៅក្នុងឱកាសនោះដែរ ឯកឧត្តមឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកក៏បានសម្តែងនូវបំណងលើការងារកិច្ចសហប្រតិបត្តិការពាក់ព័ន្ធមួយចំនួនទៀត ដែលស្ថិតនៅក្នុងក្របខ័ណ្ឌនៃការងារអនុវត្តច្បាប់ ហើយសម្តេចក្រឡាហោម ក៏បានថ្លែងអំណរគុណចំពោះគោលបំណងដ៏ល្អនេះ និងបានជម្រាបជូនវិញថាភាគីព្រះរាជាណាចក្រកម្ពុជា ជាពិសេសក្រសួងមហាផ្ទៃ នឹងបន្តខិតខំអនុវត្តនូវអ្វីដែលភាគីទាំងពីរបានព្រមព្រៀងគ្នាកន្លងមកនៅក្នុងកិច្ចសហប្រតិបត្តិការទ្វេភាគីជាមួយសហរដ្ឋអាមេរិក៕ **ដោយៈកូឡាប**

## ថៃស្នើឲ្យកម្ពុជា ពន្លឿនការបញ្ជូនពលករ ១ពាន់នាក់ ទៅធ្វើការនៅប្រទេសថៃ

http://btv.com.kh/ 06/10/2020

ភ្នំពេញៈ ឯកឧត្តម អ៊ុក សោភ័ណ ឯកអគ្គរាជទូតកម្ពុជាប្រចាំទីក្រុងបាងកក ប្រទេសថៃ បានឲ្យដឹងថា ថៃស្នើឲ្យកម្ពុជាពន្លឿនការបញ្ជូនពលករ១ពាន់នាក់ ទៅធ្វើការនៅប្រទេសថៃ ក្នុងនោះភាគីនឹងទទួលបន្ទុកលើការចំណាយធ្វើចត្តាឡីស័ក រួមទាំងផ្តល់ការតាមដានសុខភាពជាប្រចាំជូនពលករ។ ថ្លែងក្នុងសម្ភាសន៍ជាមួយ BTV នៅថ្ងៃទី៦ ខែតុលា ឆ្នាំ២០២០នេះ ឯកឧត្តម អ៊ុក សោភ័ណ ឯកអគ្គរាជទូតកម្ពុជា ប្រចាំទីក្រុងបាងកក បានមានប្រសាសន៍ថា កាលពីពេលកន្លងទៅ ក្នុងជំនួបពិភាក្សារវាងអាជ្ញាខេត្តបាត់ដំបង និងខេត្តចាន់ថាក់បុរី ភាគីថៃ បានស្នើឲ្យកម្ពុជាបញ្ជូនពលករចំនួន៥០០នាក់ ដើម្បីទៅបន្តការងារនៅប្រទេសពាក់ព័ន្ធនឹងវិស័យកសិកម្ម ប៉ុន្តែទន្ទឹមនឹងការស្នើពីភាគីថៃ កម្ពុជាបានសម្រេចបន្ថែមចំនួនពលករដែលនឹងត្រូវនៅធ្វើការប្រទេសថៃចំនួន១ពាន់នាក់ ខណៈភាគីថៃ និងសមាគមអ្នកវិនិយោគចម្ការមៀនថៃឯកភាពនឹងចំណាយការធ្វើចត្តាឡីស័កជូនបងប្អូនពលករ។

ឯកឧត្តម អ៊ុក សោភ័ណ បានគូសបញ្ជាក់ទៀតថា ដើម្បីចូលរួមទប់ស្កាត់ការឆ្លងរាតត្បាតនៃជំងឺកូវីដ១៩ ភាគីកម្ពុជា-ថៃនឹងសម្របសម្រួលការចេញចូល និងអនុវត្តយ៉ាងតឹងរឹងចំពោះវិធានសុខាភិបាល ដូចជាការពិនិត្យសុខភាពជាប្រចាំពីអាជ្ញាធរថៃផងដែរ។ ដោយឡែក អំឡុងកិច្ចប្រជុំរវាងឯកឧត្តម អ៊ុក សោភ័ណ ឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសថៃ ជាមួយឯកឧត្តម សុឆាត ឈុំគ្លិន រដ្ឋមន្ត្រីក្រសួងការងារថៃ កាលពីដើមខែតុលានេះ ភាគីថៃបានឯកភាពជួយសម្រួលដល់ពលករកម្ពុជាដែលបានដំណើរការចូលមកធ្វើការក្នុងប្រទេសថៃតាមប្រព័ន្ធ MoU ដើម្បីអាចធ្វើការបានដោយបណ្តោះអាសន្ននៅប្រទេសថៃ, បញ្ចុះតម្លៃទិដ្ឋាការស្នាក់នៅ ពី១, ៩០០បាត ក្នុង១ឆ្នាំ ទៅតម្លៃ ៥០០បាត សម្រាប់រយៈពេល២ឆ្នាំ ដល់ពលករខ្មែរ, សម្រួលបើកឱ្យនាំចូលពលករបរទេសចូលមកធ្វើការក្នុង

ប្រទេសថៃតាមប្រព័ន្ធ MOU ដោយបន្ធូរបន្ថយការចំណាយលើថ្លៃចត្តាឡីស័កចំនួន ១៤ថ្ងៃផងដែរ៕ អត្ថបទ៖ សេក ឧត្តម

## ប្រទេសហ្វាំងឡង់ គ្រោងបើកស្ថានកុងស៊ុលកិត្តិយសនៅកម្ពុជា និងត្រូវការពលករបេះផ្លែឈើតាមរដូវកាល

https://www.cen.com.kh/ October 7, 2020

បាងកក ៖ រដ្ឋាភិបាលហ្វាំងឡង់ គ្រោងបើកស្ថានកុងស៊ុលកិត្តិយសនៅកម្ពុជា ដើម្បីពង្រឹងទំនាក់ទំនងការទូត និងពង្រីកកិច្ចសហការសេដ្ឋកិច្ចជាមួយប្រទេសកម្ពុជា ឱ្យកាន់តែប្រសើរថែមទៀត ក្នុងនោះក៏មានត្រូវការពលករបេះផ្លែឈើតាមរដូវកាលផងដែរ នេះបើតាមការបញ្ជាក់របស់ ឯកឧត្តម Jyri Järviaho ឯកអគ្គរដ្ឋទូតហ្វាំងឡង់ថ្មីប្រចាំព្រះរាជាណាចក្រកម្ពុជា និងថៃឡង់ដ៏។ នេះបើតាមការផ្សាយព័ត៌មានរបស់ Royal Embassy of Cambodia in Bangkok នៅថ្ងៃទី៧ខែតុលាឆ្នាំ២០២០។

នៅក្នុងជំនួបជាមួយ ឯកឧត្តម អ៊ុក សោភ័ណ ឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសថៃ កាលពីព្រឹកថ្ងៃពុធ ទី ៧ ខែតុលា ឆ្នាំ២០២០ ឧត្តមមន្ត្រីការទូតហ្វាំងឡង់រូបនេះ ក៏បានបង្ហើបពីគម្រោងផ្តល់ជំនួយបច្ចេកទេស និងសម្ភារដល់កម្ពុជា ដើម្បីកសាងសមត្ថភាពគ្រូបង្រៀនតាមប្រព័ន្ធអនឡាញ និងគម្រោងកែច្នៃសំរាមទៅជាថាមពលអគ្គិសនី (Waste Energy)។

ជាការឆ្លើយតប ឯកឧត្តម អ៊ុក សោភ័ណ បានសម្តែងការស្វាគមន៍ចំពោះគម្រោងខាងលើ និងបានលើកឡើងពីទំនាក់ទំនងទ្វេភាគី និងកិច្ចសហប្រតិបត្តិការល្អរវាងកម្ពុជា និងហ្វាំងឡង់។ ឯកឧត្តមឯកអគ្គរាជទូត បានសន្យាផ្តល់គាំទ្រអស់ពីលទ្ធភាព និងស្នើសុំសមភាគីហ្វាំងឡង់ ជំរុញគម្រោងខាងលើឱ្យបានឆាប់រហ័ស ដើម្បីនាំយកឧត្តមប្រយោជន៍ជូនប្រទេសជាតិ និងប្រជាជន៕**ដោយ៖កូឡាប**

## នគរបាលប៉ុស្តិ៍ជ្រោយបន្ទាយ ស្រុកព្រែកប្រសព្វ ចុះផ្សព្វផ្សាយដល់ប្រជាពលរដ្ឋអំពីគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព

http://cambodiapolice.com/policekh/ 3:27 pm 7 តុលា 2020

ក្រចេះ ៖ នាព្រឹកថ្ងៃទី០៧ ខែតុលា ឆ្នាំ២០២០ កម្លាំងប៉ុស្តិ៍រដ្ឋបាលជ្រោយបន្ទាយ នៃអធិការដ្ឋាននគរបាលស្រុកព្រែកប្រសព្វ បានចុះធ្វើការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋនៅតាមខ្នងផ្ទះ ក្នុងភូមិកោះធំ ឃុំជ្រោយបន្ទាយ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ អំពី ៖

១.ផលអាក្រក់នៃការប៉ះពាល់គ្រឿងញៀន៩ចំណុច

២.ច្បាប់ចរាចរណ៍ផ្លូវគោក(អនុក្រឹតលេខ៣៩ថ្មី អនក្រ.បក)

៣.ល្បែងស៊ីសងខុសច្បាប់

៤.អំពើហិង្សាក្នុងគ្រួសារ

៥.ការជួញដូរផ្លូវភេទស្ត្រីនិងកុមារ

៦.ការគ្រោះថ្នាក់អគ្គីភ័យផ្សេងៗ

៧.ការគ្រោះថ្នាក់នៃអាវុធយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ

៨.មានការណែនាំពួកគាត់ឲ្យចេះថែរក្សានូវទ្រព្យសម្បត្តិដូចជាសត្វគោ ក្របី និងសម្ភារៈផ្សេងៗឲ្យបានត្រឹមត្រូវ ជៀសវាងចោរលួចដើម្បីភូមិ-ឃុំយើងមានសុវត្ថិភាពល្អ និងបានណែនាំពួកគាត់ឲ្យមានអនាម័យល្អ និងស្តាប់ការណែនាំតាមក្រសួងសុខាភិបាលក្នុងការការពារឆ្លងរាលនៃជំងឺCOVID-១៩ ។

យុទ្ធនាការនេះ កម្លាំងប៉ុស្តិ៍ធ្វើបានចំនួន១៣ខ្នងផ្ទះ ដោយមានប្រជាពលរដ្ឋចូលរួមចំនួន ២៩នាក់ និងចែកខិត្តប័ណ្ណ ២៩សន្លឹក ៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៩៣នាក់

https://www.facebook.com/GDIOfficial 07-10-2020

នៅថ្ងៃទី០៧ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការនិងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៩៣នាក់ ស្រី ៣៤នាក់៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរចំនួន ០៤នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងករណីឆ្លងដែនខុសច្បាប់

https://www.facebook.com/GDIOfficial 07-10-2020

នៅថ្ងៃទី០៧ ខែតុលា ឆ្នាំ២០២០ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរចំនួន ០៤នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងករណីឆ្លងដែនខុសច្បាប់។ នគរបាលប៉ុស្តិ៍បានឲ្យដឹងថា ពលករខ្មែរទាំង ០៤នាក់នេះ មាន ១-ឈ្មោះ ប៊ិច ចិត្ត ភេទប្រុស អាយុ ២៩ឆ្នាំ ភូមិស្រែរៀង ឃុំស្វាយជ្រុំ ស្រុកមេសាង ខេត្តព្រៃវែង, ២-ឈ្មោះ មួង ចេក ភេទប្រុស អាយុ ២៣ឆ្នាំ ភូមិ៤ សង្កាត់ដងទង់ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង, ៣-ឈ្មោះ តោ ទួន ភេទប្រុស អាយុ ២៩ឆ្នាំ ភូមិអូរតាទែក ឃុំតាតោក ស្រុកសំឡូត ខេត្តបាត់ដំបង, ៤-ឈ្មោះ សំ ភ័ក្ត្រា ភេទប្រុស អាយុ ២៧ឆ្នាំ ភូមិខ្សាច់ពយ ឃុំវត្តកោ ស្រុកបាត់ដំបង ខេត្តបាត់ដំបង និងបានធ្វើការសាកសួរ អប់រំណែនាំ ដោយមានការចូលរួមត្រួតពិនិត្យសុខភាពពីមន្ត្រីចត្តាឡីស័កប្រចាំមាត់ច្រក នូវវិធានការរបស់ក្រសួងសុខាភិបាលផងដែរ។ ដោយឡែកខាងភាគីថៃ នៅតែបន្តបិទច្រកមិនឲ្យអ្នកដំណើរ ចេញ-ចូល ចំណែកទំនិញទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តចំនួន ០២នាក់ ដែលទទួលបានការអនុញ្ញាត និងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានយ៉ាងត្រឹមត្រូវ៕

## ថៃ អនុញ្ញាតបន្តរយៈពេលសម្រាប់ពលករចំណាកស្រុកដែលធ្វើការនៅក្នុងប្រទេសរបស់ខ្លួន

https://business.khmernote.com.kh/ October 8, 2020 Nita

ប្រទេសថៃ កំពុងពិចារណាអនុញ្ញាតឱ្យពលករចំណាកស្រុក ដែលការងាររបស់ពួកគេផុតកំណត់ចាប់ផ្តើមនៅខែក្រោយ ដើម្បីបន្តស្ថិតនៅក្នុងប្រទេស ជំនួសឱ្យការវិលត្រឡប់ទៅកាន់ប្រទេសកំណើតរបស់ពួកគេវិញ ដើម្បីដាក់ពាក្យសុំការងារពីទីនោះ។ សេចក្តីសម្រេចអនុញ្ញាតឱ្យមានរយៈពេលអនុគ្រោះ ដោយគណៈកម្មាធិការគ្រប់គ្រងគោលនយោបាយរបស់ពលករចំណាកស្រុក ដែលដឹកនាំដោយរដ្ឋមន្ត្រីក្រសួងការងារថៃលោក Suchart Chomklin នៅថ្ងៃទី ៦ ខែតុលា មានគោលបំណងទប់ស្កាត់ការរីករាលដាលនៃជំងឺ Covid-19 ។ រដ្ឋមន្ត្រីរូបនេះ ត្រូវបានសារព័ត៌មានក្នុងស្រុកថៃដកស្រង់សម្តីថា ប្រសិនបើពលករចំណាកស្រុកវិលត្រឡប់ទៅប្រទេសកំណើតវិញ

បន្ទាប់ពីបានធ្វើការនៅប្រទេសថៃអស់រយៈពេល៤ឆ្នាំតាមតម្រូវការនៃអនុស្សរណៈនៃការយោគយល់រវាងរដ្ឋាភិបាល និងប្រទេសនីមួយៗ ពួកគេប្រហែលជាចង់ត្រឡប់មកធ្វើការវិញ។ ដោយនេះធ្វើឱ្យមានការព្រួយបារម្ភអំពីពួកគេក្នុងការឆ្លងជំងឺ Covid-19 ខណៈពេលរង់ចាំត្រឡប់មកវិញ ហើយយកជំងឺរាតត្បាតនេះមកជាមួយនៅពេលពួកគេត្រឡប់មកវិញ។ លោកបានបន្ថែមថា មានហានិភ័យពិតប្រាកដនៃការឆ្លងជំងឺ Covid-19 នាំចូលដែលបង្កជារលកផ្ទុះលើកទី២ ។ ទោះបីជា លោក Suchart មិនបាននិយាយថា រយៈពេលនៃការអនុគ្រោះនឹងមានរយៈពេលប៉ុណ្ណាក៏ដោយ លោកបានបញ្ជាក់យ៉ាងច្បាស់ថា បញ្ហានេះនឹងត្រូវបានស្នើសុំឱ្យគណៈរដ្ឋមន្ត្រីពិចារណាក្នុងពេលវេលាជាក់លាក់មួយ។

ទន្ទឹមនឹងនេះ សិទ្ធិទទួលបានរយៈពេលលើកលែង គឺជាពលករចំណាកស្រុកដែលមានកិច្ចសន្យាការងាររយៈពេល ៤ ឆ្នាំនឹងចាប់ផ្តើមនៅខែក្រោយរហូតដល់ចុងខែធ្នូ ឆ្នាំក្រោយ។ លោកបានបន្ថែមទៀតថា ចំពោះការវិលត្រឡប់សម្រាប់ពលករចំណាកស្រុកទៅប្រទេសរបស់ពួកគេវិញ នឹងដាក់ពាក្យសុំការងារពីទីនោះ ខណៈពេលដែលកំពុងស្ថិតក្រោមវិធានការណ៍ប្រឆាំងនឹងជំងឺ Covid-19 ផងដែរ រួមទាំងការដាច់រយៈពេល ១៤ ថ្ងៃដោយការធ្វើបែបនេះនឹងធ្វើឱ្យថ្លៃចំណាយច្រើន ដូច្នេះវានឹងមិនអាចដំណើរការបាន និងពិបាកក្នុងការអនុវត្ត។

យោងតាមក្រសួងការងារថៃបានឱ្យដឹងថា ពលករចំណាកស្រុកសរុបចំនួន ១៣១,៥៨៧ នាក់មកពីប្រទេសមីយ៉ាន់ម៉ា ឡាវ និងកម្ពុជាប័ណ្ណការងាររបស់ពួកគេផុតកំណត់នៅចន្លោះខែក្រោយ និងខែធ្នូ ឆ្នាំក្រោយ៕
អត្ថបទ៖ នីតា

## ថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២០

### ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ចំនួន ៤៧នាក់ ពីអាជ្ញាធរ

https://www.facebook.com/GDIOfficial 08-10-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២០ មានពលករខ្មែរឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ៤៧នាក់ ស្រី ១៩នាក់ និងកុមារ ០១នាក់។ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធន់ធំដំណើរការជាធម្មតា៕

### ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៩១នាក់

https://www.facebook.com/GDIOfficial 08-10-2020

នៅថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការនិងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូល

ប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៨១នាក់ ស្រី ៩៧នាក់ និងពលរដ្ឋថៃដែលបានចាកចេញមាន ០១នាក់ ដោយមានឯកសារចេញពីស្ថានទូតថៃ និងលិខិតបញ្ជាក់សុខភាព៕

## ថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០

### ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក ចំនួន ១០នាក់

https://www.facebook.com/GDIOfficial 11-10-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី១១ ខែតុលា ឆ្នាំ២០២០ បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ១០នាក់ ស្រី ០៣នាក់។ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធន់ធំ ដំណើរការជាធម្មតា៕

### ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិភ្នំដី បានធ្វើការឃាត់ខ្លួនប្រជាពលរដ្ឋខ្មែរចំនួន ១២នាក់ ឆ្លងដែនខុសច្បាប់តាមរបៀង (ស្លាបឆ្វេង)

https://www.facebook.com/GDIOfficial 11-10-2020

នៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ១០និង០០នាទី ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិភ្នំដី បានធ្វើការឃាត់ខ្លួនប្រជាពលរដ្ឋខ្មែរចំនួន ១២នាក់ ដែលជាប្រជាពលរដ្ឋរស់នៅក្នុងមូលដ្ឋានស្រុកសំពៅលូន បានធ្វើការឆ្លងដែនតាមរបៀង (ស្លាបឆ្វេង) របស់ប៉ុស្តិ៍ ចេញទៅផ្សារ បានខៅឌីន(ផ្សារជាប់ព្រំដែន) ក្នុងស្រុកខ្លងហាត់ ខេត្តស្រះកែវ ប្រទេសថៃ។ បន្ទាប់មកកម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការអប់រំណែនាំ ដល់ប្រជាពលរដ្ឋទាំងអស់ខាងលើ ក្នុងនោះក៏មានការចូលរួមណែនាំពីលោក ងាវ ប៊ុនយាង អភិបាល នៃគណៈអភិបាលស្រុកសំពៅលូន, លោកអភិបាលរងស្រុក ក៏ដូចជាតំណាង លោកប្រធានស្នាក់ការ ត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិភ្នំដី និងបានឲ្យពួកគាត់ធ្វើកិច្ចសន្យា បញ្ឈប់ការធ្វើសកម្មភាពបែបនេះទៀត៕

### ភាគីថៃបានបញ្ជូនពលរដ្ឋខ្មែរចំនួន ០១នាក់ ឲ្យមកប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ ពីបទឆ្លងដែនខុសច្បាប់

https://www.facebook.com/GDIOfficial 11-10-2020

នៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០២០ ខាងភាគីថៃបានបញ្ជូនពលរដ្ឋខ្មែរចំនួន ០១នាក់ ឲ្យមកប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ ពីបទឆ្លងដែនខុសច្បាប់ ទៅកាប់ឈើនៅប្រទេសថៃ ដែលចេញតាមច្រកទឹកខៀវ ខេត្តព្រះវិហារ៕

### ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៩៩នាក់

https://www.facebook.com/GDIOfficial 11-10-2020

នៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ផង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិន

អនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការនិងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបរយានយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៩៩នាក់ ស្រី ៨៦នាក់ និងពលរដ្ឋថៃដែលបានចាកចេញមានចំនួន ១០នាក់ ស្រី ០១នាក់ ដោយមានឯកសារចេញពីស្ថានទូតថៃ និងលិខិតបញ្ជាក់សុខភាព៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១០៥នាក់

https://www.facebook.com/GDIOfficial 11-10-2020

នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្ដោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការនិងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបរយានយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១០៥នាក់ ស្រី ៣៩នាក់៕

## ភាគីថៃបានបញ្ជូនពលរដ្ឋខ្មែរចំនួន ០១នាក់ ឲ្យមកប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ ពីបទឆ្លងដែនខុសច្បាប់

https://www.facebook.com/GDIOfficial 10-10-2020

នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០២០ ខាងភាគីថៃបានបញ្ជូនពលរដ្ឋខ្មែរចំនួន ០១នាក់ ឲ្យមកប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ ពីបទឆ្លងដែនខុសច្បាប់ ទៅកាប់ឈើនៅប្រទេសថៃ ដែលចេញតាមច្រកចាក់ច្រែង ខេត្តព្រះវិហារ៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរចំនួន ០២នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងករណីឆ្លងដែនខុសច្បាប់

https://www.facebook.com/GDIOfficial 09-10-2020

នៅថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង១៦និង៣០នាទី ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរចំនួន ០២នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងករណីឆ្លងដែនខុសច្បាប់។ នគរបាលប៉ុស្តិ៍បានឲ្យដឹងថា ពលករខ្មែរទាំង ០២នាក់នេះ មាន ១-ឈ្មោះយុង សុយទ្រី ភេទប្រុស អាយុ ៣៥ឆ្នាំ នៅភូមិអូរលាវ ឃុំផ្ទះកណ្ដាល ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម, ២-ឈ្មោះ អ៊ូច ចន្ទ ភេទស្រី អាយុ ៤៥ឆ្នាំ នៅភូមិច្រកល្ពៅ ឃុំទូកមាសខាងកើត ស្រុកបន្ទាយមាស ខេត្តកំពត និងបានធ្វើការសាកសួរ អប់រំណែនាំ ដោយមានការចូលរួមត្រួតពិនិត្យសុខភាព ពីមន្ត្រីចត្តាឡីស័កប្រចាំមាត់ច្រក នូវវិធានការរបស់ក្រសួងសុខាភិបាលផងដែរ។

ដោយឡែកខាងភាគីថៃ នៅតែបន្តបិទច្រកមិនឲ្យអ្នកដំណើរ ចេញ-ចូល ចំណែកទំនិញទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តចំនួន ០២នាក់ ដែលទទួលបានការអនុញ្ញាត និងបានការឆ្លងកាត់ត្រួតពិនិត្យដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានយ៉ាងត្រឹមត្រូវ។

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១២៣នាក់

https://www.facebook.com/GDIOfficial 09-10-2020

នៅថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ធង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្ដោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការនិងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១២៣នាក់ ស្រី ៥៦នាក់ និងពលរដ្ឋថៃដែលបានចាកចេញមាន ០១នាក់ ដោយមានឯកសារចេញពីស្ថានទូតថៃនិងលិខិតបញ្ជាក់សុខភាព។

# ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០

## មន្ត្រីកំពុងស្រាវជ្រាវរកអត្តសញ្ញាណស្ត្រីខ្មែរម្នាក់ នៅប្រទេសចិន ដែលសុំឱ្យនាយករដ្ឋមន្ត្រីជួយ

https://www.postkhmer.com/ សុទ្ធ គឹមសឿន | Publication date 13 October 2020 | 08:00 ICT

**ភ្នំពេញៈ** មន្ត្រីជំនាញនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជននៃអគ្គស្នងការដ្ឋាននគរបាលជាតិបាននិងកំពុងស្រាវជ្រាវរកទីតាំង និងអត្តសញ្ញាណពលការិនីខ្មែរម្នាក់នៅប្រទេសចិន បន្ទាប់ពីនាងអំពាវនាវតាមបណ្ដាញសង្គមហ្វេសប៊ុកឱ្យលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ជួយអន្តរាគមន៍យកនាងត្រឡប់មកកម្ពុជាវិញ ក្រោយពីនាងចាញ់បោកមេខ្យល់ទៅធ្វើការខុសច្បាប់។

លោក ជីវ ផល្លី ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជននៃអគ្គស្នងការដ្ឋាននគរបាលជាតិបានថ្លែងពីម្សិលមិញថា បន្ទាប់ពីទទួលបានព័ត៌មាននេះ មន្ត្រីជំនាញនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជននៃអគ្គស្នងការដ្ឋាននគរបាលជាតិ បាននិងកំពុងបន្តស្រាវជ្រាវរកអត្តសញ្ញាណស្ត្រីរងគ្រោះ ស៊ើបអង្កេតរកសាច់ញាតិនាងនៅកម្ពុជា។ មន្ត្រីជំនាញក៏កំពុងសហការជាមួយមន្ត្រីស្ថានទូតកម្ពុជាប្រចាំនៅប្រទេសចិន ប៉ុន្តែរហូតមកដល់ថ្ងៃទី ១២ ខែតុលា មិនទាន់មានសញ្ញាវិជ្ជមានណាមួយនៅឡើយ។ លោកថា ស្ត្រីជនរងគ្រោះគ្រាន់តែអំពាវនាវឱ្យអាជ្ញាធរជួយអន្តរាគមន៍សង្គ្រោះឱ្យត្រឡប់មកប្រទេសកម្ពុជាវិញ ប៉ុន្តែនាងមិនបានបង្ហាញពីឈ្មោះនាងផ្ទាល់ ឈ្មោះទីតាំងដែលនាងកំពុងស្នាក់អាស្រ័យ ឬឈ្មោះកន្លែងធ្វើការ។ នាងក៏មិនបានបង្ហាញឈ្មោះទីតាំងស្រុកកំណើតនៅប្រទេសកម្ពុជាដែរ។ ដូច្នេះបញ្ហានេះ ធ្វើឱ្យសមត្ថកិច្ចមានការពិបាកក្នុងការស្រាវជ្រាវរកស្ត្រីជនរងគ្រោះ។ លោក ជីវ ផល្លី បញ្ជាក់ថា៖ «យើងបានទាក់ទងទៅគណនីហ្វេសប៊ុកដែលគាត់បានបង្ហោះមកហ្នឹងជារៀងរាល់ថ្ងៃ ប៉ុន្តែគាត់មិនបានឆ្លើយតបមកយើងវិញទេ។ កិច្ចការបន្តទៀត គឺខ្ញុំកំពុងស្នើឱ្យមន្ត្រីជំនាញខាងប្រឆាំងបទល្មើសបច្ចេកវិទ្យា ជួយកំណត់ទីតាំងគាត់ហ្នឹង ប៉ុន្តែមិនមានលទ្ធផលអ្វីទេ ហើយយើងនឹងបន្តសហការជាមួយភាគីចិន ដើម្បីស្រាវជ្រាវបន្តទៀត»។

តាមគណនីហ្វេសប៊ុកមួយឈ្មោះ«វីណា វីណា»បានបង្ហោះវីដេអូកាលពីចុងសប្តាហ៍មុន បង្ហាញពីស្ត្រីខ្មែរម្នាក់លើកដៃសំពះសុំអង្វរឱ្យលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន អន្តរាគមន៍ជួយនាងឱ្យបានត្រឡប់មកប្រទេសកម្ពុជាវិញ។ ស្ត្រីរូបនេះបានអះអាងថា នាងចាញ់បោកមេខ្យល់មកធ្វើការខុសច្បាប់នៅប្រទេសចិនអស់រយៈពេល ២ ឆ្នាំហើយ។ ថៅកែបានធ្វើទារុណកម្មមកលើនាងស្ទើររាល់ថ្ងៃ។ ស្ត្រីរងគ្រោះនិយាយលើគណនីហ្វេសប៊ុកនោះថា៖ «ខ្ញុំចាញ់បោកគេមកដល់ប្រទេសចិនរយៈពេល ២ ឆ្នាំហើយ។ ខ្ញុំវេទនា ខ្ញុំអត់មានទូរស័ព្ទទាក់ទងម៉ែឪខ្ញុំទេ ទើបតែឥឡូវទេ ខ្ញុំសុំទូរស័ព្ទគេបានវិញ ហើយខ្ញុំចង់ទៅស្រុកខ្មែរវិញ។ ខ្ញុំអត់ចង់នៅកន្លែងហ្នឹងទៀតទេ គេធ្វើបាបខ្ញុំឆ្អែតហើយ»។ តាមហ្វេសប៊ុកដដែលនាងបន្ថែមថា៖ «ខ្ញុំសំណូមពរដល់លោកអ៊ំ ហ៊ុន សែន ជួយខ្ញុំផង និងឯកឧត្តមណាក៏ដោយឱ្យតែជួយខ្ញុំបាន។ ខ្ញុំមានជំងឺក្នុងខ្លួន គេអត់យកខ្ញុំទៅពេទ្យទេ គេទុកខ្ញុំចោល ខ្ញុំសង្ឃឹមថា លោកអ៊ំជួយខ្ញុំឱ្យបានទៅស្រុកកំណើតជួបម៉ែឪខ្ញុំវិញ។ យ៉ាងហោចណាស់ខ្ញុំបានជួបម៉ែឪខ្ញុំ ខ្ញុំស្លាប់ទៅក៏បិទភ្នែកជិតដែរ។ បងប្អូនទាំងអស់គ្នាជួយស៊ែរឱ្យលោកអ៊ំ ហ៊ុន សែន បានឃើញជួយខ្ញុំផង»។

លោកស្រី ខែក កែមាលីស៊ីសូដា ឯកអគ្គរាជទូតកម្ពុជាប្រចាំនៅប្រទេសចិន ពីម្សិលមិញមិនទាន់អាចស្វែងរកប្រភពទាក់ទងសុំការបញ្ជាក់ជុំវិញករណីនេះបានទេ។

លោក មឿន តុលា នាយកប្រតិបត្តិអង្គការសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្សថ្លែងពីម្សិលមិញថា ករណីនេះមិនមែនជាលើកទី ១ ទេពោលគឺមានច្រើនករណីរួចមកហើយ។ ប៉ុន្តែអាជ្ញាធរក៏ធ្លាប់បានជួយសង្គ្រោះពួកគាត់ឱ្យមកជួបជុំគ្រួសារវិញដែរ។ លោកជំរុញឱ្យអាជ្ញាធរកម្ពុជាសហការជាមួយអាជ្ញាធរចិនជួយសង្គ្រោះនាងឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ព្រោះនាងកំពុងតែមានបញ្ហាសុខភាព។ កន្លងមកអាជ្ញាធរ និងសង្គមស៊ីវិលធ្លាប់បានផ្សព្វផ្សាយ អប់រំ និងណែនាំបង្ហាញពីកលល្បិចរបស់ជនខិលខូចមួយចំនួនដែលនាំពលករខុសច្បាប់ទៅធ្វើការនៅបរទេស ប៉ុន្តែបញ្ហានេះថមថយតិចតួច ពោលគឺនៅតែបន្តកើតមានឡើង។ លោកបញ្ជាក់ថា៖ «ខ្ញុំសូមអំពាវនាវកុំចាត់ទុកពួកគាត់ជាពលករខុសច្បាប់ គឺយើងត្រូវតែចាត់ទុកគាត់ជនរងគ្រោះដែលត្រូវបានគេជួញដូរកម្លាំងពលកម្មពួកគាត់ ហើយត្រូវតែជួយសង្គ្រោះពួកគាត់ជាបន្ទាន់។ ខ្ញុំសង្កេតឃើញបទល្មើសមួយរយៈចុងក្រោយនេះ គឺជនល្មើសបាននាំជនរងគ្រោះចូលទៅតាមប្រទេសវៀតណាម ហើយនាំពីវៀតណាមទៅកាន់ចិនតែម្តង។ ដូច្នេះអាជ្ញាធរទាំង ៣ ប្រទេសត្រូវតែពង្រឹងច្បាប់ជួញដូរមនុស្សបន្ថែមទៀត»៕

## បញ្ជូនខ្លួនថៅកែស្រីម្នាក់ ដែលប្រើអំពើហិង្សាលើកូនឈ្នួលជាអនីតិជន ទៅសាលាដំបូងខេត្តកណ្តាល

http://www.freshnewsasia.com/ 2020-10-12 05:35pm

**(កណ្តាល)៖** កម្លាំងការិយាល័យប្រឆាំងការជួញដូរ និងការពារអនីតិជននៃស្នងការដ្ឋាននគរបាលខេត្តកណ្តាល នៅរសៀលថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០នេះ បានបញ្ជូនស្ត្រីម្នាក់ជាថៅកែ ដែលប្រើហិង្សាមកលើកូនឈ្នួលរបស់ខ្លួនដូចសត្វធាតុ មកកាន់សាលាដំបូងខេត្តកណ្តាល ដើម្បីចាត់ការតាមនីតិវិធីច្បាប់។ បើតាមប្រភពសុំមិនបញ្ចេញឈ្មោះ បញ្ជាក់ប្រាប់ភ្នាក់ងារព័ត៌មាន Fresh News ប្រចាំខេត្តកណ្តាល នៅរសៀលនេះថា៖ **«ស្ត្រីដែលដល់រូបនេះ តែងតែប្រើអំបើហិង្សាលើកូនឈ្នួលរបស់គាត់ដែលជាអនីតិជនរហូតដល់មានរបួសស្នាមទៀតផង»**។

ជនរងគ្រោះឈ្មោះ ផ ស រ ភេទស្រី អាយុ១៧ឆ្នាំ មានមុខរបរអ្នកបម្រើនៅតាមផ្ទះ និងមានស្រុកកំណើតនៅភូមិអូរអង្គរ ឃុំសាគ្រាម ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ បច្ចុប្បន្នស្នាក់នៅភូមិថ្មី សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល។ ចំណែកជនសង្ស័យឈ្មោះ ដាំង រស្មី ភេទស្រី អាយុ ២៧ឆ្នាំ ជនជាតិខ្មែរ ទីលំនៅភូមិថ្មី សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល មុខរបរមេផ្ទះ។ ប្រភពដដែល បានរៀបរាប់ដំណើររឿងថា កាលពីថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២០ មីងបង្កើតរបស់ជនរងគ្រោះ ឈ្មោះ សុខ ស្រី មុខរបរ កសិករ មានទីលំនៅភូមិឃុំជាមួយគ្នាបាននាំក្មួយ

ឈ្មោះ ផាត សុរីន មកធ្វើការជាអ្នកបម្រើនៅផ្ទះរបស់ឈ្មោះ ដាំង រស្មី ស្ថិតនៅភូមិថ្មី សង្កាត់ តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល។ ពេលដែលរូបនាងមកធ្វើការជាអ្នកបម្រើនៅផ្ទះថៅកែស្រី ឈ្មោះ ដាំង រស្មី តែងតែប្រើអំពើឃោរឃៅវាយដំមកលើរូបនាងរហូត គឺយកវែកសម្លរ វាយក្បាល វាយមុខ បណ្ដាលឱ្យបែកហូរឈាម ពេលខ្លះទៀតយកកាំបិតប៉ុងតោ វាយក្បាល និងដាច់មុខបណ្ដាលឱ្យបែកហូរឈាមជាច្រើនលើកច្រើនសារ ហើយមិនបាននាំនាងទៅពេទ្យ ឬទិញថ្នាំឱ្យនាងលេបទេ ហើយឱ្យនាងធ្វើការងារផ្ទះទោះបីជានាងឈឺក៏ដោយ។ ប្រភពបន្តថា នៅថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០២០ ថៅកែស្រីបានប្រើឱ្យយកកូនចានបបរ ស្លាបព្រា និងកែវមកឱ្យតែយកមកមិនទាន់ចិត្ត ត្រូវបានថៅកែស្រីយកវែកសម្លរវាយបែកចិញ្ចើមខាងស្ដាំបែកហូរឈាម ភ្លាមពេលនោះនាងបានដើរចូលទៅក្នុងបន្ទប់យកអាវមកទប់ឈាមកុំឱ្យហូរ។

បើតាមប្រភពព័ត៌មានដដែល ក៏បានបញ្ជាក់ឱ្យដឹងថា៖ «**កាលថ្ងៃទី៩ ខែតុលា ឆ្នាំ២០២០ កូនថៅកែរូបនេះបានប្រើឱ្យនាងជាជនរងគ្រោះអាំងត្រី និងមើលសម្លរដែលថៅកែស្រីរបស់នាងឱ្យមើល ដោយសារតែនាងអាំងត្រីមិនឆ្អិនល្អ ថៅកែស្រីរបស់នាង បានយកវែកវាយចំចិញ្ចើមមុខខាងឆ្វេងបណ្ដាលឱ្យបែកហូរឈាម ចំពីលើស្នាមកាំបិតចាស់ដែលថៅកែនាងធ្លាប់វាយ ហើយពេលនោះដែរ ថៅកែស្រីនាងបានប្រើឱ្យនាងមកទិញទឹកត្រីនាងមានឱកាសក៏បានរត់ចេញហើយហៅម៉ូតូឌុប ដើម្បីរកអ្នកជួយដល់រូបនេះ**»។ ក្រោយទទួលបានព័ត៌មាន កម្លាំងជំនាញសហការណ៍ជាមួយនគរបាលក្រុងតាខ្មៅ តាមបញ្ជាស្នងការ ព្រមទាំងបានសហការណ៍ជាមួយលោកស្រី ប្រធានមន្ទីរកិច្ចការនារីខេត្ត និងការិយាល័យ សង្គមកិច្ច ក្រុង និង មន្ត្រីជំនាញមន្ទីរសង្គមកិច្ចបានចុះទៅជួបជនរងគ្រោះ និងបាននាំនាងដាក់ពាក្យបណ្ដឹងព្រមទាំងនាំនាងមកកាន់មន្ទីរពេទ្យបង្អែកជ័យជំនះខេត្តកណ្ដាល ធ្វើការសម្ភាសន៍សាកសួរជនរងគ្រោះហើយបាននាំជនរងគ្រោះទៅពិនិត្យរបួសស្នាមលើរាងកាយ និងការពិនិត្យផ្លូវភេទ៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្ដរមានជ័យ មានចំនួន ១១៧នាក់

https://www.facebook.com/GDIOfficial 12-10-2020

ថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិឆុង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្ដរមានជ័យ ជាបណ្ដោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្ដរមានជ័យ មានចំនួន ១១៧នាក់ ស្រី ៥៧នាក់ និងពលរដ្ឋថៃដែលបានចាកចេញមាន ០២នាក់ ដោយមានឯកសារចេញពីស្ថានទូតថៃ និងលិខិតបញ្ជាក់សុខភាព៕

## អង្គការសង់ត្រាល់បានរៀបចំវេទិការសហគមន៍ស្ដីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាពនៅទីតាំងចំនួន២កន្លែង

https://www.facebook.com/CentralCambodiaOrg/ 12-10-2020

នៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០២០នេះ អង្គការសង់ត្រាល់បានរៀបចំវេទិការសហគមន៍ស្ដីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាពនៅទីតាំងចំនួន២កន្លែង ១/ភូមិជន្លាស់ដៃ ឃុំគោកកបិន ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ២/ភូមិតាសៀវ ឃុំគោកកបិន ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ក្នុងនោះមានអ្នកចូលរួមចំនួន១០៣នាក់ ស្រ្តី ៥១នាក់ និងវត្តមានអាជ្ញាធរមូលដ្ឋានភូមិ ឃុំ ស្រុកចូលរួមក្នុងកម្មវិធីនេះផងដែរ។

កម្មវិធីនេះរៀបចំឡើងក្នុងគោលបំណងដើម្បី៖

- លើកកម្ពស់ការយល់ដឹងដល់ប្រជាពលរដ្ឋ ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ជៀសវាងចាញ់បោកមេខ្យល់ដែលជាកម្មវត្ថុក្នុងការជួញដូរមនុស្ស និងការរំលោភបំពានសិទ្ធការងារគ្រប់រូបភាព។
- កាត់បន្ថយការធ្វើចំណាកស្រុកដោយគ្មានឯកសារជាហេតុប្រឈមនិងគ្រោះថ្នាក់នៃអំពើជួញដូរ និងរំលោភបំពានសិទ្ធមនុស្សផ្សេងៗ។
- លើកកម្ពស់ការចូលរួមពីប្រជាពលរដ្ឋ និងពង្រឹងពង្រីកសហការណ៍ជាមួយអាជ្ញាធរមូលដ្ឋានក្នុងការទប់ស្កាត់ការជួញដូរមនុស្សគ្រប់ប្រភេទ។

## ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២០

## ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បើកកិច្ចប្រជុំពិនិត្យលើសេចក្តីព្រាងផែនការសកម្មភាព ឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ តាមប្រព័ន្ធអ៊ីនធឺណេត

http://www.freshnewsasia.com/ 2020-10-13 05:20pm

**(កំពត)៖** អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ សហការជាមួយអង្គការ Terre des hommes និងអង្គការ APLE បានរៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសអន្តរក្រសួង ដើម្បីពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងផែនការសកម្មភាព ឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទ លើកុមារតាមប្រព័ន្ធអ៊ីនធឺណេតនៅកម្ពុជា។ កិច្ចប្រជុំនេះ ធ្វើឡើងនៅថ្ងៃទី១៣-១៤ ខែតុលា ឆ្នាំ២០២០ នៅមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តកំពត ក្រោមអធិបតីភាព លោកស្រី ញៀប សុភាព អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ដោយមានការចូលរួមពីសំណាក់លោក លោកស្រី ដែលជាក្រុមការងារបច្ចេកទេស គណៈកម្មការការពារកុមារថ្នាក់ជាតិ និងមន្ត្រី ក.ជ.ក។ ក្នុងគោលបំណងនៃកិច្ចប្រជុំនេះ ទី១៖ ស្នើសុំពិនិត្យ និងផ្តល់ធាតុចូលលើសេចក្តីព្រាងផែនការសកម្មភាព ឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ តាមប្រព័ន្ធអ៊ីនធឺណេត នៅកម្ពុជា និងទី២៖ ស្នើសុំការសម្រេច និងផ្តល់ការឯកភាពលើ សេចក្តីព្រាងផែនការសកម្មភាពឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទ លើកុមារតាមប្រព័ន្ធអ៊ីនធឺណេតនៅកម្ពុជា៕

## ជួយសង្គ្រោះបានហើយ ពលការិនី ដែលយំរៀបរាប់និងសុំឲ្យសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ជួយដើម្បីបានវិលត្រឡប់ ពីប្រទេសចិន មកកម្ពុជា

http://www.fridaydailynews.com/ ,14 Oktober 2020 ( Time 08:24 ) ដោយ ៖ លោក រ៉េម សារី

នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ ២០២០ ឯកឧត្តម ឧត្តមសេនីយ៍ឯក ជីវ ផល្លី ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានបញ្ជាក់ឲ្យដឹងថា ពលការិនីម្នាក់ដែលបានធ្វើវីដេអូឃ្លីបបង្ហោះក្នុងបណ្តាញសង្គមហ្វេសប៊ុកថា ខ្លួនត្រូវបានមេខ្យល់ធបោកឲ្យទៅធ្វើការងារនៅឯប្រទេសចិនអស់ជាងពីរឆ្នាំដោយរងទុក្ខលំបាក និងស្នើសុំសម្តេចតេជោ នាយករដ្ឋមន្ត្រី ហ៊ុន សែន ជួយអន្តរាគមន៍ដើម្បីបានវិលត្រឡប់មកប្រទេសកម្ពុជា ជាទឹកដីកំណើតរបស់ខ្លួនវិញនោះ ត្រូវបានស្រាវជ្រាវរកឃើញអត្តសញ្ញាណ និងកន្លែងស្នាក់នៅឯប្រទេសចិននោះហើយ និងត្រូវបានអន្តរាគមន៍រំដោះឲ្យមកស្នាក់នៅបណ្តោះអាសន្ននៅស្ថានអគ្គកុងស៊ុលប្រចាំទីក្រុងសៀងហៃ ដើម្បីរង់ចាំរៀបចំបំពេញបែបបទបញ្ជូនត្រឡប់មកកម្ពុជាវិញនៅចុងខែតុលា ឆ្នាំ២០២០ នេះ។ ឯកឧត្តមបានឲ្យដឹងថា កាលពីថ្ងៃទី៨ ខែតុលា ឆ្នាំ២០២០ នាយកដ្ឋានជំនាញបានទទួលព័ត៌មានពីក្រុមការងារប្រតិកម្មរហ័សនៃអគ្គស្នងការដ្ឋាននគរបាលជាតិស្តីពីព័ត៌មានលើគណនីហ្វេសប៊ុកឈ្មោះ វីណា វីណា ដែលបានបង្ហោះជាឃ្លីបវីដេអូរយៈពេល១នាទី និង៤៩វិនាទី អះអាងថានាងត្រូវចាញ់បោកមេខ្យល់ទៅប្រទេសចិន និងស្នើសុំឲ្យជួយសង្គ្រោះ និងបញ្ជូននាងត្រឡប់មកកម្ពុជាវិញ។

អនុវត្តបទបញ្ជារបស់ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ ឯកឧត្តមឧត្តមសេនីយ៍ឯក ឆាយ គឹមខឿន អគ្គស្នងការរងសេនាធិការ និងមតិចង្អុលដឹកនាំ ពីឯកឧត្តម អគ្គស្នងការរងទទួលផែនយុត្តិធម៌ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានសហការជាមួយនាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា ចាត់មន្ត្រីជំនាញចូលទំនាក់ទំនងក្នុងគណនីហ្វេសប៊ុកឈ្មោះ រីណា រីណា ដោយស្នើសុំផ្តល់ព័ត៌មានអំពីអាសយដ្ឋានដែលនាងកំពុងស្នាក់នៅប្រទេសចិន និងសាច់ញាតិ លេខទូរស័ព្ទទំនាក់ទំនងនៅប្រទេសកម្ពុជា និងដោយទទួលបានកិច្ចសហការល្អបំផុតជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ លេខាធិការដ្ឋានក្រុមការងារសហប្រតិបត្តិការមេគង្គឡានឆាង និងអង្គភាពពាក់ព័ន្ធធ្វើការស្រាវជ្រាវ ទើបដល់ថ្ងៃទី ១២ ខែតុលា ឆ្នាំ២០២០ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិបានផ្តល់ព័ត៌មានមកថា ស្ថានអគ្គកុងស៊ុលនៃព្រះរាជណាចក្រកម្ពុជាប្រចាំទីក្រុងសៀងហៃ បានធ្វើកិច្ចសហការជាមួយសមត្ថកិច្ចចិនជួយសង្គ្រោះម្ចាស់គណនីហ្វេសប៊ុកឈ្មោះ រីណា រីណា បានហើយនៅខេត្តជីជាំង ប្រទេសចិន ដែលមានឈ្មោះពិតគឺ សែម ស្រីពេជ្រ ( SEM SREY PHECH) កើតថ្ងៃទី ១៦/០៥/១៩៩៤ មានស្រុកកំណើតនៅភូមិល្វាត្បូង ឃុំល្វា ស្រុកចំការលើ ខេត្តកំពង់ចាម៕

## សហរដ្ឋអាមេរិកនឹងបើកការិយាល័យ FBI នៅប្រទេសកម្ពុជា

https://khmer.voanews.com/ 13 តុលា 2020

ភ្នំពេញ៖ ទីភ្នាក់ងារស៊ើបអង្កេតសហព័ន្ធ (FBI) របស់សហរដ្ឋអាមេរិកនឹងបើកការិយាល័យរបស់ខ្លួននៅអគ្គស្នងការដ្ឋាននគរបាលជាតិកម្ពុជា ដើម្បីជួយតាមដានរកឧក្រិដ្ឋជនអាមេរិក ស្របពេលដែលសហរដ្ឋអាមេរិកកំពុងស្វះស្វែងស្តារឡើងវិញនូវទំនាក់ទំនងដ៏រកាំរកូសជាមួយប្រទេសកម្ពុជា។ ការិយាល័យនេះនឹងត្រូវប្រើដើម្បីជួយដល់ប៉ូលិសកម្ពុជា ក្នុងកិច្ចប្រឹងប្រែងតាមចាប់ខ្លួនឧក្រិដ្ឋជនអាមេរិកដែលរត់គេចខ្លួន និងដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើភេរវកម្ម។ នេះបើតាមការបញ្ជាក់របស់លោកឧត្តមសេនីយ៍ឯក ឆាយ គឹមឃឿន អ្នកនាំពាក្យនគរបាលជាតិកម្ពុជា នៅថ្ងៃអង្គារនេះ។ លោក ឆាយ គឹមឃឿន បានប្រាប់ទីភ្នាក់ងារព័ត៌មាន Reuters ថា កាលពីមុន នគរបាលជាតិកម្ពុជាបានសហការក្នុងមួយករណីម្តងមួយករណីម្តង ហើយឥឡូវនេះ វត្តមានរបស់ការិយាល័យ [FBI] នេះអាចជួយពន្លឿនការងារ។ លោក ឆាយ គឹមឃឿន បានបន្ថែមថា លោកមិនបានដឹងអំពីពេលវេលាជាក់ស្តែងថាតើពេលណាការិយាល័យនេះនឹងបើកដំណើរការនោះទេ។

នៅក្នុងសេចក្តីថ្លែងការណ៍មួយផ្ញើតាមអ៊ីមែលទៅកាន់ទីភ្នាក់ងារព័ត៌មាន Reuters ស្ថានទូតអាមេរិកប្រចាំទីក្រុងភ្នំពេញ បដិសេធមិនបញ្ជាក់អំពីការិយាល័យ FBI នេះ តែថាស្ថាប័នទាំងពីរបានបង្កើតទំនាក់ទំនងជាមួយគ្នា។ សេចក្តីថ្លែងការណ៍នេះបានឲ្យដឹងថា៖ «ក្រុមការងាររួមរបស់ទីភ្នាក់ងារ FBI និងនគរបាលជាតិកម្ពុជាដែលត្រូវបានបង្កើតឡើង ដើម្បីប្រយុទ្ធប្រឆាំងនឹងបទឧក្រិដ្ឋលើកុមារ ការលាងលុយកខ្វក់ និងឧក្រិដ្ឋកម្មហិរញ្ញវត្ថុ កំពុងដំណើរការនៅពេលបច្ចុប្បន្ននេះ។ កិច្ចសហប្រតិបត្តិការផ្នែកអនុវត្តច្បាប់របស់យើងធ្វើឲ្យប្រទេសយើងទាំងពីរកាន់តែមានសុវត្ថិភាព»។ ស្ថានទូតអាមេរិកប្រចាំទីក្រុងភ្នំពេញបានឲ្យដឹងថា កិច្ចព្រមព្រៀងត្រូវបានធ្វើឡើងកាលពីឆ្នាំមុនដើម្បីបង្កើតក្រុមការងារនេះ ដែលក្រុមការងារនេះក៏នឹងដោះស្រាយបញ្ហាឧក្រិដ្ឋកម្មរៀបចំទុកជាមុន និងដើម្បីតាមរកចាប់ខ្លួនឧក្រិដ្ឋជនអន្តរជាតិផងដែរ៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីអាជ្ញាធរថៃបញ្ជូនមក មានចំនួន ៤៤នាក់

https://www.facebook.com/GDIOfficial 13-10-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០ បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ៤៤នាក់ ស្រី ១១នាក់។ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធន់ធំ ដំណើរការជាធម្មតា៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១១៤នាក់

https://www.facebook.com/GDIOfficial 13-10-2020

នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការនិងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១១៤នាក់ ស្រី ៥៧នាក់៕

# ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២០

## នារីខ្មែរ ដែលចាញ់បោកមេខ្យល់ទៅធ្វើការនៅចិន ត្រូវបានសង្គ្រោះហើយ

https://thmeythmey.com/ 15, Oct 2020 , 8:29 pm

នារីខ្មែរម្នាក់ ដែលនិយាយតាមវីដេអូឃ្លីបថា នាង ត្រូវមេខ្យល់បោកយកទៅធ្វើការនៅចិន ហើយរងការធ្វើបាបនោះ ត្រូវអាជ្ញាធរកម្ពុជា ស្រាវជ្រាវរកឃើញអាសយដ្ឋានរបស់នាង កាលពីថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០ និងបានបញ្ជូនទៅស្នាក់នៅបណ្តោះអាសន្នក្នុងស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំនៅទីក្រុងសៀងហៃ។

លោកឧត្តមសេនីយ៍ឯក ជីវ ផល្លី ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជននៃអគ្គស្នងការដ្ឋាននគរបាលជាតិ ប្រាប់ថា បច្ចុប្បន្ននារីខ្មែររូបនេះកំពុងស្ថិតក្រោមការគាំពារពីសំណាក់ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំនៅទីក្រុងសៀងហៃ។ លោក បន្តថា ស្ថានអគ្គកុងស៊ុល កំពង់រៀបចំបែបបទ ដើម្បីបញ្ជូននាងមកកម្ពុជាវិញ នៅចុងខែតុលា ឆ្នាំ២០២០។ ក្នុងកិច្ចសម្ភាសជាមួយសារព័ត៌មានថ្មីៗ នៅព្រឹកថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០ មន្ត្រីនគរបាលប្រឆាំងនឹងការជួញដូរមនុស្សរូបនេះ មានប្រសាសន៍ថា៖« ដោយសារតែនាងមានបញ្ហាសុខភាពអ៊ីចឹង យើងមិនទាន់សួរនាងទេ។ ពេលនាង មកដល់កម្ពុជាវិញ យើង នឹងសម្ភាសព័ត៌មានពីនាង និងសួររកមេខ្យល់ដើម្បីស្រាវជ្រាវតាមចាប់ យកមកចាត់ការតាមច្បាប់»។

នារីខ្មែររូបនោះ មានស្រុកកំណើត នៅស្រុកចម្ការលើ ខេត្តកំពង់ចាម។ ថ្មីៗនេះ គេ បានឃើញវីដេអូអំពីនាងនៅលើបណ្តាញសង្គម។ នាង និយាយថា នាង ត្រូវបានមេខ្យល់បោកយកទៅធ្វើការនៅចិនអស់រយៈពេលប្រមាណ

ពីរឆ្នាំហើយ ហើយនាង រងការធ្វើបាបនិងជួបការលំបាកជាច្រើន។ នាង រៀបរាប់ថា សូម្បីតែនាងឈឺ ក៏គេ មិនបញ្ជូននាងទៅមន្ទីរពេទ្យដែរ។ នាង បន្តថា នាង គ្មានទាំងទូរស័ព្ទ ដើម្បីទាក់ទងមកគ្រួសារនៅកម្ពុជា រហូតដល់បានពឹងគេ ឲ្យជួយថតវីដេអូ បង្ហោះលើបណ្តាញសង្គម ដើម្បីសុំឲ្យរដ្ឋាភិបាលជួយ។ ក្នុងវីដេអូ នាង និយាយបណ្តើរយំបណ្តើរ ដោយលើកដៃសំពះ ស្នើទៅសម្តេចនាយករដ្ឋមន្ត្រីថា៖«ខ្ញុំ ចង់ទៅស្រុកវិញ។ ខ្ញុំ សំណូមពរលោកអ៊ុំហ៊ុន សែន ជួយខ្ញុំផង លោកឯកឧត្តមណាក៏ដោយ ឲ្យតែលោក ជួយខ្ញុំបាន។...ខ្ញុំ សង្ឃឹមថា លោកអ៊ុំ ជួយខ្ញុំ ឲ្យខ្ញុំទៅស្រុកកំណើតជួបម៉ែឪខ្ញុំវិញ»។ ពេលឃើញវីដេអូអំពីនារីខ្មែររូបនោះ ក្រុមការងារប្រតិកម្មរហ័សនៃអគ្គស្នងការដ្ឋាននគរបាលជាតិ បានបញ្ជូនករណីរបស់នាង ទៅនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ដើម្បីជួយធ្វើអន្តរាគមន៍៕

## រាជរដ្ឋាភិបាល ជួយស្ត្រីខ្មែរម្នាក់នៅខេត្តជីដាំង ឲ្យបានត្រឡប់មកកម្ពុជាវិញ ដោយសារមិនអាចរស់នៅចុះសម្រុងជាមួយប្តីបាន

http://www.freshnewsasia.com/ 2020-10-15 05:53pm

**(ភ្នំពេញ)៖** ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំទីក្រុងសៀងហៃ ប្រទេសចិន បានសហការជាមួយអាជ្ញាធរចិន អន្តរាគមន៍ជួយនារីខ្មែរម្នាក់ឈ្មោះ សែម ស្រីពេជ្រ ស្នាក់នៅខេត្តជីដាំង ប្រទេសចិន ដែលមានបំណងត្រឡប់មកកម្ពុជាវិញ ដោយសារមិនអាចរស់នៅចុះសម្រុងជាមួយប្តីបាន។ នេះបើតាមសេចក្តីប្រកាសរបស់ លោក កុយ គួង អ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២០នេះ ដែលបណ្តាញព័ត៌មាន Fresh News ទទួលបាន។

បើតាមលោក កុយ គួង, រាជរដ្ឋាភិបាលកម្ពុជា តាមរយៈស្ថានអគ្គកុងស៊ុលដដែលនេះ បានចេញលិខិតបើកផ្លូវដល់រូបនាង ហើយប៉ូលីសចិន ក៏បានយល់ព្រមនឹងប្រគល់ទិដ្ឋាការជូន នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០២០ ខាងមុខនេះផងដែរ។បច្ចុប្បន្នអ្នកនាង សែម ស្រីពេជ្រ កំពុងស្នាក់នៅផ្ទះមិត្តភក្តិជាស្ត្រីខ្មែរនៅជិតប៉ុស្តិ៍ប៉ូលីសខេត្តជីដាំង ក្រុងវិនចូវ ដើម្បីរង់ចាំទទួលទិដ្ឋាការ។ តាមសំណើរបស់ស្ថានអគ្គកុងស៊ុល អង្គការសម្ព័ន្ធចាប់ដៃកម្ពុជានៅរាជធានីភ្នំពេញ បានយល់ព្រមជួយចេញសំបុត្រយន្តហោះដល់នាងទៀតផង។ លោក កុយ គួង បានបញ្ជាក់ទៀតថា ស្ថានអគ្គកុងស៊ុល ក៏បានឧបត្ថម្ភថ្លៃហូបចុក ថ្លៃសំបុត្ររថភ្លើង (ពីទីក្រុងវិនចូវ មកសៀងហៃ) ថ្លៃពិនិត្យស្វែងរកមេរោគកូវីដ-១៩ ដែលសរុបជាទឹកប្រាក់ ៥០០ដុល្លារអាមេរិក ជូនដល់នាងផងដែរ៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរចំនួន ០៣នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងករណីឆ្លងដែនខុសច្បាប់

https://www.facebook.com/GDIOfficial 15-10-2020

នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ១៦និង៣០នាទី ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរចំនួន ០៣នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងករណីឆ្លងដែនខុសច្បាប់។ នគរបាលប៉ុស្តិ៍បានឲ្យដឹងថា ពលករខ្មែរទាំង ០៣នាក់នេះ មាន ១-ឈ្មោះ ដែន នីណា ភេទប្រុស អាយុ ២២ឆ្នាំ, ២-ឈ្មោះ ឈឿន ស្រីមុំ ភេទស្រី អាយុ ២៧ឆ្នាំ ភូមិ៣ ឃុំស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង, ៣-ឈ្មោះឡាយ សុផាត ភេទប្រុសអាយុ ៤១ឆ្នាំ ភូមិតាចាក ឃុំទួលគគី ស្រុកមណ្ឌលសីម៉ា ខេត្តកោះកុង និងបានធ្វើការសាកសួរ អប់រំណែនាំ ដោយមានការចូលរួមត្រួតពិនិត្យសុខភាព ពីមន្ត្រីចត្តាឡីស័កប្រចាំមាត់ច្រក នូវវិធានការរបស់ក្រសួងសុខាភិបាលផងដែរ។ ដោយឡែកខាងភាគីថៃ នៅតែបន្តបិទច្រកមិនឲ្យអ្នកដំណើរ ចេញ-ចូល ចំណែកទំនិញទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តចំនួន ០២នាក់ ដែលទទួលបានការអនុញ្ញាត និងបានការឆ្លងកាត់ត្រួតពិនិត្យដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានយ៉ាងត្រឹមត្រូវ៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១០៨នាក់

https://www.facebook.com/GDIOfficial 15-10-2020

នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្ដោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការនិងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១០៨នាក់ ស្រី ៤៥នាក់៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៧១នាក់

https://www.facebook.com/GDIOfficial 14-10-2020

នៅថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្ដោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការនិងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៧១នាក់ ស្រី ២៨នាក់៕

## ភាគីថៃបានបញ្ជូនពលរដ្ឋខ្មែរចំនួន ០៣នាក់ ឲ្យមកប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ ពីបទឆ្លងដែនខុសច្បាប់

https://www.facebook.com/GDIOfficial 14-10-2020

នៅថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២០ ខាងភាគីថៃបានបញ្ជូនពលរដ្ឋខ្មែរចំនួន ០៣នាក់ ឲ្យមកប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ ពីបទឆ្លងដែនខុសច្បាប់ ទៅកាប់ឈើនៅប្រទេសថៃ ដែលចេញតាមច្រកមុំបី ខេត្តព្រះវិហារ៕

## កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិភ្នំដី បានធ្វើការល្បាតតាមរបៀងស្លាបឆ្វេង និងស្លាបស្តាំ ដើម្បីទប់ស្កាត់ប្រជាពលរដ្ឋ កុំឲ្យធ្វើការឆ្លងដែនតាមរបៀង

https://www.facebook.com/GDIOfficial 14-10-2020

នៅថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ០៣និ៥០នាទីទៀបភ្លឺ កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិភ្នំដី បានធ្វើការល្បាតតាមរបៀងស្លាបឆ្វេង និងស្លាបស្តាំ ក្នុងវង្វង់ប្រតិបត្តិការណ៍របស់ប៉ុស្តិ៍ ដើម្បីទប់ស្កាត់ប្រជាពលរដ្ឋ កុំឲ្យធ្វើការឆ្លងដែនតាមរបៀង។ កម្លាំងប៉ុស្តិ៍ក៏បានប្រទះឃើញប្រជាពលរដ្ឋខ្មែរ មួយចំនួនជាប្រជាពលរដ្ឋរស់នៅក្នុងមូលដ្ឋានស្រុកសំពៅលូន ដែលខ្លះជាអ្នកស៊ីឈ្នួលលើកសំភារៈ និងខ្លះទៀតជាអាជីវករ បាន

បម្រុងនឹងធ្វើការឆ្លងដែនចេញទៅផ្សារ បានខៅឌីន (ផ្សារជាប់ព្រំដែន) ស្រុកខ្លងហាត ខេត្តស្រះកែវ ប្រទេសថៃ តាមរបៀង(ស្លាបធ្វេង) របស់ប៉ុស្តិ៍ ។ បន្ទាប់មកកម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការអប់រំណែនាំដល់ប្រជាពលរដ្ឋទាំងអស់ខាងលើ ឲ្យបញ្ឈប់ការធ្វើសកម្មភាពបែបនេះទៀត និងបានអនុញ្ញាតឲ្យពួកគាត់ត្រលប់ទៅផ្ទះវិញរៀងៗខ្លួន៕

## ថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០

## ស្ត្រីខ្មែរម្នាក់ត្រូវបានជួយសង្គ្រោះ ក្នុងករណីរាយការណ៍ថាចាញ់បោកស្វាមីជនជាតិចិន

https://khmer.voanews.com/ 16 តុលា 2020 ស៊ុន ណារិន

ភ្នំពេញ៖ ស្ត្រីខ្មែរម្នាក់ត្រូវបានអាជ្ញាធរកម្ពុជានៅប្រទេសចិនអន្តរាគមន៍ជួយសង្គ្រោះ ក្រោយមានសេចក្តីរាយការណ៍ថា ស្ត្រីនោះរៀបការជាមួយស្វាមីជនជាតិចិន។ បញ្ហាស្ត្រីខ្មែរចាញ់បោកនៅប្រទេសចិន ត្រូវបានមន្ត្រីរដ្ឋាភិបាល និងអ្នកធ្វើការលើផ្នែកសិទ្ធិមនុស្ស ចាត់ទុកថាជាការព្រួយបារម្ភ ហើយចំណាកស្រុករបស់ពួកគេ នៅតែមានភាពប្រថុយប្រថាននៅឡើយ។

នៅក្នុងសេចក្តីប្រកាសព័ត៌មានមួយចេញផ្សាយ កាលពីថ្ងៃព្រហស្បតិ៍ ក្រសួងការបរទេសកម្ពុជាបានឲ្យដឹងថា ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំទីក្រុងសៀងហៃ បានសហការជាមួយអាជ្ញាធរចិន ក្នុងការជួយស្ត្រីខ្មែរម្នាក់ស្នាក់នៅខេត្តជឺជាំង ប្រទេសចិន ហើយដែលមានបំណងត្រឡប់មកកម្ពុជាវិញ ដោយសារ «មិនអាចរស់នៅចុះសម្រុង» ជាមួយស្វាមី។ ក្រសួងការបរទេសកម្ពុជាបញ្ជាក់ថា៖ «បច្ចុប្បន្ននាងកំពុងស្នាក់នៅផ្ទះមិត្តភក្តិជាស្ត្រីខ្មែរនៅជិតប៉ុស្តិ៍ប៉ូលិស ខេត្តជឺជាំង ក្រុងវិនចូវ ដើម្បីរង់ចាំទទួលទិដ្ឋាការ»។

លោក កុយ គួង អ្នកនាំពាក្យក្រសួងការបរទេសកម្ពុជា មានប្រសាសន៍ថា ស្ត្រីរងគ្រោះនឹងទទួលបានទិដ្ឋាការស្នាក់នៅបណ្តោះអាសន្នពីអាជ្ញាធរចិន នៅថ្ងៃនេះ។ លោកបញ្ជាក់ថា៖ «ក្រោយបានទិដ្ឋាការ នាងនឹងជិះរថភ្លើងមកស្នាក់នៅបណ្តោះអាសន្ននៅស្ថានអគ្គកុងស៊ុល នៅសៀងហៃ រង់ចាំជំណើរតាមយន្តហោះមកកាន់រាជធានីភ្នំពេញ នៅថ្ងៃទី ២២ ខែតុលា ឆ្នាំ ២០២០»។ លោក កុង គួង មានប្រសាសន៍ថា អាជ្ញាធរធ្លាប់បានអំពាវនាវកុំឲ្យប្រជាពលរដ្ឋរៀបការដោយប្រថុយប្រថានជាមួយជនជាតិចិន ប៉ុន្តែវានៅតែមានករណីបែបនេះកើតឡើង ដោយសារលោកថា ចាញ់បោកមេខ្យល់។ លោកថ្លែងប្រាប់ VOA ថា៖ «តាមពិត ការអំពាវនាវហ្នឹងយើងអំពាវនាវច្រើនហើយជាច្រើនឆ្នាំមកហើយ។ អំពាវនាវ(ថា) ស្ត្រីយើងចាញ់បោកទៅរៀបការជាមួយបុរសចិន។ យើងតែងតែអំពាវនាវយូរឆ្នាំមកហើយ (អំពាវនាវ)ជាច្រើន ប៉ុន្តែពលរដ្ឋមួយចំនួននៅតែបន្តចាញ់បោកឈ្មួញកណ្តាល»។ លោកបន្តថា នៅពេលមានបញ្ហាកើតឡើងអាជ្ញាធរកម្ពុជានៅក្រៅប្រទេស តែងតែព្យាយាមជួយសង្គ្រោះពួកគេ។

ក្នុងឆ្នាំ ២០១៩ កម្ពុជាបានកត់ត្រាថាស្ត្រីខ្មែរ ១១១ នាក់បានវិលត្រឡប់ពីប្រទេសចិនមកកម្ពុជាវិញ ដោយពួកគេអះអាងថា ត្រូវបានបង្ខំឲ្យរៀបការជាមួយជនជាតិចិន។ នេះបើយោងតាមរដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សលោកស្រី ជូ ប៊ុនអេង។ លោកស្រី ជូ ប៊ុនអេង មានប្រសាសន៍ថា បើទោះជាមានការផ្សព្វផ្សាយ ស្ត្រីខ្មែរនៅតែចាញ់បោកមេខ្យល់ជាបន្តបន្ទាប់។ លោកស្រីបញ្ជាក់ថា៖ «ក្នុងដំណាក់កាលនេះហើយ នៅតែមានអ្នកចាញ់បោក។ ដល់យូរៗទៅ យើងសឹងតែយល់ថា វាលែងជាការចាញ់បោក ដោយសារតែដឹងហើយ ឮហើយ នៅតែឲ្យគេបោកបាន ហើយឥឡូវ វាមានជាបន្តបន្ទាប់អ៊ីចឹងឯង។ ហើយឥឡូវហ្នឹង វាមានជាបន្តបន្ទាប់អ៊ីចឹងឯង»។ លោកស្រីមិនទាន់អាចបញ្ជាក់ចំនួនស្ត្រីដែលត្រូវបានជួយសង្គ្រោះ និងរាយការណ៍ករណីចាញ់បោកនៅប្រទេសចិន សម្រាប់រយៈពេលណាមួយក្នុងឆ្នាំ ២០២០ នេះទេ។

យោងតាមកំណត់ទូតរបស់កម្ពុជា ចុះខែមីនា ឆ្នាំ ២០១១ អាពាហ៍ពិពាហ៍រវាងជនបរទេសនិងពលរដ្ឋខ្មែរត្រូវធ្វើឡើងទៅតាមគោលការណ៍ស្ម័គ្រចិត្ត ដែលចេញពីឆន្ទៈផ្ទាល់របស់សាមីខ្លួនទាំងសងខាងដោយគ្មានការបង្ខំ ឬការបន្លំបោកប្រាស់។ កាលនោះ ក្រសួងការបរទេសបានកំណត់ថា ជនបរទេសដែលរៀបអាពាហ៍ពិពាហ៍អាយុមិន

ត្រូវឲ្យលើសពី ៥០ ឆ្នាំ និងត្រូវមានប្រាក់ចំណូលយ៉ាងតិច ២.៥០០ ដុល្លារក្នុងមួយខែ។ ប៉ុន្តែ ក្នុងខែវិច្ឆិកា ឆ្នាំ ២០១៨ ក្រសួងការបរទេសកម្ពុជាបានដកបម្រាមកំណត់អាយុវិញ គឺថា ជនបរទេសដែលមានអាយុលើស ៥០ ឆ្នាំ ក៏អាចរៀបការជាមួយនារីខ្មែរបានដែរ។

លោកស្រី មាស សាអ៊ីម អនុប្រធានផ្នែកស្ត្រីនិងកុមារនៃសមាគមអាដហុក ដែលធ្វើការលើការជួយពលរដ្ឋខ្មែរ ដែលចាញ់បោកគេនៅបរទេស មានប្រសាសន៍ថា មានស្ត្រីខ្មែរផ្សេងទៀតដែលកំពុងរងគ្រោះនៅក្នុងប្រទេសចិន ដែលពួកគេមិនទាន់មានឱកាសរាយការណ៍ទៅអាជ្ញាធរ ដើម្បីឲ្យជួយសង្គ្រោះ។ លោកស្រីមានប្រសាសន៍ថា៖ «យើងគិតថាករណីហ្នឹងនៅមានច្រើនទៀត ដែលនៅកំពុងកកស្ទះនៅចិន។ ហើយនេះស្ត្រីដែលគាត់សំណាងល្អដែលខាងទូត ហើយនិងអង្គការដៃគូគាត់ ជួយមកបាន។ ហើយនៅមានស្ត្រីមួយចំនួនទៀតដែលគាត់កំពុងតែរង់ចាំដង្ហោយហៅជួយពីអង្គការដៃគូ ក៏ដូចជាស្ថានទូតខ្មែរយើងនៅទីនោះ ដើម្បីឲ្យជួយគាត់ដែរ»។ លោកស្រីបន្ថែមថា ស្ត្រីខ្មែរចាញ់បោកគេក្នុងរូបភាពផ្សេងៗគ្នា ហើយក្នុងនោះក៏មានការសន្យាថាទៅរៀបការជាមួយស្វាមីជនជាតិចិនដែលល្អ។ លោកស្រីបញ្ជាក់ថា៖«ហើយរូបភាពមួយទៀត គឺរូបភាពកុហកឆបោកតែម្ដ ថាទៅធ្វើការនៅទីនោះ មានបានប្រាក់ខែច្រើន ហើយអាចផ្ដល់មកផ្គត់ផ្គង់ក្រុមគ្រួសារអីបានអ៊ីចឹង។ ការងារល្អ បរិយាកាសនៅទីនោះល្អ»។ បើតាមលោកស្រី មេខ្យល់បានលួងលោមស្ត្រីទាំងនោះឲ្យទៅរៀបការ ឬទៅធ្វើការក្នុងប្រទេសចិនដោយប្រើប្រាស់អ្នកជិតខាង ដែលមានសាច់ញាតិរៀបការជាមួយស្វាមីជនជាតិចិន ឬសាច់ញាតិទៅលួងលោមស្ត្រី ដោយសារមេខ្យល់ទាំងនោះ មិនអាចនិយាយផ្ទាល់ជាមួយស្ត្រី។ លោកស្រីបន្ថែមថា៖ «មេខ្យល់ជាអ្នករត់ការឯកសារទាំងអស់ហ្នឹង។ អ៊ីចឹងខ្ញុំគិតថា វាអាចពាក់ព័ន្ធនឹងអាជ្ញាធរដែរ ដែលគាត់រៀបចំឯកសារហ្នឹងជូន ព្រោះចេញទៅមិនមែនចេញទៅទទេ...(មិនមែនអត់ឯកសារ) អាចចេញទៅបានទេ។ ទាល់តែមានលិខិតឆ្លងដែនជាទិដ្ឋាការទេសចរណ៍»។ បើតាមមន្ត្រីអាដហុករូបនោះ គិតពីដើមឆ្នាំរហូតដល់ខែតុលានេះ សមាគមបានទទួលករណីស្ត្រីខ្មែរ ៣ នាក់ត្រឡប់មកពីប្រទេសចិនវិញ។

របាយការណ៍របស់ទីភ្នាក់ងារអង្គការសហប្រជាជាតិឈ្មោះ UN-ACT ដែលផ្សាយកាលពីឆ្នាំ ២០១៦ បានលើកឡើងថា ស្ត្រីខ្មែរទៅប្រទេសចិនដោយសារចាញ់បោកមេខ្យល់ ដែលសន្យាបោកប្រាស់ថា ពួកគេនឹងទទួលបានការងារមានប្រាក់ខែច្រើន។ របាយការណ៍បន្តថាស្ត្រីខ្មែរមួយចំនួនក៏បានយល់ព្រមរៀបការ ប៉ុន្តែពួកគេត្រូវបានប្រាប់ព័ត៌មានខុសដោយថា ពួកគេនឹងមានជីវភាពល្អពេលរៀបការជាមួយស្វាមីចិន ប៉ុន្តែការពិត ពួកគេបានធ្លាក់ជាជនរងគ្រោះវិញ ដោយរៀបការជាមួយបុរសជនជាតិចិន ដែលក្រីក្រនៅតាមជនបទ។ របាយការណ៍ឲ្យដឹងទៀតថា បុរសជនជាតិចិនបានឲ្យប្រាក់ទៅមេខ្យល់ពី ១ ម៉ឺនទៅ ២ ម៉ឺនដុល្លារ ដើម្បីឲ្យទាក់ទងស្ត្រីខ្មែររៀបការជាមួយខ្លួន៕

## ក្រសួងការងារ ប្រកាសឲ្យពលករខ្មែរជំនាញផ្នែកថែទាំ ប្រញាប់ដាក់ពាក្យធ្វើតេស្ត ឆាប់បានទៅធ្វើការនៅជប៉ុន

http://kampucheathmey.com/ 17/10/2020 12:44 Pm

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានប្រកាសឲ្យពលករខ្មែរ ជំនាញផ្នែកថែទាំទាំងអស់ ត្រូវប្រញាប់មកដាក់ពាក្យធ្វើតេស្តជំនាញ និងភាសាជប៉ុន។ ក្នុងនោះដើម្បីឆាប់បានទៅធ្វើការនៅប្រទេសជប៉ុន នាពេលខាងមុខ។ តាមរយៈសេចក្តីជូនដំណឹងរបស់ក្រសួងការងារដែលទទួលបាននៅថ្ងៃនេះ លោកបណ្ឌិត អ៊ិតសំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានឲ្យដឹងថា អង្គភាពទទួលបន្ទុកការធ្វើតេស្តជំនាញ និងតេស្តភាសាជប៉ុន នឹងរៀបចំការធ្វើតេស្តជំនាញ និងភាសាជប៉ុន សម្រាប់ផ្នែកថែទាំចាប់ពីដើមខែវិច្ឆិកា ឆ្នាំ២០២០ ខាងមុខនេះ តទៅ។ លោករដ្ឋមន្ត្រី បានបន្តថា ការធ្វើតេស្តជំនាញ និងភាសាជប៉ុន សម្រាប់ផ្នែកថែទាំនេះ គឺធ្វើចំនួនពីរ

ទីតាំង ដែលទីតាំងទី១ ធ្វើនៅមណ្ឌលសាកលវិទ្យាល័យបែលធី សាខាទួលស្លែង ចាប់ពីថ្ងៃទី៤ ដល់ថ្ងៃទី៦ និងថ្ងៃទី១៤ ដល់ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២០ និងចាប់ពីថ្ងៃទី២៣ ដល់ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០។ លោកបានបន្ថែមទៀតថា ចំពោះទីតាំងទី២ នៅមណ្ឌលវិទ្យាស្ថានអភិវឌ្ឍន៍វិស័យអប់រំ ដែលមានអាសយដ្ឋាននៅសង្កាត់បឹងកេងកង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ នាថ្ងៃទី៧ ទី២០ និង២១ខែវិច្ឆិកា ឆ្នាំ២០២០ និង នៅថ្ងៃទី១៨ និង ទី១៩ ខែធ្នូ ឆ្នាំ២០២០។

លោករដ្ឋមន្ត្រី បានបញ្ជាក់ទៀតថា ចំពោះវិញ្ញាសាធ្វើតេស្តជំនាញ និងភាសាជប៉ុន ចែកជា២ផ្នែក គឺទី១.តេស្តជំនាញថែទាំ មានរយៈពេល៦០នាទី និងមាន៤៥សំណួរ ការប្រឡងវិញ្ញាសាសរសេរមាន ៤០សំណួរ មូលដ្ឋានគ្រឹះ នៃការថែទាំ មាន១០សំណួរ ការយល់ដឹងផ្នែកអារម្មណ៍ និងរូបរាងកាយ មាន៦សំណួរ ជំនាញទំនាក់ទំនងមាន៤សំណួរ ការថែទាំផ្នែករាងកាយ មាន២០សំណួរ និងការប្រឡងអនុវត្ត មាន៥សំណួរ។ ដោយឡែក ផ្នែកទី២វិញ មានការធ្វើតេស្តភាសាជប៉ុនសម្រាប់ជំនាញថែទាំ មានរយៈពេល៣០នាទី និងមាន១៥សំណួរ ពាក្យបច្ចេកទេស នៃការថែទាំមាន៥សំណួរ ការសន្ទនាសម្រាប់ផ្នែកថែទាំមាន ៥សំណួរ និងការអានអត្ថបទទាក់ទងការថែទាំមាន៥សំណួរ។ លោករដ្ឋមន្ត្រី បានឲ្យដឹងទៀតថា ចំពោះពិន្ទុជាប់ គឺចាប់ពី៦០% នៃពិន្ទុសរុប សម្រាប់តេស្តនីមួយៗដែលការធ្វើតេស្តជំនាញ និងភាសាជប៉ុន ត្រូវធ្វើឡើងតាមរយៈប្រព័ន្ធកុំព្យូទ័រ (CBT Method) ហើយ លទ្ធផល នឹងត្រូវជូនដំណឹងមួយខែក្រោយ នៃការប្រឡង។ លោករដ្ឋមន្ត្រី បានបញ្ជាក់ថា ការធ្វើតេស្តជំនាញ និងភាសាជប៉ុននេះ បេក្ខជន ត្រូវបង់ថ្លៃចំនួន២០ដុល្លារ សម្រាប់ទទួលបានសិទ្ធិធ្វើតេស្ត ដែលបេក្ខជននីមួយៗ ត្រូវមានអាយុចាប់ពី១៧ឆ្នាំ ឡើងទៅដោយមិនគិតពីកម្រិតវប្បធម៌ និងត្រូវភ្ជាប់មកជាមួយនូវឯកសារមួយចំនួនដូចជា អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ឬប័ណ្ណបើកបរ៕ អត្ថបទ ៖ សំអឿន

## នគរបាល ជាផ្នែកមួយយ៉ាងសំខាន់ក្នុងការបង្ការទប់ស្កាត់ និងបង្ក្រាបបទល្មើស ជាពិសេសបទល្មើសបំពារបំពានលើស្ត្រី និងកុមារ

https://www.cen.com.kh/ October 19, 2020

ភ្នំពេញ ៖ លោកជំទាវ នាយឧត្តមសេនីយ៍ យក់ សុខា បានថ្លែងថា នគរបាល គឺជាផ្នែកមួយយ៉ាងសំខាន់ក្នុងការបង្ការទប់ស្កាត់ និងបង្ក្រាបបទល្មើសទាំងឡាយដែលនៅតែបន្តកើតមាន ជាពិសេសបទល្មើសបំពារបំពានលើស្ត្រី និងកុមារ ដែលជាជនងាយរងគ្រោះ។ លោកជំទាវ នាយឧត្តមសេនីយ៍ យក់ សុខា អគ្គស្នងការរងនគរបាលជាតិ ថ្លែងបែបនេះ ក្នុងពិធីបើកវគ្គបណ្តុះបណ្តាលគ្រូបង្គោល ស្តីពី កិច្ចការពារកុមាររបស់នគរបាល នាព្រឹកថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២០នេះ នៅអគ្គស្នងការដ្ឋាននគរបាលជាតិ ។ លោកជំទាវ នាយឧត្តមសេនីយ៍ អគ្គស្នងការរងនគរបាលជាតិ បានលើកឡើងបន្តទៀតថា គោលបំណង នៃវគ្គបណ្តុះបណ្តាលនេះ គឺពង្រឹងសមត្ថភាពរបស់នគរបាលថ្នាក់ឃុំ-សង្កាត់ និងថ្នាក់ស្រុក ក្នុងការចូលរួមបង្ការទប់ស្កាត់កុមារឲ្យរួចផុតពីអំពើហិង្សាគ្រប់ប្រភេទ និងបង្ការទប់ស្កាត់កុមារកុំឲ្យប្រព្រឹត្តបទល្មើស និងពង្រឹងសមត្ថភាពរបស់នគរបាល ដើម្បីឲ្យពួកគាត់អាចបណ្តុះបណ្តាលមន្ត្រីនគរបាលនៅក្នុងឃុំ-សង្កាត់ផ្សេងទៀត ក្នុងគោលបំណងឈានទៅធ្វើជាជនបង្គោល ទទួលបន្ទុកកិច្ចការពារកុមារ ចំនួន២រូប នៅក្នុងឃុំ-សង្កាត់ និងស្រុកនីមួយៗនៃខេត្តគោលដៅទាំង៥។

លោកជំទាវ នាយឧត្តមសេនីយ៍ បានគូសបញ្ជាក់ថា "ក្នុងនាមកងកម្លាំងនគរបាលជាតិនិយាយជារួម ហើយនិយាយដោយឡែកក្នុងនាមយើងទាំងអស់គ្នាដែលជាមន្ត្រីនគរបាល ដែលមានវត្តមាននៅទីនេះ សុទ្ធសឹងជាមន្ត្រីជំនាញផ្នែកយុត្តិធម៌ ហើយការងារស្នូលរបស់យើង គោលបំណងសំខាន់ គឺកិច្ចការពារសង្គ្រោះជនរងគ្រោះ ជាពិសេសគឺកុមារ និងការស្វែងរកចាប់ខ្លួនជនល្មើសយកមកកាត់ទោសតាមច្បាប់ ក្នុងគោលដៅដើម្បីធ្វើឲ្យសង្គមជាតិមានសុខសន្តិភាព ហើយប្រជាពលរដ្ឋបានរស់នៅដោយភាពសុខដុមរមនា និងសុវត្ថិភាព ដែលកិច្ចការទាំងនេះទាមទារឲ្យមានការឆ្លើយតបឲ្យបានឆាប់រហ័ស និងមានប្រសិទ្ធភាព"។ លោកជំទាវ បន្តថា កងកម្លាំងយើងដែល

បានសិក្សានៅទីនេះ នឹងក្លាយជាគ្រូបង្គោល ព្រោះកិច្ចការទាំងអស់នេះ មិនមែនយើងធ្វើតែមន្ត្រីដែលចូលរួមនេះទេ អ៊ីចឹងហើយបានជាគោលការណ៍របស់ ឯកឧត្តម នាយឧត្តមសេនីយ៍សន្តិបណ្ឌិត អគ្គស្នងការនគរបាលជាតិ បង្កើតឲ្យមានវគ្គបណ្តុះបណ្តាលនេះឡើង ដើម្បីឲ្យគ្រូបង្គោលយកទៅផ្សព្វផ្សាយបន្ត ពង្រីកការងារ និងចំណេះដឹងបន្តដល់អង្គភាពជំនាញនៅតាមមូលដ្ឋានបានយល់ដូចៗគ្នា ដើម្បីឲ្យការអនុវត្តច្បាប់ ត្រូវតាមនីតិវិធីច្បាប់។ វគ្គបណ្តុះបណ្តាល និងបំប៉នគ្រូបង្គោលនាពេលនេះ មានគោលបំណងសំខាន់ គឺពង្រឹង បំប៉ន សមត្ថភាពមន្ត្រីជំនាញ ដែលពាន់ព័ន្ធទៅលើកុមារទាំងអស់ សម្រាប់បង្ហាត់បង្ហាញបន្តដល់មន្ត្រីនគរបាលទាំងថ្នាក់ជាតិ និងថ្នាក់ស្នងការដ្ឋានរាជធានី-ខេត្តទាំងអស់ ដែលកំពុងប្រតិបត្តិការលើកិច្ចការពារកុមារនេះ។

ក្នុងឱកាសនោះដែរ លោកស្រី លូសៀ សូលីទី Lucia Soleti ប្រធានកម្មវិធីកិច្ចការពារកុមារ បានមានប្រសាសន៍ថា «លោកស្រី សូមចូលរួមអបអរសាទរចំពោះ អគ្គស្នងការដ្ឋាននគរបាលជាតិ ដែលបានខិតខំប្រឹងប្រែងពង្រឹងប្រព័ន្ធកិច្ចការពារកុមារសម្រាប់កម្ពុជា ។ ការអនុម័តច្បាប់ស្តីពីយុត្តិធម៌អនីតិជន និងការតែងតាំងជនបង្គោលទទួលបន្ទុកខាងកិច្ចការពារកុមារ នៅក្នុងឃុំ-សង្កាត់ និងស្រុកនីមួយៗ គឺជាសមាសភាពមួយយ៉ាងសំខាន់ នៃប្រព័ន្ធកិច្ចការពារកុមារនេះ ។ ប្រព័ន្ធកិច្ចការពារកុមារ ដែលអាចដំណើរការទៅបានល្អ គឺទាមទារឲ្យមានកម្លាំងការងារប្រកបដោយវិជ្ជាជីវៈ និងមានសមត្ថភាពពេញលេញក្នុងការកំណត់អត្តសញ្ញាណការពារ និងផ្តល់សេវាដល់កុមារគ្រប់រូប ជាពិសេសកុមារដែលប្រឈមនឹងអំពីហិង្សា ការកេងប្រវញ្ចន៍និងការរំលោភបំពាន »។ លោកស្រីប្រធានកម្មវិធីកិច្ចការពារកុមារ បានបន្តថា អង្គការយូនីសេហ្វ រីករាយនឹងធ្វើការជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិ ដើម្បីកំណត់តួនាទីជាក់លាក់សម្រាប់នគរបាលទទួលបន្ទុកកិច្ចការពារកុមារ ហើយឈានទៅធ្វើការផ្សព្វផ្សាយជាផ្លូវការនូវតួនាទីនេះឲ្យយល់ជ្រាបជាទូទៅនៅថ្នាក់ខេត្ត»។

សូមជម្រាបថា វគ្គសិក្សាលើកទី២នេះ មាន១១មេរៀន ដែលមានគ្រូឧទ្ទេសនាមមកពី ស្ថាប័នពាក់ព័ន្ធរួមមាន ៖ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍១រូប, ប្រធាន-អនុប្រធាននាយកដ្ឋានកិច្ចការប៉ុស្តិ៍នគរបាលរដ្ឋបាល និងនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន៣រូប, មេធាវី នៃគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា ១រូប, សាស្ត្រាចារ្យវង នៃបណ្ឌិត្យសភានគរបាលកម្ពុជា ១រូប, និងមន្ត្រីសម្របសម្រួលនៃអង្គការ Unicerf ១រូប ដែលមានសិក្ខាកាមចូលរួម ចំនួន៣៩នាក់ (ស្រី៤នាក់) មានរយៈពេល៥ថ្ងៃ ចាប់ពីថ្ងៃទី១៩ដល់ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២០ ដែលមកពីស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តសៀមរាប ខេត្តព្រះសីហនុ និងបាត់ដំបង ៕**ដោយៈបញ្ញាស័ក្តិ**

## ទូតកម្ពុជា ប្រចាំអេហ្ស៊ីប ជួយសម្រួលពលករខ្មែរ ២៧នាក់ នៅហ្ស៊កដានី ឲ្យវិលត្រលប់មកកម្ពុជាវិញ

https://dap-news.com/ ByKD102 Posted on October 19, 2020

ភ្នំពេញ៖ ស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំសាធារណរដ្ឋអារ៉ាប់អេហ្ស៊ីប បានជួយសម្របសម្រួលជូនពលករខ្មែរចំនួន ២៧នាក់ ដែលបានបញ្ចប់កិច្ចសន្យាការងារ នៅក្នុងរោងចក្រវាយនភណ្ឌចំនួន ២ នៅប្រទេសហ្ស៊កដានី ឱ្យបានត្រលប់មកប្រទេសកម្ពុជាវិញ តាមរយៈជើងយន្តហោះរបស់ក្រុមហ៊ុនអាកាសចរណ៍ Qatar Airways លេខ QR401 ចាកចេញពីទីក្រុង Amman ប្រទេសហ្ស៊កដានី នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២០ ដោយធ្វើដំណើរឆ្លងកាត់ប្រទេសកាតា និងកូរ៉េ ហើយបានមកដល់កម្ពុជាតាមជើងយន្តហោះ Korean Air លេខ KE ៦៨៩ នៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២០ ។ គួរកត់សម្គាល់ថា ស្ថានឯកអគ្គរាជទូត បានជួយសម្របសម្រួលជូនពលរដ្ឋខ្មែរ រស់នៅប្រទេសហ្ស៊កដានីបានចំនួន ៣លើក សរុបចំនួន ៨៤នាក់ ឱ្យបានវិលត្រលប់មកប្រទេសកម្ពុជាវិញ ដោយសុវត្ថិភាព៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១១៩នាក់

https://www.facebook.com/GDIOfficial 19-10-2020

នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ផង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្ដោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១១៩នាក់ ស្រី ៥០នាក់៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៩៣នាក់

https://www.facebook.com/GDIOfficial 18-10-2020

នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ផង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្ដោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៩៣នាក់ ស្រី ៣១នាក់៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ៣៩នាក់

https://www.facebook.com/GDIOfficial 18-10-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២០ បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ៣៩នាក់ ស្រី ០៥នាក់ និងកុមារ ០២នាក់។ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធន់ធំដំណើរការជាធម្មតា៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិភ្នំដី បានធ្វើការឃាត់ខ្លួនប្រជាពលរដ្ឋខ្មែរចំនួន ២២នាក់ ធ្វើការឆ្លងដែនតាមរបៀង (ស្លាបឆ្វេង និងស្លាបស្តាំ)

https://www.facebook.com/GDIOfficial 17-10-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិភ្នំដី នាវេលាម៉ោង ១៣និង២០នាទី ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២០ បានធ្វើការឃាត់ខ្លួនប្រជាពលរដ្ឋខ្មែរចំនួន ២២នាក់ ស្រី ០៦នាក់ ដែលជាប្រជាពលរដ្ឋរស់នៅក្នុងមូលដ្ឋានស្រុកសំពៅលូន ធ្វើការឆ្លងដែនតាមរបៀង (ស្លាបឆ្វេង និងស្លាបស្តាំ) របស់ប៉ុស្តិ៍ ចេញទៅផ្សារ បានខៅឌីន (ផ្សារជាប់ព្រំដែន) ក្នុងស្រុកខ្លងហាត់ ខេត្តស្រះកែវ ប្រទេសថៃ។ បន្ទាប់មកកម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការអប់រំណែនាំដល់ប្រជាពលរដ្ឋទាំងអស់ខាងលើ ឲ្យបញ្ឈប់ការធ្វើសកម្មភាពបែបនេះទៀត ក្នុងនោះក៏មានការចូលរួមណែនាំពីលោក ងាវ ប៊ុនយាង អភិបាល នៃគណៈអភិបាលស្រុកសំពៅលូន, លោកអភិបាលរងស្រុក ក៏ដូចជាតំណាងលោកប្រធានស្នាក់ការ ត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិភ្នំដី ទើបអនុញ្ញាតឲ្យពួកគាត់ត្រលប់ទៅផ្ទះវិញរៀងៗខ្លួន៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៣៧នាក់

https://www.facebook.com/GDIOfficial 17-10-2020

នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ដើម្បីបង្ការនិងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៣៧នាក់ ស្រី ៧៥នាក់ និងពលរដ្ឋថៃដែលបានចាកចេញមានចំនួន០១នាក់ដោយមានឯកសារចេញពីស្ថានទូតថៃនិងលិខិតបញ្ជាក់សុខភាព៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត បានទទួលពលករខ្មែរ ឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ០៨នាក់

https://www.facebook.com/GDIOfficial 16-10-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២០ បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ០៨នាក់ ស្រី ០៤នាក់។ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធន់ធំ ដំណើរការជាធម្មតា៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៣៦នាក់

https://www.facebook.com/GDIOfficial 16-10-2020

នៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្ដោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ដើម្បីបង្ការនិងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៣៦នាក់ ស្រី ១៦នាក់ និងបានពលរដ្ឋខ្មែរចំនួន ០៥នាក់ ពីភាគីថៃ ពាក់ព័ន្ធនឹងបទលួចចូលកាប់ឈើខុសច្បាប់ ក្នុងទឹកដីប្រទេសថៃ៕

# ថ្ងៃទី២១ ខែតុលា ឆ្នាំ២០២០

## កម្ពុជា-អាម៉េរិក បន្តរួមគ្នាប្រយុទ្ធប្រឆាំងបទល្មើសលើកុមារ ដោយអ្នកអនុវត្តន៍ច្បាប់ទាំងអស់ ត្រូវពង្រីកសមត្ថភាពស៊ើបអង្កេតតាមចាប់ជនល្មើសមកដាក់ទោស

https://www.information.gov.kh/ AKP សៀមរាប ថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០

ស្ថានទូតសហរដ្ឋអាមេរិក ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា បានរៀបចំសន្និសីទ ស្ដីពីបទល្មើសលើកុមាររយៈពេល៣ថ្ងៃ ចាប់ពីថ្ងៃទី២០ ដល់ ថ្ងៃទី២២ ខែតុលា ឆ្នាំ២០២០។ ដើម្បីផ្ដល់នូវការបណ្ដុះបណ្ដាលដល់អ្នកធ្វើការក្នុងជួររដ្ឋាភិបាល ឬទីភ្នាក់ងារមិនរកកម្រៃនានា ធ្វើការក្នុងវិស័យអនុវត្តន៍ច្បាប់ ជួយដល់សេវាកម្មការពារកុមារកិច្ចការសង្គម ការតស៊ូមតិ ផ្នែកកុមារ ការផ្ដល់ការព្យាបាលផ្លូវចិត្ត និងសុខាភិបាល ជាអ្នកដែលធ្វើការផ្ទាល់ជាមួយជន រងគ្រោះជាកុមារក្នុងរឿងឧក្រិដ្ឋ។

ឯកឧត្ដម W. Patrick Murphy ឯកអគ្គរដ្ឋទូតអាមេរិកប្រចាំនៅកម្ពុជា បានថ្លែងថា សន្និសីទនៅថ្ងៃនេះ មិនត្រឹមតែជាការផ្ដល់នូវវិធីសាស្ត្រស្វែងរកព័ត៌មានស៊ើបអង្កេត ប៉ុណ្ណោះទេ គឺបានធ្វើការសិក្សាពីរបៀបតាមរកឧក្រិដ្ឋជនតាមប្រព័ន្ធអ៊ីនធឺណិតផងដែរ។

ឯកឧត្ដមថា សហរដ្ឋអាមេរិកនឹងបន្តសហការជាមួយកម្ពុជាក្នុងការការពារ និងទប់ ស្កាត់បទល្មើសលើកុមារតាមរយៈការស្រាវជ្រាវរកព័ត៌មានឧក្រិដ្ឋជន ហើយពេលយើងមានព័ត៌មានយើង និងផ្ដល់ឱ្យគ្នាទៅវិញទៅមក ឧទាហរណ៍ថា ឧក្រិដ្ឋជន បានធ្វើសកម្មភាពចាប់ កុមារនៅសហរដ្ឋអាមេរិក ហើយបានរត់មកលាក់ខ្លួននៅកម្ពុជា គឺខាងអាម៉េរិក និងផ្ដល់ព័ត៌មានឱ្យខាងកម្ពុជា ដើម្បីឱ្យកម្ពុជាចាប់ឧក្រិដ្ឋជននោះដាក់ទោសទៅតាមច្បាប់នៅកម្ពុជា។ ឯកឧត្ដមឯកអគ្គរដ្ឋទូតបានបន្តថា ការជួញដូរកុមារកន្លងមកនេះ ពួកឧក្រិដ្ឋជន ភាគច្រើនធ្វើទៅលើកុមារណាដែលមានជីវភាពខ្វះខាត ដោយគេបានប្រើប្រាស់ គ្រប់មធ្យោបាយ ដើម្បីកេងប្រវ័ញ្ចលើកុមារ។ ដូច្នេះការជួបជុំរបស់អ្នកអនុវត្តន៍ច្បាប់កម្ពុជា និងសហរដ្ឋអាមេរិកនៅថ្ងៃនេះ គឺមានសារៈសំខាន់ណាស់ ក្នុងពិភាក្សាគ្នា ក្នុងការស្រាវជ្រាវរកឧក្រិដ្ឋជន ដោយយើងអាចដាក់ទិសដៅនិងកំណត់បទឧក្រិដ្ឋមួយ បានច្បាស់លាស់ ពេលមានកិច្ចសហប្រតិបត្តិការនៃប្រទេសទាំងពីរ។

ឯកឧត្ដម កេង សុម៉ារិទ្ធ រដ្ឋលេខាធិការក្រសួងយុត្តិធម៌ បានមានប្រសាសន៍ថា ក្រៅពីយន្តការច្បាប់កម្ពុជាមានឆន្ទៈខ្ពស់ក្នុងការបង្ការទប់ស្កាត់ និងផ្ដល់កិច្ចការពារកុមារ ដោយមានស្ថាប័នជាច្រើនបានកំពុងធ្វើការងារនេះដូចជា គណៈកម្មការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រុមប្រឹក្សាជាតិដើម្បីកុមារ ជាដើម។ ក្រៅពីនេះកម្ពុជា

ក៏បង្កើតឱ្យមានក្រុមមេធាវីតែដោសែន ដែលមានមេធាវីជាសមាជិកច្រើន នៅគ្រប់ រាជធានីខេត្ត ដើម្បីផ្តល់សេវាផ្នែកច្បាប់ដោយឥតគិតថ្លៃ ដល់ស្ត្រី និងកុមាររងគ្រោះ។ ជាមួយគ្នាកម្ពុជាក៏បានចុះកិច្ចព្រមព្រៀងជាមួយប្រទេសអូស្ត្រាលី ស្តីពីការប្រឆាំងការជួញដូរមនុស្ស ហើយថ្មីៗនេះក្រសួងយុត្តិធម៌ក៏បង្ហាញពីកិច្ចប្រតិបត្តិការជាមួយស្ថានទូតអាម៉េ រិកក្នុងការបង្ក្រាបបទល្មើសឆ្លងដែន។ ឯកឧត្តមបានស្នើសុំឱ្យតួអង្គអ្នកអនុវត្តន៍ច្បាប់ទាំងអស់ ដែលបានចូលរួមនៅថ្ងៃនេះ ត្រូវធ្វើការពិភាក្សាគ្នាឱ្យបានផុសផុល និងចែករំលែកបទពិសោធន៍ល្អៗ ដើម្បីស្វែងរក វិធីសាស្ត្រដោះស្រាយបញ្ហាប្រឈមនានាឱ្យបានឆាប់រហ័ស ដើម្បីផ្តល់យុត្តិធម៌ដល់ ជនរងគ្រោះ។

សូមបញ្ជាក់ថា សន្និសីទស្តីពីបទឧក្រិដ្ឋប្រឆាំងកុមារ មានអ្នកចូលរួមជាង ៦០នាក់ មកពីក្រសួងយុត្តិធម៌ នគរបាលជាតិកម្ពុជា អគ្គនាយកដ្ឋានអន្តោប្រវេសន៍ ការិយាល័យស៊ើបអង្កេតសន្តិសុខមាតុភូមិ (HSI) ការិយាល័យស៊ើបអង្កេតសហព័ន្ធ(FBI)និងការិយាល័យសន្តិសុខតំបន់(RSO)និងអង្គការក្រៅរដ្ឋាភិបាលជាច្រើន៕ ដោយៈយុត សៅ

## ថ្នាក់ដឹកនាំ ខេត្តកំពង់ចាម បានស្នើ ឲ្យ ក្រុមជំនាញទាំង ៦ នៃគណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរួបរួមគ្នាបញ្ចេញ សមត្ថភាពរបស់ខ្លួន

https://www.pdikampongcham.info/ ២០ ខែតុលា ២០២០ **អត្ថបទៈ លឹម ប៉ៃលិន**

លោកជំទាវ ប៉ាង ដានី អភិបាលរងខេត្ត តំណាង ឯកឧត្តម អ៊ុន ចាន់ដា អភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម បានសំណូមពរដល់ក្រុមការងារជំនាញទាំង៦ ឲ្យមានការរួបរួមគ្នា និងបញ្ចេញសមត្ថភាពរបស់ខ្លួន ក្នុងការគោរពនូវផែនការព្រមទាំងគោរពតាមតួនាទីរបស់ខ្លួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខណៈដែលមេខ្យល់ត្រូវបានចាប់ខ្លួនជាបន្តបន្ទាប់ព្រមជាមួយការរំដោះជនរងគ្រោះបានជាច្រើនរូបផងដែរ ។ ការស្នើឡើងយ៉ាងដូច្នេះក្នុងកិច្ចប្រជុំត្រួតពិនិត្យការរៀបចំ ផែនការ សកម្មភាព របស់គណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ ខ ប ជ ) នាព្រឹកថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០ នៅសាលាខេត្តកំពង់ចាម ។

ថ្លែងក្នុងកិច្ចប្រជុំនោះដែរ លោកជំទាវ ប៉ាង ដានី អភិបាលរងខេត្តបានវាយតម្លៃខ្ពស់ និងកោតសរសើរចំពោះស្មារតីទទួលខុសត្រូវ និងការខិតខំបំពេញការងារ ជូនរដ្ឋបាលខេត្ត ពីសំណាក់ក្រុមការងារទាំង៦ និងលេខាធិការដ្ឋាន ជាពិសេស ការងារប្រយុទ្ធប្រឆាំងអំពើរជួញដូរមនុស្ស និងទប់ស្កាត់ការធ្វើចំណាកស្រុក មិនស្របច្បាប់ រហូតឈានទៅដល់ការ ចាប់ខ្លួនមេខ្យល់ និងជួយសង្គ្រោះជនរងគ្រោះបានជាបន្តបន្ទាប់ ក្នុងពេលអនុវត្តការងារ កន្លងមក ។ លោកជំទាវ បានបន្តថា ក្នុងកំឡុងពេលមានការរីករាលដាលនៃជំងឺកូវីដ១៩ ដែលធ្វើឲ្យប៉ះពាល់ដល់ការងារ និងជីវភាពរបស់បងប្អូនប្រជាពលរដ្ឋ ហេ ីយគាត់បានត្រលប់មកពីការធ្វើចំណាកស្រុកវិញជាបន្តបន្ទាប់ ចាប់ពីដើមឆ្នាំ២០២០រហូតដល់បច្ចុប្បន្ន អ្នកចំណូលស្រុកកើនដល់៤,៦២៥នាក់ ទន្ទឹមនេះដែរក្រុមការងារយើងក៏បាន ខិតខំបន្តកិច្ចសហការជាមួយ អ្នកពាក់ព័ន្ធ ក៏ដូចជាអង្គការដៃគូនានា ដើម្បីបន្តជួយដោះស្រាយជូនប្រជាពលរដ្ឋ ដែលជួបការលំបាកក្នុងកំឡុងពេលកូវីដ១៩ នេះផងដែរ ។

ជាមួយគ្នានោះ លោកជំទាវ ប៉ាង ដានី ក៏បានសំណូមពរឲ្យបណ្តាអង្គការពាក់ព័ន្ធនានាផ្សេងទៀត មេត្តាចូលរួមសហការ និងគាំទ្រដល់ក្រុមការងារយើងជាបន្តទៀត ដើម្បីទប់ស្កាត់ ការចំណាកស្រុកមិនស្របច្បាប់ និងប្រយុទ្ធប្រឆាំងអំពើរជួញដូរមនុស្ស ជាពិសេសគាំទ្រដល់សកម្មភាពដែលក្រុម ការងារទាំង៦ និងលើកឡើងជាផែនការសកម្មភាពរបស់ខ្លួនក្នុងកិច្ចប្រជុំនេះ។ ព្រមទាំងសូមឲ្យប្រធាន និងសមាជិកនៃក្រុមការងារទាំង៦ ត្រូវខិតខំលើកសកម្មភាពឆ្លើយតប ឲ្យបានច្បាស់លាស់ និងអនុវត្តន៍បាន ដើម្បីសម្រេចបានលទ្ធផលកាន់តែល្អប្រសើរក្នុងឆ្នាំ២០២១ខាងមុខនេះ ផងដែរ ៕

## លោកជំទាវ ប៉ាង ដានី បានអញ្ជើញជាគណៈអធិបតីក្នុងពិធីបើកកិច្ចប្រជុំរៀបចំផែនការសកម្មភាព របស់គណៈកម្មធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅខេត្តកំពង់ចាម

https://www.pdikampongcham.info/ ២០ ខែតុលា ២០២០ **អត្ថបទ៖ ទឹម សំណាង**

លោកជំទាវ ប៉ាង ដានី អភិបាលរងខេត្តដំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តមអ៊ុនចាន់ដាអភិបាលនៃគណៈអភិបាលខេត្តកំពង់ចាមបានលើកឡើងថា៖ ក្រុមការងារបស់គណៈកម្មធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ត្រូវបញ្ចេញឲ្យអស់ពីសមត្ថភាពរបស់ខ្លួនដើម្បីការគោរពនូវផែនការក៏ដូចជាធ្វើតាមនូវតួនាទីរបស់ខ្លួនក្នុងការប្រយុទ្ធប្រឆាំងការជួនដូរមនុស្ស ការលើកឡើងបែបនេះគឺបានធ្វើឡើងក្នុងឱកាស ដែលលោកជំទាវ អញ្ជើញជាគណៈអធិបតីក្នុង ពិធីបើកកិច្ចប្រជុំរៀបចំផែនការសកម្មភាពរបស់គណៈកម្មធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅខេត្តកំពង់ចាម ដែលបានប្រព្រឹត្តទៅនាថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០ និងដោយបានការអញ្ជើញចូលរួមពីសំណាក់ លោក លោកស្រី ជាប្រធានអនុប្រធានមន្ទីរ ស្ថាប័នអង្គភាពពាក់ពន្ធ័និងអាជ្ញាស្រុកមួយចំនួនផងដែរ។

នៅក្នុងរបាយការណ៍របស់លោក ចេង ហ៊ាង ប្រធានមន្ទីរការងារខេត្តកំពង់ចាម បានគូសបញ្ជាក់ថា៖ ចំណាកស្រុកទូទាំងខេត្តកំពង់ចាមសរុបមានចំនួន ៨៤.២២៣នាក់ ក្នុងនោះស្រីមានចំនួ ៤០.៧៧៨ នាក់។ នៅក្នុងឆ្នាំ២០២០នេះ ពលករចំណូលស្រុកមានចំនួនសរុប ៤៧១៩នាក់ ស្រី១៧៧៩នាក់ ស្មើនិង ៨៩% នៃចំណូលស្រុកសរុប និងបានរួចផុតពីជម្ងឺឆ្លងកូវីដ១៩ផងដែរ។ ចំពោះបញ្ហាប្រឈមរបស់បេក្ខ ជននិងអ្នកចំណាកស្រុករួមមានបញ្ហាចាញ់បោកមេខ្យល់ការជួញដូរមនុស្ស និងការឆ្លងមេរោគកូវីដ១៩ និងការរំលោភបំពានសិទ្ធ និងផលប្រយោជន៍ផ្សេងៗ។ល។

អញ្ជើញមានប្រសាសន៍សំណេះសំណាលនាឱកាសនោះលោកជំទាវ ប៉ាង ដានី អភិបាលរងខេត្តដំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តមអ៊ុនចាន់ដាអភិបាលនៃគណៈអភិបាលខេត្តកំពង់ចាមបានបានលើកសរ សើរចំពោះក្រុមការងារដែលបានយកចិត្តទុកដាក់ខិតខំសិក្សាស្រាវជ្រាវ ស្វែយល់ពីសកម្មភាព នៃការជួញដូរមនុស្សរហូតឈានដល់សម្រេចលទ្ធផលជាបន្តបន្ទាប់ក្នុងនោះមេខ្យល់ក៏ចាប់ឃាត់ខ្លួនបាន និង ជនរងគ្រោះក៏យើងបានទទួលហើយដែរ។ លោកជំទាវក៏បានបនតថា៖ក្រុមការងារបស់គណៈកម្មធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ត្រូវបញ្ចេញឲ្យអស់ពីសមត្ថភាពរបស់ខ្លួន ដើម្បីការគោរពនូវផែនការក៏ដូចជាធ្វើតាមនូវតួនាទីរបស់ខ្លួនក្នុងការប្រយុទ្ធប្រឆាំងការជួនដូរមនុស្សពិសេសការស្រាវជ្រាវរុករកបន្ត ពពួកក្រុមមេខ្យល់ដែលតែងតែបញ្ចុះបញ្ចូលអនាព្យាបាលស្លូងគំនិតចាញ់បោកពួកគេតាមការសន្យានានា។ ដូច្នេះសូមក្រុមយើងទាំង៦ ត្រូវបន្តសហការណ៍គ្នាឲ្យបានល្អបន្ថែមទៀតសំដៅបង្កើននូវសមត្ថ ភាពការងារឲ្យកាន់តែប្រសើរនិងទទួលបានភាពជោគជ័យជារៀងរហូត។

## គ្រួសារមួយនៅឃុំពន្លៃ ខេត្តកំពង់ឆ្នាំង ត្រូវបានក្រុមហ៊ុននាំពលករទៅធ្វើការនៅជប៉ុនម្ចឹងទារសំណងចំនួន៥ពាន់ដុល្លារ, គ្រួសារទទូចឲ្យអាជ្ញាធរជួយអន្តរាគមន៍

http://www.freshnewsasia.com/ 2020-10-20 02:26pm

**(កំពង់ឆ្នាំង)៖** បុរសជាពលករម្នាក់បានទៅបំរើការនៅប្រទេសជប៉ុន ហើយបានបាត់ដំណឹងអស់រយៈពេលជាង ៣ខែមកហើយ មិនបានទំនាក់ទំនងមកក្រុមគ្រួសារ ធ្វើឲ្យឪពុកម្តាយប្រពន្ធកូន មានការបារម្ភអំពីសុខទុក្ខដោយមិនដឹងថា រូបគេបានសុខឬទុក្ខយ៉ាងណានោះទេ។ នេះបើតាមការអះអាងរបស់ក្រុមគ្រួសារនៅឯស្រុកខ្មែរ។

ស្ត្រី ទ្រួយ ស្រីពៅ អាយុ២៩ឆ្នាំ ដែលត្រូវជាប្រពន្ធបានរៀបរាប់ប្រាប់អង្គភាពព័ត៌មាន Fresh News កាលពីព្រឹកថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២០ថា បច្ចុប្បន្ននាងមានទីលំនៅក្នុងភូមិស្វាយគយ ឃុំពន្លៃ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង និងមានកូន៣នាក់នៅក្នុងបន្ទុក ដែលកូនរបស់នាងទាំងបីនាក់។ ពួកគេទើបតែមានអាយុពី ២ឆ្នាំ ទៅ៨ឆ្នាំតែប៉ុណ្ណោះ។ រីឯប្តីរបស់នាងឈ្មោះ យុង ពែក អាយុ៣១ឆ្នាំ បានទៅធ្វើ ការនៅប្រទេសជប៉ុន ដោយបានចេញ

ទៅកាលពីថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២០ តាមរយៈក្រុមហ៊ុនមួយមានឈ្មោះថា ក្រុមហ៊ុន អេស៊ាន យូមេន ស៊ឹបផត (ខេមបូឌា)(ASIAN HUMAN SUPPORT (CAMBODIA) Co.,Ltd) ក្រុមហ៊ុននេះមានទីតាំងនៅទីក្រុងភ្នំពេញ។ នាងបានឲ្យដឹងទៀតថា នៅពេលដែលប្តីរបស់នាងបានទៅដល់ប្រទេសជប៉ុន បានរយៈពេលជាង៣ខែដំបូង ប្តីនាងក៏បានផ្ញើប្រាក់មកឲ្យនាង និងឪពុកម្តាយនៅឯស្រុកខ្មែរបានចំនួនពីរដង សរុបជាទឹកប្រាក់បានជាង ១ពាន់ដុល្លារ សម្រាប់ឲ្យនាងសងបំណុលគេ និងបង់ការប្រាក់ឲ្យអង្គការកម្ចីឥណទាន ដែលនាងបានខ្ចីសម្រាប់ឱ្យប្តីនាងស្នាក់នៅរៀនបំប៉ន និងហូបចុកផ្សេងៗ នៅកន្លែងក្រុមហ៊ុន រួមនិងថ្លៃការចេញដំណើរទៅប្រទេសជប៉ុន ដែលខាងក្រុមហ៊ុនតម្រូវឲ្យបង់ចំនួន ៥៥០០ដុល្លារផងនោះ។

នាងថា មុនពេលដែលប្តីនាងបានចេញទៅធ្វើការនៅប្រទេសជប៉ុននេះ ក្រុមគ្រួសារនាងត្រូវចំណាយប្រាក់អស់ជាច្រើន សម្រាប់ការហូបចុកស្នាក់នៅរៀនសូត្រ និងចំណាយផ្សេងៗនៅកន្លែងក្រុមហ៊ុន ព្រោះការស្នាក់នៅរៀនសូត្រកន្លែងក្រុមហ៊ុនខាងលើនេះ រហូតទៅដល់២វគ្គ ដែលមានរយៈពេលជិត២ឆ្នាំឯណោះ មុនពេលធ្លាក់ឈ្មោះបានទៅធ្វើការនៅប្រទេសជប៉ុន ដោយលើកទី១ ត្រូវស្នាក់ នៅរៀនបំប៉នកន្លែងក្រុមហ៊ុនអស់រយៈពេលជិត៨ខែ ហើយមិនមានឈ្មោះចេញទៅធ្វើការនៅប្រទេសជប៉ុន ខាងក្រុមហ៊ុនក៏ឱ្យប្តីរបស់នាងត្រឡប់មកផ្ទះវិញ។ លុះប្តីនាងមកស្នាក់នៅផ្ទះបានប្រមាណជា៥ខែ ខាងក្រុមហ៊ុនក៏បានទូរស័ព្ទមកប្រាប់ក្រុមគ្រួសារនាងថា ឱ្យប្តីនាងឡើងមកធ្វើការសម្ភាសន៍ ព្រោះនៅប្រទេសជប៉ុនកំពុងត្រូវ ការកម្មករសំណង់ ជាបន្ទាន់ ខណៈនោះនាង និងក្រុមគ្រួសារក៏បានប្រញាប់ប្រញាល់នាំប្តីទៅកន្លែងក្រុមហ៊ុននៅឯភ្នំពេញ ព្រោះនឹកស្មានថា បានចេញទៅធ្វើការនៅប្រទេសជប៉ុនភ្លាមៗ តែពេលទៅដល់ ខាងក្រុមហ៊ុន មិនបានធ្វើការសម្ភាសន៍ និងឲ្យចេញទៅភ្លាមៗ ដូចដែលក្រុមហ៊ុនបានទូរស័ព្ទប្រាប់នោះទេ ដោយខាងក្រុមហ៊ុនតម្រូវឱ្យប្តីរបស់នាងស្នាក់នៅរៀនជាបន្តទៀតសិន។ ដោយជ្រុលនិងលង់ខ្ចីលុយអង្គការអស់ជាច្រើនហើយនោះ នាង និងក្រុមគ្រួសារមិនអាចរកប្រាក់មកសងអង្គការវិញបាន ក៏បានសម្រេចចិត្តឲ្យប្តីរបស់នាងនៅស្នាក់រៀនកន្លែងក្រុម ហ៊ុននេះជាបន្ត ទៀត។ រៀនលើកទី២នេះ ប្តីនាងត្រូវស្នាក់នៅរៀនអស់រយៈពេល៧ខែទៀត ទើបធ្លាក់ឈ្មោះបានចេញទៅធ្វើការនៅប្រទេសជប៉ុន។

នាងបានបន្តឲ្យដឹងទៀតថា មុនពេលដែលប្តីនាងបាត់ដំណឹង គឺប្តីរបស់នាងបានទូរស័ព្ទមកនាង ដោយប្រាប់ថា នៅកន្លែងធ្វើការសំណង់ ត្រូវបានថៅកែវាយដំរាល់ ថ្ងៃ ពេលនោះនាងក៏បាននិយាយអង្វរប្តីសុំឱ្យប្តីនាងបន្តធ្វើការជាបន្តទៀតសិន ចាំនាងទៅកន្លែងក្រុមហ៊ុននៅភ្នំពេញ ដើម្បីផ្តល់ព័ត៌មានពីបញ្ហាដែលគេធ្វើបាបប្តី ទៅឲ្យក្រុមហ៊ុនបានជ្រាប ក្រែងក្រុមហ៊ុនជួយរកកន្លែងការងារផ្សេងឲ្យធ្វើ។ នាងថា ពេលប្តីរបស់នាងទូរស័ព្ទមកនាងពីល្ងាច លុះព្រឹកឡើងក៏ស្រាប់តែ ខាងក្រុមហ៊ុនបានទូរស័ព្ទមកក្រុមគ្រួសាររបស់នាង ដោយបានប្រាប់ថាឈ្មោះ យុង ពែក នៅប្រទេសជប៉ុន បានរត់គេចចេញ ពីកន្លែងធ្វើការហើយ ពេលនោះក្រុមហ៊ុនបានឲ្យក្រុមគ្រួសារនាង និងនាងឲ្យជួយទំនាក់ទំនងរកប្តីរបស់នាងផង ថាតើគេរត់ទៅនៅកន្លែងណា?។ គ្រាន់តែបានទទួលដំណឹងនេះ នាង និងក្រុមគ្រួសារ មានការបារម្ភពីប្តីពិសេសគឺក្រុមគ្រួសាររបស់នាងបារម្ភ និងមិនដឹងទៅរកប្តីរបស់នាងនៅកន្លែងណា ព្រោះក្រុមហ៊ុនបានឲ្យគ្រួសារនាង ជួយស្រាវជ្រាវរក នាងនិងក្រុមគ្រួសារ មិនដឹងថាតើទៅរកប្តី ដោយរបៀបណា ព្រោះនាងនៅឯស្រុកខ្មែរឯណោះ។ នាងបន្តថា រយៈពេលដែលក្រុមហ៊ុន បានទូរស័ព្ទមកគ្រួសារនាងឱ្យស្រាវជ្រាវរកប្តីនាង បានប្រមាណជាកន្លះខែក្រោយមក ក៏ស្រាប់តែត្រូវបានសមត្ថកិច្ចនគរបាលស្រុកបរិបូណ៌ បានហៅរូបនាង ឪពុកក្មេករបស់នាង និងបងថ្លៃ ទៅកន្លែងអធិការដ្ឋាននគរបាលស្រុកបរិបូណ៌។ ពេលទៅដល់សមត្ថកិច្ចក៏ បានអានពាក្យបណ្តឹងរបស់ក្រុមហ៊ុន ពាក់ព័ន្ធនឹងបញ្ហាដែលនាង ឪពុកនាង និងបងថ្លៃរបស់នាង បានធ្វើកិច្ចសន្យាជាមួយនឹងក្រុមហ៊ុន មុនពេលដែលប្តីរបស់នាង បានចេញទៅធ្វើការនៅប្រទេសជប៉ុន។ នៅក្នុងលិខិតដែលសមត្ថកិច្ចអានឱ្យក្រុមគ្រួសារនាងស្តាប់នោះដែរ គឺខាងក្រុមហ៊ុនតម្រូវឱ្យគ្រួសារនាងបង់ ប្រាក់ឲ្យក្រុមហ៊ុនចំនួន១៥,០០០ដុល្លារ។

បន្ទាប់ពីបានស្តាប់នូវខ្លឹមសារ ដែលសមត្ថកិច្ចបានអានឱ្យស្តាប់រួចមក ទាំងរូបនាង និងគ្រួសាររបស់នាង មានតែលើកម្រាមដៃ១០ អង្វរទៅដល់ក្រុមហ៊ុនដោយសុំឲ្យក្រុមហ៊ុនយោគយល់ និងជួយរកប្តីរបស់នាងឲ្យឃើញសិន ព្រោះពេលនេះនាង និងក្រុមគ្រួសារ មិនមានប្រាក់បង់ឲ្យក្រុមហ៊ុននោះទេ ព្រោះនាងនៅជំពាក់អង្គការជាង១ម៉ឺនដុល្លារ ដោយនាងត្រូវរកប្រាក់បង់ការរាល់ខែ ក្នុងមួយខែត្រូវបង់៣០០ដុល្លារ។ តាំងពីបាត់ដំណឹងប្តីមក ដោយមិនមានប្រាក់បង់ឲ្យអង្គការ នាងក៏បានទៅស៊ីឈ្នួលឲ្យគេនៅក្រុងភ្នំពេញ ដោយទុកកូនពីរនាក់ផ្ញើនឹងម្តាយឪពុកចាស់ៗនៅផ្ទះ ហើយនាងបានយកកូនតូចមួយ ទៅធ្វើការជាមួយ ដោយកម្រៃក្នុងមួយខែ១៥០ដុល្លារ សម្រាប់យកមកបង់ឱ្យ អង្គការមិនគ្រប់ទេ តែបានអង្គការយោគយល់ និងបានឲ្យនាងបង់តែការក្នុងមួយខែ១៥០ដុល្លារ ដូច្នេះប្រាក់ខែដែលនាងរកបានក្នុងមួយខែ១៥០ដុល្លារ គឺនាងមិនបានសល់ទុកផ្ញើរឱ្យកូននោះទេ ដោយសន្សំបានបន្តិចបន្តួច ដែលថៅកែ គេឱ្យនាងមួយថ្ងៃ២ពាន់រៀល ទៅ៣ពាន់រៀល ដើម្បីសន្សំសម្រាប់ផ្ញើរមកឲ្យកូនរៀនតែប៉ុណ្ណោះ ហេតុនេះនាង និងឪពុកម្តាយដែលមានវ័យចាស់ៗណាស់ទៅហើយនោះ រកប្រាក់ឯណាទៅបង់ឲ្យក្រុមហ៊ុនរហូតដល់ ១៥,០០០ដុល្លារនោះ។

បន្ទាប់ពីសមត្ថកិច្ចនគរបាលស្រុកបរិបូណ៌ បានហៅក្រុមគ្រួសារនាងទៅសួរនាំ រំលងជាង១ខែ ក្រោយមកទៀត ក្រុមគ្រួសារនាងបានទទួលដីកាពីតុលាការខេត្តកំពង់ឆ្នាំង ដែលបានកោះហៅនាង ឪពុកក្មេករបស់នាង និងបងថ្លៃឲ្យទៅឆ្លើយបំភ្លឺនៅតុលាការ នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០២០នេះ ដើម្បីចូលរួមនីតិវិធីត្រៀមទាញហេតុផលពាក់ព័ន្ធនឹងបណ្តឹងរបស់ក្រុមហ៊ុន ដែលបានប្តឹងទាមទារសំណងពីក្រុមគ្រួសារនាងចំនួន៥,០០០ដុល្លារ។ នាងថាបើទោះជាក្រុមហ៊ុនបានបន្ធូរបន្ថយឲ្យក្រុមគ្រួសាររបស់នាងបង់ប្រាក់ទៅឲ្យក្រុមហ៊ុន មកនៅត្រឹមតែ៥ពាន់ដុល្លារក៏ដោយ ទាំងនាង និងកូនៗ រួមទាំងតាយាយចាស់ៗដែលជាឪពុកក្មេក ម្តាយក្មេក រួបទាំងបងថ្លៃផង បានលើកដៃសំពះ សុំអង្វរដល់ក្រុមហ៊ុនសុំលោកមេត្តាអធ្យាស្រ័យ និងយោគយល់ដល់គ្រួសារនាងផង តើឲ្យនាងទៅពឹងអ្វីបើប្តីរបស់នាងបាត់ដំណឹង មិនដែលទំនាក់ទំនងមកនាង និងក្រុមគ្រួសារផងនោះ ដូច្នេះនាង និងក្រុមគ្រួសារ មិនមានលទ្ធភាពរកប្រាក់មកបង់ឲ្យក្រុមហ៊ុននោះទេ ព្រោះបច្ចុប្បន្ននេះនាងក៏នៅជំពាក់អ្នកជិតខាង និងអង្គការជាង ១ម៉ឺនដុល្លារឯណោះ ដោយធ្វើការបានប្រាក់បន្តិចបន្តួច សម្រាប់បង់ឲ្យតែអង្គការមិនគ្រប់ផង ហេតុនេះនាងសុំឲ្យក្រុមហ៊ុន មេត្តាសណ្តុសប្រណី និងអនុគ្រោះដល់ក្រុមគ្រួសារនាង និងសុំជួយរកប្តីរបស់នាងឲ្យឃើញសិនចុះ។ ក្នុងពាក្យបណ្តឹងរបស់ក្រុមហ៊ុនខាងលើនេះ គឺក្រុមហ៊ុនបានប្តឹង៖

*ទី១៖ សុំឲ្យសហកូនបំណុលសងប្រាក់ចំនួន ៥,០០ដុល្លារ ឲ្យមកក្រុមហ៊ុន អេស៊ាន យូមេន ស៊ឹបផត (ខេមបូឌា) ។

*ទី២៖ សុំឱ្យសហកូនបំណុលផ្តល់សំណងជំងឺចិត្ត និងខាតពេលវេលាចំនួន៣,៥០០ដុល្លារ។

*ទី៣៖ សុំឲ្យតុលាការចេញសាលក្រមដែលមានអនុភាព អនុវត្តជាបណ្តោះអាសន្ន។

*ទី៤៖ ប្រាក់ពន្ធលើកម្មវត្ថុបណ្តឹង និងប្រាក់ប្រដាប់ក្តី ជាបន្ទុករបស់សហចុងចម្លើយ។

ជុំវិញករណីខាងលើនេះ តំណាងក្រុមហ៊ុន អេស៊ាន យូមែន ស៊ឹបផត (ខេមបូឌា) បានឆ្លើយបំភ្លឺប្រាប់អង្គភាពព័ត៌មាន Fresh News តាមទូរស័ព្ទនៅព្រឹកថ្ងៃទី១៩ ខែតុលា ឆ្នាំ ២០២០ថា លោកជាតំណាងឲ្យក្រុមហ៊ុននាំពលករទៅប្រទេសជប៉ុនដោយឡែកករណីឈ្មោះ យុង ពេក ដែលជាពលករទៅបម្រើការនៅប្រទេសជប៉ុ តាមរយៈក្រុមហ៊ុនរបស់លោកនេះ គឺឈ្មោះនេះបានរត់ចេញពីកន្លែងការងារ ដោយមិនបានជូនដំណឹងមកក្រុមហ៊ុននោះទេ។ ក្រុមហ៊ុនរបស់លោកនៅពេលដែលបញ្ជូនពលករទៅបម្រើការនៅប្រទេសជប៉ុន មុននឹងទៅក្រុមហ៊ុនរបស់លោកបានធ្វើការណែនាំ និងអប់រំពាក់ព័ន្ធនឹងច្បាប់ការងារ ក៏ដូចជាការរស់នៅធ្វើការ នៅទីនោះផងដែរ។ ជាពិសេសខាងក្រសួងការងារ ក៏ជួយធ្វើការអប់រំណែនាំបន្ថែមទៀតពាក់ព័ន្ធទៅនឹងពលករដែលជួបនូវបញ្ហាផ្សេងៗ ព្រោះទីនោះ គឺមានទាំងសហជីពមានទាំងទីប្រឹក្សាពលករ ជប៉ុន ហើយនិងមានស្ថានទូត សម្រាប់ឲ្យពលករធ្វើការទំនាក់ទំនងផង

ដែរ ប្រសិនបើពលករជួបបញ្ហាផ្សេងៗ។ ម្យ៉ាងទៀត នៅពេលដែលពលករទៅដល់ប្រទេសជប៉ុន ខាងសហជីពនៅជប៉ុន បានអញ្ជើញទីប្រឹក្សាភ្នាក់ងារពលករជប៉ុនដែលជារបស់រដ្ឋ នៅប្រទេសជប៉ុន ដើម្បីចុះមកបណ្ដុះបណ្ដាលពួកគាត់រយៈពេលមួយខែដើម្បីឲ្យចេះធ្វើការទំនាក់ទំនងបើសិនមានបញ្ហាអ្វី ឬក៏កើតទុក្ខមិនសុខចិត្តពួកគាត់អាចប្ដឹងទៅក្រសួង ឬស្ថានទូត នៅទីនោះបានផងដែរ។

ប៉ុន្តែចំពោះឈ្មោះ យុង ពៃក នេះ គឺរត់ចោលពីកន្លែងការងារ ដោយមិនបានជូនដំណឹងមកក្រុមហ៊ុន ឬក៏ក្រុមប្រឹក្សាសហជីពណានៅប្រទេសជប៉ុនបានដឹងនៅឡើយ ហើយឈ្មោះនេះផងដែរ ក៏មានគម្រោងរត់តាំងពីនៅស្រុកខ្មែរមកម្ល៉េះថា នៅពេលមកដល់ប្រទេសជប៉ុនគាត់នឹងរត់ចេញពីការងារ។ បើចំណែកច្បាប់នៅប្រទេសជប៉ុនបើពលកររត់មិនត្រឹមតែប្រឈមមុខជាមួយខាងក្រុមហ៊ុនយើងប៉ុណ្ណោះទេ។ ខាងជប៉ុនបើពលកររត់ ពេលប៉ូលីសគេចាប់បានគាត់ត្រូវមានទោសត្រូវជាប់គុកពី៦ខែ ទៅ៣ឆ្នាំ និងត្រូវបង់សំណងឲ្យគេចំនួន៣ម៉ឺនដុល្លារទៀតផង៕

## ពលការិនីខ្មែររងគ្រោះពីររូប បានមកដល់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញល្ងាចម្សិលមិញនេះ

http://nokorwatnews.com/ 20-10-2020

ភ្នំពេញ៖ ដោយមានកិច្ចអន្តរាគមន៍របស់ស្ថានទូតកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ី ពលការិនីខ្មែររងគ្រោះពីររូប (ឈ្មោះ រិន ស៊ា និងឈ្មោះ យួន ស្រីពៅ) បានមកដល់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញតាមជើងយន្តហោះ MI 608 នៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ០៥៖៣០ នាទីល្ងាច។ ក្នុងអំឡុងពេលរង់ចាំត្រឡប់ទៅកម្ពុជាវិញ ស្ថានទូតបានសម្របសម្រួលទាមទារប្រាក់ខែពីនិយោជក ស្វែងរកការឧបត្ថម្ភថ្លៃសំបុត្រយន្តហោះ ផ្ដល់កន្លែងស្នាក់នៅ និងម្ហូបអាហារបរិភោគ ព្រមទាំងចាត់មន្ត្រីជូនពលការិនីទាំងពីរទៅអាកាសយានដ្ឋានអន្តរជាតិ KLIA ផងដែរ៕

## កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិភ្នំដី បានទប់ស្កាត់ប្រជាពលរដ្ឋ កុំឲ្យធ្វើការឆ្លងដែនតាមរបៀង ចំនួន ០៧នាក់

https://www.facebook.com/GDIOfficial 20-10-2020

នៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ០៥និង០០នាទីព្រឹក កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិភ្នំដី បានធ្វើការល្បាតតាមរបៀងស្លាបឆ្វេង និងស្លាបស្តាំ ក្នុងវង្វង់ប្រតិបត្តិការណ៍របស់ប៉ុស្តិ៍ ដើម្បីទប់ស្កាត់ប្រជាពលរដ្ឋ កុំឲ្យធ្វើការឆ្លងដែនតាមរបៀង។ បន្ទាប់មកកម្លាំងនគរបាលប៉ុស្តិ៍ ក៏បានប្រទះឃើញប្រជាពលរដ្ឋខ្មែរចំនួន ០៧នាក់ ជាប្រជាពលរដ្ឋរស់នៅក្នុងមូលដ្ឋានស្រុកសំពៅលូន ដែលខ្លះជាអ្នកស៊ីឈ្នួលលើកសំភារៈ និងខ្លះទៀតជាអាជីវករ បានធ្វើការឆ្លងដែនចេញទៅផ្សារ បានខៅឌីន (ផ្សារជាប់ព្រំដែន) ស្រុកខ្លងហាត ខេត្តស្រះកែវ ប្រទេសថៃ តាមរបៀង (ស្លាបឆ្វេង និងស្លាបស្តាំ) របស់ប៉ុស្តិ៍។ ក្រោយមកកម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការអប់រំណែនាំដល់ប្រជាពលរដ្ឋទាំងអស់ខាងលើ ឲ្យបញ្ឈប់ការធ្វើសកម្មភាពបែបនេះទៀត និងបានអនុញ្ញាតឲ្យពួកគាត់ត្រលប់ទៅផ្ទះវិញរៀងៗខ្លួន៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៣៧នាក់

https://www.facebook.com/GDIOfficial 20-10-2020

នៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ធង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្ដោះអាសន្ន មិន

អនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ដើម្បីបង្ការនិងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៣៧នាក់ ស្រី ៦៦នាក់៕

## ថ្ងៃទី២២ ខែតុលា ឆ្នាំ២០២០

### សម្តេចតេជោ ហ៊ុន សែន អំពាវនាវឲ្យពលរដ្ឋ រកការងារធ្វើក្នុងស្រុកចៀសវាង ចាញ់បោកមេខ្យល់ នាំទៅក្រៅប្រទេស

https://dap-news.com/national/ ByKD102 Posted on October 22, 2020

ភ្នំពេញ៖ ក្នុងឱកាសអញ្ជើញបន្ត សួរសុខទុក្ខនិងផ្តល់អំណោយ ជូនប្រជាពលរដ្ឋរងគ្រោះដោយទឹកជំនន់ ក្នុងស្រុកថ្មពួក និងក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យប្រមាណ ១ម៉ឺនគ្រួសារ នៅព្រឹកថ្ងៃទី២២ ខែតុលា ឆ្នាំ ២០២០នេះ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃ ព្រះរាជាណាចក្រកម្ពុជា បានអំពាវនាវឲ្យប្រជាពលរដ្ឋខ្មែរ ខិតខំស្វែងរកការងារធ្វើក្នុងស្រុក ចៀសវាងចេញទៅធ្វើការ នៅក្រៅប្រទេសនាំឲ្យមាន ការចាញ់បោកមេខ្យល់ ។

### លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន អំពាវនាវឱ្យពលករទាំងអស់កុំចាញ់បោកមេខ្យល់ធ្វើការចំណាកស្រុកដោយប្រថុយប្រថាន

https://grandnewsasia.com/ 22-10-2020

នៅព្រឹកថ្ងៃទី២២ ខែតុលា ឆ្នាំ២០២០ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានអញ្ជើញក្នុងឱកាសជួបសំណេះសំណាលសួរសុខទុក្ខ និងចែកអំណោយជូនប្រជាពលរដ្ឋ ដែលរងគ្រោះដោយសារទឹកជំនន់ នៅស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ។ នាឱកាសនោះលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានថ្លែងថា សូមបងប្អូនប្រជាពលរដ្ឋទាំងអស់មានការប្រុងប្រយ័ត្នជំងឺឆ្លងកូវីដ-១៩ ហើយការពារឱ្យបានកុំនាំមេរោគកូវីដ-១៩ មកឱ្យគ្រួសារ និងសហគមន៍រស់នៅរបស់ខ្លួនឱ្យសោះ។ លោក បានថ្លែងបន្តផ្តាំផ្ញើដល់ពលករទាំងអស់កុំចាញ់បោកមេខ្យល់ចេញទៅធ្វើការនៅប្រទេសថៃ ដោយធ្វើការបង់លុយឱ្យជនខិលខូចទាំងនោះ ខ្លះទារយកលុយមុនចំនួន១០០$ ខ្លះ២០០$ ជាថ្នូរបានការងារធ្វើនៅក្រៅប្រទេស។ ទន្ទឹមនោះផងដែរ លោកនាយករដ្ឋមន្ត្រី បានអំពាវនាវយ៉ាងទទូចដល់ប្រជាពលរដ្ឋទាំងអស់តស៊ូជម្នះឧបសគ្គនេះ កុំដោយសារតែជួបខ្វះខាតក្នុងជីវភាព បែរជាត្រូវបង្ខំចិត្តចាកចេញពីស្រុកកំណើតរបស់ខ្លួន ទៅកាន់ប្រទេសគេនោះ ដោយធ្វើចំណាកស្រុកដោយប្រថុយប្រថាន ក្នុងស្ថានភាពនេះ មានជំងឺឆ្លងកូវីដ-១៩ នៅទូទាំងសកលលោកផង និងជួបគ្រោះទឹកជំនន់ផង ត្រូវនាំគ្នារស់នៅក្នុងស្រុក ហើយខិតខំត្រៀមលក្ខណៈជាមុនដើម្បីបង្កបង្កើនផលកសិកម្មវិញ រកស៊ីតក់ៗពេញបំពង បានរស់នៅជួបជុំគ្រួសារ៕

### មន្ត្រីក្រសួងមហាផ្ទៃ ក្រើនរំលឹកដល់ស្ត្រីខ្មែរគ្រប់រូប ដែលចង់ស្វែងរកគូស្រករនៅក្រៅប្រទេសត្រូវគិតគូរឲ្យបានច្បាស់លាស់

http://btv.com.kh/ 21/10/2020

ភ្នំពេញ ៖ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស បានក្រើនរំលឹកដល់ស្ត្រីខ្មែរគ្រប់រូប ត្រូវគិតគូរឲ្យបានច្បាស់លាស់ មុននឹងសម្រេចចិត្តជ្រើសរើសគូស្រករ ដែលជាជនជាតិបរទេស ខណៈមានស្ត្រីខ្មែរមួយចំនួនត្រូវបានចាញ់បោកគេ (មេ

ខ្យល់)ថា បានប្តីបរទេសមានជីវភាពប្រសើរអាចជួយខ្លួនឯង និងគ្រួសារបានជាដើមនោះ។ ថ្លែងប្រាប់អ្នកយកព័ត៌មានក្រោយពី អញ្ជើញបើកសិក្ខាសាលា ស្តីពី សេវាគាំទ្រជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅភោជនីយដ្ឋានទន្លេបាសាក់២ នៅព្រឹកថ្ងៃទី២១ ខែតុលា ឆ្នាំ២០២០នេះ លោកជំទាវ ជូ ប៊ុនអេង បានលើកឡើងថា យើងបានឃើញស្រាប់ហើយថា កាលពីកន្លងទៅថ្មីៗនេះមានស្ត្រីខ្មែរម្នាក់ បានចាញ់បោកមេខ្យល់ឲ្យទៅរៀបការជាមួយជនជាតិចិន ដោយគេបោកថា នឹងទទួលបានប្រាក់ និងការងារស្រួលដើម្បីយកមកផ្គត់ផ្គង់ក្រុមគ្រួសារបានដោយងាយនោះ។ ប៉ុន្តែផ្ទុយទៅវិញការរៀបការនោះមិនងាយស្រួលដូចការចង់បានរបស់គាត់ ឬងាយស្រួលដូចអ្វីដែលមេខ្យល់បានប្រាប់គាត់នោះឡើយ ដូច្នេះ មុននឹងសម្រេចចិត្តយកបរទេសមកធ្វើជាគូស្រករ ត្រូវធ្វើការពិចារណាឲ្យបានដិតដល់ជៀសវាង មានវិប្បដិសារី ទៅថ្ងៃក្រោយ។ ជាមួយគ្នានោះដែរ លោកជំទាវ ជូ ប៊ុនអេង ក៏បានលើកឡើងផងដែរថា នាពេលបច្ចុប្បន្ននេះ អាជ្ញាធរពាក់ព័ន្ធទាំងអស់កំពុងតែបន្តសហការគ្នាយ៉ាងសកម្មក្នុងការស្វែងរក និងទប់ស្កាត់នូវមេខ្យល់ទាំងនោះ ដែលបានដើរបោកបងប្អូនប្រជាពលរដ្ឋតាមរយៈរូបភាពនេះ និងរូបភាពផ្សេងៗទៀត យកមកផ្តន្ទាទោសទៅតាមច្បាប់ តែទោះជាយ៉ាងណាក្តីក៏ត្រូវមានការសហការជាមួយជនរងគ្រោះ និងបងប្អូនប្រជាពលរដ្ឋផងដែរទើបអាចទៅរួច។

កាលពីកន្លងទៅថ្មីៗនេះ ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំទីក្រុងសៀងហៃ ប្រទេសចិន បានសហការជាមួយអាជ្ញាធរចិន អន្តរាគមន៍ជួយនារីខ្មែរម្នាក់ឈ្មោះ សែម ស្រីពេជ្រ ស្នាក់នៅខេត្តជឺជាំង ប្រទេសចិនដែលមានបំណងត្រឡប់មកកម្ពុជាវិញ បន្ទាប់ពីនាងអះអាងតាមរយៈហ្វេសបុកថា មិនអាចរស់នៅចុះសម្រុងជាមួយស្វាមីបាន។ បច្ចុប្បន្នស្ត្រីរូបនេះ កំពុងស្នាក់នៅទីក្រុងសៀងហៃប្រទេសចិន ហើយស្ថានអគ្គកុងស៊ុលប្រចាំនៅទីក្រុងសៀងហៃ បានចេញលិខិតបើកផ្លូវដល់រូបនាង ហើយប៉ូលិសចិនក៏បានយល់ព្រមនិងប្រគល់ទិដ្ឋាការជូនដល់នាងនៅថ្ងៃពុធនេះផងដែរ ដើម្បីឲ្យវិលត្រឡប់មកកម្ពុជាវិញនោះ៕ អត្ថបទ ៖ បានចក់

## អាមេរិកជួយបណ្តុះបណ្តាលមន្ត្រីកម្ពុជាលើ«ជំនាញឧក្រិដ្ឋកម្មប្រឆាំងកុមារ»

https://thmeythmey.com/ 21, Oct 2020 ,  10:33 pm  ដោយ: អ៊ីសា រ៉ូហានី ( Isa Rohany )

សៀមរាប៖ ស្ថានទូតអាមេរិកប្រចាំកម្ពុជា បានរៀបចំវគ្គបណ្តុះបណ្តាលផ្នែកច្បាប់ និងជំនាញឧក្រិដ្ឋកម្មប្រឆាំងកុមារ ដល់មន្ត្រីកម្ពុជាប្រហែល១០០នាក់ ដើម្បីបង្កើនសមត្ថភាព ក្នុងការតាមចាប់ និងផ្តល់ទោសដល់ឧក្រិដ្ឋជនចាប់ពីថ្ងៃទី២០ ដល់ថ្ងៃទី២២តុលា ឆ្នាំ២០២០។ វគ្គបណ្តុះបណ្តាលផ្នែកបច្ចេកទេសឧក្រិដ្ឋកម្មប្រឆាំងកុមារដែលធ្វើឡើងនៅសណ្ឋាគារសូហ្វីតែល ខេត្តសៀមរាបនេះមានគោលដៅចម្បងផ្តល់វិធីសាស្ត្រក្នុងការកំណត់ស្វែងរកព័ត៌មាននិងស៊ើបអង្កេតលើឧក្រិដ្ឋលើកុមារពឹងផ្អែកលើប្រព័ន្ធអ៊ីនធឺណិត (Internet) ឬប្រព័ន្ធឌីជីថល (Digital)។ នេះបើតាមឯកអគ្គរដ្ឋទូតអាមេរិកប្រចាំកម្ពុជាលោក W. Patrick Murphy។ អគ្គរដ្ឋទូតរូបនេះបន្តថា វគ្គបណ្តុះបណ្តាលនេះ ក៏មានបញ្ចូលរបៀបសួរសំណួរទៅកាន់ទាំងជនរងគ្រោះ និងទាំងឧក្រិដ្ឋជន ដើម្បីទទួលបានព័ត៌មានមួយពេញលេញមួយសម្រាប់ការសម្រេចចិត្តមួយ។ កន្លងមករដ្ឋាភិបាលអាមេរិក បានគាំទ្រ និងសហប្រតិបត្តិការជាមួយកម្ពុជា ក្នុងការទប់ស្កាត់ឬប្រយុទ្ធប្រឆាំងការជួញដូរលើកុមារ, ការរំលោភបំពានកុមារ ជាពិសេសពង្រឹងសមត្ថភាពក្នុងការតាមចាប់ឧក្រិដ្ឋជន។ លោក Murphy មានប្រសាសន៍ដូច្នេះ៖«យើងជួយក្នុងការស្រាវជ្រាវរកព័ត៌មាន ហើយនៅពេលដែលយើងមានព័ត៌មាន គឺយើងផ្តល់ឱ្យខាងកម្ពុជា ដោយកម្ពុជា ជាអ្នកសម្រេចថាត្រូវថ្កោលទោសបញ្ជូនគាត់[ឧក្រិដ្ឋជន]ត្រលប់ទៅប្រទេសវិញ ឬហាមអ្នកទោសមិនឱ្យមកប្រទេសកម្ពុជាវិញ ឬក៏យ៉ាងណា...»។

ឯកអគ្គរដ្ឋទូតរូបនេះបានបញ្ជាក់ថា ក្នុងករណីខ្លះឧក្រិដ្ឋជន គឺបានប្រព្រឹត្តបទល្មើសនៅសហរដ្ឋអាមេរិក ហើយក៏បានមកលាក់ខ្លួននៅកម្ពុជា។ ដូច្នេះអាមេរិកនឹងសហការជាមួយកម្ពុជាក្នុងការស្វែងរកឧក្រិដ្ឋជន ដើម្បីផ្តល់

ទោស។ តាមពិតទៅ កិច្ចការងារតាមចាប់ឧក្រិដ្ឋជនដែលប្រព្រឹត្តបទល្មើសប្រឆាំងកុមារនេះ អាជ្ញាធរអាមេរិកមិនត្រឹមតែមានសហប្រតិបត្តិការជាមួយកម្ពុជានោះទេ គឺមាននៅគ្រប់បណ្តាប្រទេសនានាជុំវិញពិភពលោក។ កិច្ចសហប្រតិការទ្វេភាគីលើការប្រឆាំងឧក្រិដ្ឋកម្មប្រឆាំងកុមារនេះ គឺមានសារៈសំខាន់ណាស់ដែលទាមទារឱ្យភាគីទាំងពីរស្រាវជ្រាវ និងស៊ើបអង្កេតទៅលើឧក្រិដ្ឋជន ក្នុងការកំណត់នូវឧក្រិដ្ឋកម្មមួយយ៉ាងច្បាស់លាស់។ នេះបើតាមការលើកឡើងរបស់លោក Murphy។ «ដូច្នេះ យើងបានសហការជាមួយក្រសួងពាក់ព័ន្ធជាច្រើន។ ក្នុងនោះមានក្រសួងយុត្តិធម៌ ក្រសួងព័ត៌មាន ក៏ដូចជាអភិបាលខេត្តនៅតាមខេត្តនីមួយៗ ដើម្បីយកប្រមូលព័ត៌មាន។ អ៊ីចឹងនៅពេលដែលយើងសហការបែបនេះ យើងនឹងទទួលបានព័ត៌មានជាក់លាក់ ហើយយើងនឹងអាចសហការក្នុងការទប់ស្កាត់អំពើជួញដូរលើកុមារ នៅក្នុងតំបន់នីមួយៗ»។ អគ្គរដ្ឋទូតអាមេរិកប្រចាំកម្ពុជាថ្លែងដូច្នេះ។

*លោក កេង សុម៉ារិទ្ធ រដ្ឋលេខាធិការក្រសួងយុត្តិធម៌ ក្នុងពិធីបើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីកម្ពុជាលើឧក្រិដ្ឋកម្មប្រឆាំងកុមារ កាលពីថ្ងៃទី២០តុលា។* ថ្មីៗនេះដែរ ក្រសួងយុត្តិធម៌ក៏បានបង្ហាញនូវជំហរក្នុងការបង្កើតកិច្ចសហប្រតិបត្តិការ ជាមួយសហរដ្ឋអាមេរិក ដើម្បីផ្តល់ស្ថិតិឬសំណុំរឿងជួញដូរមនុស្ស នៅតាមបណ្តាតុលាការក្រោមការងារជំនាញរបស់ក្រសួងយុត្តិធម៌។ លោក កេង សុម៉ារិទ្ធ រដ្ឋលេខាធិការក្រសួងយុត្តិធម៌ ដែលបានចូលរួមក្នុងពិធីបើកវគ្គបណ្តុះបណ្តាលនេះដែរនោះបានបញ្ជាក់ថា ក្រសួងយុត្តិធម៌កន្លងមកបានផ្តល់កិច្ចក្នុងការបង្ក្រាបបទល្មើសឆ្លងដែននេះដែរ។ យ៉ាងណាមិញលោកសង្កត់ធ្ងន់ថា ការប្រឆាំងបទឧក្រិដ្ឋត្រូវការកិច្ចសហការគ្នាជិតស្និទ្ធរវាងភាគីពាក់ព័ន្ធ។ លោក កេង សុម៉ារិទ្ធ បានបញ្ជាក់ដូច្នេះថា៖« ការបង្ការ និងការទប់ស្កាត់បទល្មើសប្រឆាំងកុមារនៅកម្ពុជាមិនមែនជាកិច្ចការ ឬការទទួលខុសត្រូវរបស់ស្ថាប័នណាមួយឡើយ។ ហេតុដូច្នេះ ក្រៅពីកិច្ចសហប្រតិបត្តិការដែលបានលើកឡើងនេះ ដើម្បីចូលរួមកិច្ចការពារកុមារ គឺទាមទារឱ្យមានការចូលរួមយ៉ាងផុសផុល និងកិច្ចសហប្រតិបត្តិការដ៏ល្អពីបណ្តាក្រសួង ពីស្ថាប័នរបស់រដ្ឋាភិបាល តុលាការ ដៃគូអភិវឌ្ឍ វិស័យឯកជន និងសង្គមស៊ីវិលជាដើម»៕

## ពលករម្នាក់ដែលត្រូវបានក្រុមហ៊ុនមួយនាំទៅធ្វើការនៅប្រទេសជប៉ុនប្តឹងទារលុយពីក្រុមគ្រួសារពេលនេះបានដោះស្រាយហើយ

https://gdlf-kh.com/ 21/10/2020 Sam Sophearum កំពង់ឆ្នាំង

ខេត្តកំពង់ឆ្នាំង ៖ ករណីពលករម្នាក់ឈ្មោះ យុង ពែក ភេទប្រុស នៅស្រុកបរិបូណ៌ បានបាត់ខ្លួន នៅប្រទេស ជប៉ុន ហើយត្រូវក្រុមហ៊ុននាំចេញប្តឹងទារលុយពីក្រុមគ្រួសារទៅតុលាការ ។ ករណីនេះការិយាល័យប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន បានហៅមកសម្ភាសន៍ រួចហើយដោយបានអោយដឹងថា ប្តីគាត់បានទៅធ្វើកម្មករនៅប្រទេសជប៉ុនតាមរយៈក្រុមហ៊ុនAsean Human Support (មានទីតាំងភ្នំពេញ) តាំងពីខែ មីនា ឆ្នាំ ២០២០ ដោយបានបង់លុយអោយក្រុមហ៊ុនសរុបជាង ៦០០០ដុល្លារ រួចហើយ។ ក្រោយមកប្តីនាងបានទូរស័ព្ទប្រាប់ថាថៅកែ វាយធ្វើបាបពិបាករស់នៅ ហើយក៏បាត់ដំណឹងរហូតដល់ ០៣ខែ ស្រាប់តែក្រុមហ៊ុន មកប្តឹងនាងនៅតុលាការថា ប្តីនាងរត់ចេញ ហើយទារលុយពីនាងរហូតដល់ ១៥០០០ដុល្លារ ដោយមិនបានជួយរកប្តីនាងទេ។ ករណីនេះនៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០២០ នាងបានទៅបំភ្លឺរួច ខាងក្រុមហ៊ុនសុំដកពាក្យវិញហើយ។ ចំនែកជំនាញក៏បានទាក់ទងទៅក្រសួង ដើម្បីអន្តរាគមន៍រកប្តីគាត់រួចហើយដែរ ៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៣០នាក់

https://www.facebook.com/GDIOfficial 21-10-2020

នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្ដោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការនិងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៣០នាក់ ស្រី ៦២នាក់៕

## ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២០

### ក្រសួងការបរទេសថា ស្ត្រីខ្មែរ៧៥នាក់ ត្រូវបានរំដោះក្រោយពីចាញ់បោករៀបការប្ដីនៅចិន

https://www.rfa.org/khmer/news/ ដោយ ហេង រស្មី 2020-10-22

មន្ត្រីជាន់ខ្ពស់ក្រសួងការបរទេសថា ក្នុងរយៈពេល៩ខែ នេះ អាជ្ញាធរបានរំដោះស្ត្រីខ្មែរចំនួន៧៥ នាក់ ដែលបានចាញ់បោកគេទៅរៀបការនៅក្នុងប្រទេសចិន។ មន្ត្រីសង្គមស៊ីវិលដែលឃ្លាំមើលសិទ្ធិការងារលើកឡើងថា ដោយសារតែបញ្ហាជីវភាព ទើបធ្វើឱ្យស្ត្រីខ្មែរងាយស្រួលបាញ់បោករៀបការជាមួយជនជាតិចិនដែលមិនស្គាល់ប្រវត្តិច្បាស់លាស់។

អ្នកនាំពាក្យក្រសួងការបរទេសលោក កុយ គួង មានប្រសាសន៍ថា ស្ត្រីខ្មែរចុងក្រោយគេ ដែលបានរំដោះចេញពីទីក្រុងសៀងហៃ ប្រទេសចិន បានមកដល់ស្ថានអគ្គកុងស៊ុល កាលពីយប់ ថ្ងៃទី១៦ តុលា ដោយសុវត្ថិភាព។ លោកថា ស្ត្រីរូបនោះបានស្នាក់នៅស្ថានអគ្គកុងស៊ុល រហូតដល់ថ្ងៃទី២២ ខែតុលា ឆ្នាំ ២០២០ ទើបអាចចេញដំណើរត្រឡប់ទៅកម្ពុជាវិញតាមជើងយន្តហោះស្ព្រីង អ៊ែរឡាញ(Spring Airlines 9 c8533) ដោយចេញដំណើរពីទីក្រុងសៀងហៃ ហើយនិងទៅដល់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ វេលាម៉ោង ៥ល្ងាចថ្ងៃដដែលនេះ។ ក្រសួងការបរទេសកម្ពុជាថា ស្ថានកុងស៊ុលកម្ពុជាប្រចាំនៅក្នុងទីក្រុងសៀងហៃ ប្រទេសចិន បានសហការជាមួយអាជ្ញាធរចិនជួយស្ត្រីខ្មែរមួយរូប ស្នាក់នៅក្នុងខេត្តជឺជាំង ដោយសារតែលោកស្រីរស់នៅមិនចុះសម្រុងគ្នាជាមួយស្វាមី ហើយបានបង្ហោះតាមបណ្ដាញសង្គមហ្វេសប៊ុកសុំឱ្យលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ជួយអន្តរាគមន៍។ រដ្ឋាភិបាលកម្ពុជាបានជួយស្ត្រីខ្មែរចំនួន ៧៥ នាក់ហើយ ក្រោយពីចាញ់បោកគេទៅរៀបការនៅក្នុងប្រទេសចិន ក្នុងរយៈពេល៩ខែកន្លងទៅនេះ។

រដ្ឋលេខាធិការក្រសួងមហាផ្ទៃអ្នកស្រី ជូ ប៊ុនអេង និងជាអនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស មានប្រសាសន៍ប្រាប់ក្រុមអ្នកការសែត នៅក្នុងសិក្ខាសាលាថ្នាក់ជាតិ ស្ដីពីការជួញដូរមនុស្សថា ស្ត្រីខ្មែរក្មេងៗងាយនឹងរងគ្រោះដោយសារចាញ់បោកគេទៅរៀបការជាមួយនៅក្រៅប្រទេស។ អ្នកស្រីថា ការរៀបការនៅក្រៅប្រទេសដោយសង្ឃឹមថា នឹងមានជីវភាពសមរម្យ ធ្វើឲ្យស្ត្រីខ្មែរងាយស្រួលក្នុងការចាញ់បោកគេ។ អ្នកស្រីឲ្យដឹងទៀតថា ស្ត្រីខ្មែរគួរតែទប់ស្មារតី ដើម្បីកុំឲ្យចាញ់បោកគេ ហើយរៀនរស់នៅក្នុងប្រទេសប្រសើរជាង៖«អ៊ីចឹងកុំចេញតែប្រថុយប្រថាន យើងរៀនរស់នៅក្នុងស្រុកក្នុងស្ថានភាពមួយល្អប្រសើរដូចគេដូចឯង។ ពីព្រោះមនុស្សរាប់លាននាក់គេអាចរស់បាន តើហេតុអ្វីយើងមិនអាចរស់បាន ហើយបើចេញទៅក្រៅប្រទេស យើង

មិនហាមឃាត់ទេ បើក្នុងករណីមានសុវត្ថិភាព។ ប៉ុន្តែបើយល់ថា ចេញទៅចាញ់បោកគេ ហើយគ្មានសុវត្ថិភាព គួរតែទប់ស្កាត់ចិត្តខ្លួនឯងដើម្បីកុំឲ្យមានការចាញ់បោកបន្តទៀត»។

ទាក់ទិននឹងបញ្ហាស្ត្រីខ្មែរចាញ់បោកគេនេះ នាយកប្រតិបត្តិ នៃមជ្ឈមណ្ឌលសម្ពន្ធភាពការងារ និងសិទ្ធិមនុស្ស លោក មឿន តុលា មានប្រសាសន៍ថា ស្ត្រីខ្មែរងាយស្រួលរងគ្រោះចាញ់បោកគេ ទៅរៀបការនៅក្រៅប្រទេស គឺបណ្ដាលមកពីភាពក្រីក្រ គ្មានការងារធ្វើ ជំពាក់បំណុលគេ ហើយនឹងប្រព័ន្ធសេវាសង្គមរបស់រដ្ឋាភិបាលមិនទាន់បានទូលំទូលាយ។ លោកថា នៅបណ្ដាប្រទេសមួយចំនួននៅពេលណាដែលពលរដ្ឋអត់ការងារធ្វើ រដ្ឋាភិបាលជាអ្នកទទួលបន្ទុកចំណាយមួយចំនួនរបស់ពលរដ្ឋ ប៉ុន្តែនៅកម្ពុជាពុំទាន់មានប្រព័ន្ធសង្គមឲ្យបានគ្រប់គ្រាន់ទេ គឺពលរដ្ឋប្រឹងរស់ ប្រឹងរកការងារ ប្រឹងរកចំណូលអ្វីផ្សេងៗដោយខ្លួនឯង។ លោកបន្ថែមថា មេខ្យល់ក៏ជាចំណុចសំខាន់ក្នុងការទាក់ទាញស្ត្រីខ្មែរ ទៅរៀបការនៅក្រៅប្រទេសផងដែរ៖ «ដោយសារតែមានមេខ្យល់មកបញ្ចុះបញ្ចូលថា គាត់អាចមានឱកាស ទទួលបានការងារធ្វើនៅក្រៅប្រទេស។ល។ ទាំងប្រទេសថៃ(Thailand)ក្ដី ម៉ាឡេស៊ី(Malaysia) ចិន(China) កូរ៉េ (South Korea) ឬមួយជប៉ុន(Japan) ជាដើម ។ មេខ្យល់នេះមែនទែនទៅដោយសារការអនុវត្តច្បាប់នៅកម្ពុជា នៅមានភាពធូររលុង ហើយអំពើពុករលួយយើងនៅខ្ពស់។ អ៊ីចឹង ជាឱកាសមួយរបស់មេខ្យល់ហ្នឹងអាចធ្វើសកម្មភាពរាងទូលំទូលាយដែរ»។

របាយការណ៍ ក្រសួងការបរទេសសហរដ្ឋអាមេរិក ស្ដីពីការជួញដូរមនុស្សឆ្នាំ២០២០ បានបង្ហាញថា អំពើពុករលួយយ៉ាងរាលដាលជួយជំរុញមានបទល្មើសជួញដូរមនុស្ស។ របាយការណ៍បន្ថែមទៀតថា មន្ត្រីពុករលួយសម្រួលការជួញដូរឆ្លងកាត់ព្រំដែន រារាំងការស៊ើបអង្កេត និងការកាត់ទោស ហើយក្នុងករណីខ្លះ ទទួលបានផលចំណេញដោយផ្ទាល់ពីការជួញដូរ៕

## កិច្ចប្រជុំត្រួតពិនិត្យរបាយការណ៍រយៈពេល ១០ខែ ឆ្នាំ២០២០ របស់លេខាធិការដ្ឋាន នៃគណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

https://gdlf-kh.com/ 2020/10/23/ Kao sophy ខេត្តកោះកុង

ខេត្តកោះកុង៖ ថ្ងៃព្រហស្បតិ៍ ៦ កើត ខែកត្តិក ឆ្នាំជូតទោស័ក ពុទ្ធសករាជ ២៥៦៤ ត្រូវនឹងថ្ងៃទី២២ ខែតុលា ឆ្នាំ២០២០ លោក ស្រេងហុង អភិបាលរង នៃគណៈអភិបាលខេត្តកោះកុង និងជាប្រធានលេខាធិការដ្ឋាន នៃគណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានអញ្ជើញដឹកនាំកិច្ចប្រជុំត្រួតពិនិត្យរបាយការណ៍រយៈពេល១០ខែ ឆ្នាំ២០២០ និងលើកទិសដៅការងារបន្ត របស់លេខាធិការដ្ឋាន នៃគណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សដោយមានការចូលរួមពីមន្ត្រីជំនាញមកពីមន្ទីរ អង្គភាពពាក់ព័ន្ធមួយចំនួន។

លោក ស្រេង ហុង បានមានប្រសាសន៍លើកឡើងថា ដើម្បីឲ្យរបាយការណ៍រយៈពេល ១០ខែ របស់លេខាធិការដ្ឋាន នៃគណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សមានលក្ខណៈគ្រប់ជ្រុងជ្រោយ សូមសមាជិកអង្គប្រជុំយកចិត្តទុកដាក់ពិនិត្យ និងកែតម្រូវរាល់ចំណុចខ្វះចន្លោះឲ្យបានល្អិតល្អន់ មុននឹងគោរពជូនជំទាវអភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចុះហត្ថលេខា និងដើម្បីគោរពជូនគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សបានជ្រាបជារបាយការណ៍៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៥១នាក់

https://www.facebook.com/GDIOfficial 22-10-2020

នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្ដោះអាសន្ន មិន

អនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការនិងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបរយានយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៥១នាក់ ស្រី ៥៨នាក់៕

## ភាគីថៃបានបញ្ជូនពលរដ្ឋខ្មែរចំនួន ០៧នាក់ ឲ្យមកប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ ពីបទឆ្លងដែនខុសច្បាប់

https://www.facebook.com/GDIOfficial 22-10-2020

នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០២០ ខាងភាគីថៃបានបញ្ជូនពលរដ្ឋខ្មែរចំនួន ០៧នាក់ ឲ្យមកប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ ពីបទឆ្លងដែនខុសច្បាប់ ទៅកាប់ឈើនៅប្រទេសថៃ ដែលចេញតាមច្រកអានសេះ ខេត្តព្រះវិហារ៕

# ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២០

## ក្រសួងមហាផ្ទៃ បើកវគ្គបណ្តុះបណ្តាលមន្ត្រីថ្នាក់ក្រោមជាតិឲ្យបានយល់ដឹង និងរួមគ្នាទប់ស្កាត់អំពីការប្រយុទ្ធប្រឆាំងការជួញដូរមនុស្សនៅខេត្តបាត់ដំបង

http://m.freshnewsasia.com/ 2020-10-26 11:20am

**(បាត់ដំបង)៖** ក្រសួងមហាផ្ទៃ និងរដ្ឋបាលខេត្តបាត់ដំបង បានបើកវគ្គបណ្តុះបណ្តាលគោលការណ៍ណែនាំស្តីពី បែបបទ និងនីតិវិធីនៃការ កំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្សដើម្បីផ្តល់សេវាសមស្របមានរយៈពេល៣ថ្ងៃ ចាប់ពីថ្ងៃ២៦ ដល់ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០ នៅសាលាខេត្តបាត់ដំបង។ ពិធីនេះបានធ្វើឡើងក្រោមវត្តមានលោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងប្រតិភូអមដំណើរ លោកស្រី សុំ ចិន្តា អភិបាលរងខេត្ត និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាការប្រយុទ្ធប្រឆាំងការជួញដូរមនុស្សខេត្ត ព្រមទាំងមានការចូលរួមពីអភិបាលក្រុងស្រុក មន្ទីរពាក់ព័ន្ធ កងកម្លាំង ក្រុមប្រឹក្សាឃុំសង្កាត់ ជាច្រើននាក់ផងដែរ។ លោកស្រី សុំ ចិន្តា អភិបាលរងខេត្តបានរាយការណ៍អំពីករណីគ្រោះទឹកជំនន់ថ្មីៗនេះ ដែលធ្វើឲ្យមានផលប៉ះពាល់ដល់ការខូចខាតផលដំណាំកសិកម្មរាប់សិបហិកតា និងជួបប្រទះជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋយើង។

លោកស្រី ជូ ប៊ុនអេង បានបញ្ជាក់ពីកិច្ចការជំនាញយើងតាំងពីថ្នាក់ជាតិដល់ថ្នាក់មូលដ្ឋាន ដោយត្រូវនាំគ្នាអនុវត្តការងារនេះបន្តទៀត និងផ្តាំផ្ញើសិក្ខាកាមទាំងអស់ខិតខំយកចិត្តទុកស្រាប់គ្រូឧទ្ទេសដើម្បីទទួលយកចំណេះដឹងសម្រាប់យកទៅអនុវត្តឲ្យបានល្អចំគោលដៅផងដែរ។ លោកស្រី ជូ ប៊ុនអេង បានបញ្ជាក់អំពីករណីប្រជាពលរដ្ឋយើងដែលកំពុងរងគ្រោះដោយសារទឹកជំនន់ ហើយកំពុងប្រឈមនឹងការប៉ះពាល់ជីវភាពរស់នៅរបស់ពួកគាត់ និងបន្តការខ្វះខាតនេះ នឹងអាចជួបការលំបាកអូសបន្លាយជាច្រើនខែខាងមុខ ហើយពាក់ព័ន្ធបញ្ហាប្រឈមក្នុងការឆ្លងកូវីដ-១៩ ផងដែរ ខណៈពេលពួកគាត់បានឆ្លងដែនទៅធ្វើការនៅក្រៅប្រទេស។ លោកស្រី បានបន្តថា «**រាល់បញ្ហាកើតមានឡើងរបស់ប្រជាពលរដ្ឋដែលរងគ្រោះទាំងនោះ គឺជាបន្ទុកទទួលខុសត្រូវរបស់រាជរដ្ឋាភិបាលកម្ពុជាយើង ដូច្នេះហើយទើបយើងបានបន្តបើក វគ្គបណ្តុះបណ្តាលដល់មន្ត្រីថ្នាក់ក្រោមជាតិបានយល់ដឹង និងរួមគ្នាទប់ស្កាត់អំពី**

ការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ដើម្បីកុំឲ្យប្រជាពលរដ្ឋទទួលរងគ្រោះដោយសារការជួញដូរនេះ។ ហើយមន្ត្រីជំនាញត្រូវកំណត់អត្តសញ្ញាណការជួញដូរមនុស្ស និងជនរងគ្រោះ និងមេខ្យល់ដែលឆ្លៀតឱកាសផងដែរ»៕

## កម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំឃ្សឹម ធ្វើការផ្សព្វផ្សាយនិងចែកខិតប័ណ្ណ ស្តីពីភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋនៅភូមិឃ្សឹមក្រៅ

http://cambodiapolice.com/policekh/ 1:07 pm 26 តុលា 2020

ខេត្តក្រចេះ ៖ នាព្រឹកថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង០៨ និង០០នាទីកម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំឃ្សឹម បានធ្វើការផ្សព្វផ្សាយ និងចែកខិតប័ណ្ណ ស្តីពីភូមិឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋនៅចំណុច ភូមិឃ្សឹមក្រៅ ឃុំឃ្សឹម ស្រុកស្នួល ខេត្តក្រចេះ ។ ក្នុងនោះកម្លាំងនគរបាលប៉ុស្តិ៍រដ្ឋបាលបានធ្វើការផ្សព្វផ្សាយនិងចែកខិតប័ណ្ណរួមមាន ៖

១/ សេចក្តីចូលរួមអំពាវនាវចូលរួមគាំទ្រយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់នៅកម្ពុជា ។

២/ រួមគ្នាបង្ការទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀន ។

៣/ ចែកសារសម្រាប់អប់រំអំពីផលប៉ះពាល់គ្រោះថ្នាក់នៃគ្រឿងញៀន ។

៤/ ផ្សព្វផ្សាយអនុក្រិត្យលេខ៣៩អនក្រ,បកចុះថ្ងៃទី១៧ ខែមិនាឆ្នាំ២០២០ស្តីពីការពិន័យអន្តរកាលចំពោះអំពើល្មើសច្បាប់ចរាចរណ៍ផ្លូវគោកថ្មី ។

៥/ ផ្សព្វផ្សាយរួមគ្នាបង្ការទប់ស្កាត់បទល្មើសបញ្ហាចោរកម្ម គ្រប់ប្រភេទ ។

៦/ ផ្សព្វផ្សាយ រួមគ្នាបង្ការការប្រើអំពើហឹង្សាទាក់ទង នឹងយេនឌ័រ,អំពើជួញដូរស្ត្រីនិងកុមារ ។

៧/ ផ្សព្វផ្សាយគ្រោះថ្នាក់ដោយសារយុទ្ធភ័ណ្ឌគ្រាប់មិនទាន់ផ្ទុះ ។

៨/ ផ្សព្វផ្សាយ អំពីការលេងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ។

៩/ ផ្សព្វផ្សាយអំពីគ្រោះអគ្គីភ័យ និងផ្សព្វផ្សាយសេចក្តីណែនាំរបស់ក្រសួងសុខាភិបាលស្តីពីវិធីការការពារទប់ស្កាត់នៃការរីករាលដាលអំពីជំងឺកូវីដ១៩ផងដែរ ។

នាឱកាសក្នុងនោះដែរ កម្លាំងក៏បានធ្វើការផ្សព្វផ្សាយនូវលក្ខណៈសម្បត្តិទាំង០៩យ៉ាងរបស់គោលនយោបាយភូមិ-ឃុំមានសុវត្ថិភាពដែលមានអ្នកចូលរួមចំនួន៥៥នាក់/ស្រីចំនួន២០នាក់ ៕

## ពិធីផ្សព្វផ្សាយ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព នៅសង្កាត់ដងទង់ ក្រុងខេមរភូមិន្ទ

https://gdlf-kh.com/ 2020/10/27/ Kao sophy ខេត្តកោះកុង

ខេត្តកោះកុង៖ ថ្ងៃចន្ទ ១០ កើត ខែកត្តិក ឆ្នាំជូតទោស័ក ពុទ្ធសករាជ ២៥៦៤ ត្រូវនឹងថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២០ លោក ស្រេង ហុង អភិបាលរង នៃគណៈអភិបាលខេត្តកោះកុង និងជាប្រធានលេខាធិការដ្ឋានជួញដូរខេត្ត បានអញ្ជើញជាអធិបតី ក្នុងពិធីផ្សព្វផ្សាយ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព នៅសង្កាត់ដងទង់ ក្រុងខេមរភូមិន្ទ។ ក្នុងឱកាសនោះដែរ លោកអភិបាលរងខេត្ត បានលើកឡើងថា បច្ចុប្បន្នមានប្រជាពលរដ្ឋកម្ពុជាប្រមាណជាងមួយលាននាក់ កំពុងតែបំពេញការងារនៅបរទេសទាំងមាន និងមិនមានឯកសារគ្រប់គ្រាន់។ ប្រទេសថៃបានក្លាយជាប្រទេសគោលដៅដ៏ធំបំផុតសម្រាប់ពលករចំណាកស្រុកកម្ពុជា ហើយតាមការប៉ាន់ប្រមាណមានប្រជាពលករដ្ឋច្រើនជាងមួយលាននាក់ កំពុងតែបំពេញការងារនៅទីនោះ។ មានកត្តាជាច្រើន ដែលបណ្តាលអោយប្រជាពលរដ្ឋកម្ពុជាធ្វើចំណាកស្រុកទៅប្រទេសថៃ ដែលក្នុងនោះរួមមានទាំងកត្តាជីវភាព កង្វះខាតការងារធ្វើ និងការទាក់ទាញពីមេខ្យល់ និងនិយោជកផងដែរ។ កង្វះខាតព័ត៌មានគ្រប់គ្រាន់សំរាប់ការធ្វើសេចក្តីសម្រេចចិត្ត នៅក្នុងការធ្វើចំណាកនៅតែជាបញ្ហាប្រឈម ហើយជារឿយៗដោយសារតែបញ្ហានេះមានបានធ្វើប្រជាពលរដ្ឋកម្ពុជា ដែល

ទៅធ្វើការងារនៅបរទេសនោះបានចាញ់បោកមេខ្យល់ ថៅកែ ហើយអ្នកខ្លះទៀតធ្លាក់ខ្លួនជាជនរងគ្រោះ ដោយអំពើជួញដូរមនុស្សទៀតផង។

ដោយមើលឃើញពីសារៈសំខាន់នៃព័ត៌មានសំរាប់ពលករចំណាកស្រុកកម្ពុជា នឹងដើម្បីចូលរួមកាត់បន្ថយនៅហានិភ័យ និងភាពងាយរងគ្រោះរបស់ប្រជាជនកម្ពុជា ក៏ដូចជាប្រជាពលរដ្ឋក្នុងខេត្តកោះកុង ក្នុងការធ្វើចំណាកស្រុកស្វែងរកការងារធ្វើនោះ អង្គការជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រី អង្គការ វីវើលជីវីស៊ី អង្គការហ្វាពន្លឺសិល្បៈ និងអង្គការ មេឡៀវន្ត ក្រោមការគាំទ្រពីសហគមន៍ អឺរ៉ុប តាមរយៈគម្រោង មីក្រាវ៉ាយ (គម្រោងគាំទ្រ និងការទាក់ទាញមតិដើម្បី ការពារសិទ្ធិពលករចំណាកស្រុកកម្ពុជា)។ បានរៀបចំយុទ្ធនាការ លើកកំពស់ចំណាកស្រុកដោយសុវត្ថិភាព ដើម្បីបង្កើនលទ្ធភាពអោយពលករចំណាកស្រុក និងក្រុមគ្រួសាររបស់ពួកគេទទួលបាននូវព័ត៌មានពេញលេញមុននឹងធ្វើការសម្រេចចិត្តទៅធ្វើការងារនៅបរទេស។ គោលបំណងចម្បងក្នុងការលើកកំពស់សុវត្ថិភាព នៅក្នុងធ្វើចំណាកស្រុក សុវត្ថិភាពនៅកន្លែងធ្វើការងារតាមរយៈការផ្តល់ព័ត៌មានគ្រប់ជ្រុងជ្រោយសំរាប់ធ្វើការសម្រេចចិត្តក្នុងការធ្វើចំណាកស្រុក និងនៅពេលដែលមានបញ្ហាកើតឡើង។ ជាមួយគ្នានេះផងដែរ យុទ្ធនាការ នេះក៏មានគោលដៅជាច់ដោយឡែកមួយចំនួនដូចជា ៖-ពង្រឹងប្រពន្ធ័សុវត្ថិភាព ក្នុងការធ្វើចំណាកស្រុក -បង្ហាញនូវគន្លឹះសំខាន់ៗក្នុងការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងហានិភ័យដែលអាចកើតមាន -ផ្សព្វផ្សាយនៅបទពិសោធន៍របស់ពលករចំណាកស្រុក៕

## ពិធីផ្សព្វផ្សាយ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព នៅស្រុកមណ្ឌលសីមា

https://grandnewsasia.com/ 26-10-2020

កោះកុង៖ លោក ស្រេង ហុង អភិបាលរងខេត្តកោះកុង និងជាប្រធានលេខាធិការដ្ឋានជួញដូរខេត្ត នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២០ បានអញ្ជើញជាអធិបតីក្នុងពិធីផ្សព្វផ្សាយ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព នៅស្រុកមណ្ឌលសីមា។ ក្នុងឱកាសនោះដែរ លោកអភិបាលរងខេត្ត បានលើកឡើងថា បច្ចុប្បន្នមានប្រជាពលរដ្ឋកម្ពុជាប្រមាណជាងមួយលាននាក់ កំពុងតែបំពេញការងារនៅបរទេសទាំងមាន និងមិនមានឯកសារគ្រប់គ្រាន់។ ប្រទេសថៃបានក្លាយជាប្រទេសគោលដៅដ៏ធំបំផុតសម្រាប់ពលករចំណាកស្រុកកម្ពុជា ហើយតាមការប៉ាន់ប្រមាណមានប្រជាពលករដ្ឋច្រើនជាងមួយលាននាក់ កំពុងតែបំពេញការងារនៅទីនោះ។ មានកត្តាជាច្រើន ដែលបណ្តាលអោយប្រជាពលរដ្ឋកម្ពុជាធ្វើចំណាកស្រុកទៅប្រទេសថៃ ដែលក្នុងនោះរួមមានទាំងកត្តាជីវភាព កង្វះខាតការងារធ្វើ និងការទាក់ទាញពីមេខ្យល់ និងនិយោជកផងដែរ។ ក្នុងនោះ កង្វះខាតព័ត៌មានគ្រប់គ្រាន់សំរាប់ការធ្វើសេចក្តីសម្រេចចិត្ត នៅក្នុងការធ្វើចំណាកនៅតែជាបញ្ហាប្រឈម ហើយជារឿយៗដោយសារតែបញ្ហានេះ បានធ្វើប្រជាពលរដ្ឋកម្ពុជា ដែលទៅធ្វើការងារនៅបរទេសនោះបានចាញ់បោកមេខ្យល់ ថៅកែ ហើយអ្នកខ្លះទៀតធ្លាក់ខ្លួនជាជនរងគ្រោះ ដោយអំពើជួញដូរមនុស្សទៀតផង។

ដោយមើលឃើញពីសារៈសំខាន់នៃព័ត៌មានសំរាប់ពលករចំណាកស្រុកកម្ពុជា នឹងដើម្បីចូលរួមកាត់បន្ថយនៅហានិភ័យ និងភាពងាយរងគ្រោះរបស់ប្រជាជនកម្ពុជា ក៏ដូចជាប្រជាពលរដ្ឋក្នុងខេត្តកោះកុង ក្នុងការធ្វើចំណាកស្រុកស្វែងរកការងារធ្វើនោះ អង្គការជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រី អង្គការ វីវើលជីវីស៊ី អង្គការហ្វាពន្លឺសិល្បៈ និងអង្គការ មេឡៀវន្ត ក្រោមការគាំទ្រពីសហគមន៍ អឺរ៉ុប តាមរយៈគម្រោង មីក្រាវ៉ាយ (គម្រោងគាំទ្រ និងការទាក់ទាញមតិដើម្បីការពារសិទ្ធិពលករចំណាកស្រុកកម្ពុជា)។ បានរៀបចំយុទ្ធនាការ លើកកំពស់ចំណាកស្រុកដោយសុវត្ថិភាព ដើម្បីបង្កើនលទ្ធភាពអោយពលករចំណាកស្រុក និងក្រុមគ្រួសាររបស់ពួកគេទទួលបាននូវព័ត៌មានពេញលេញមុននឹងធ្វើការសម្រេចចិត្តទៅធ្វើការងារនៅបរទេស។ លោកបានបន្ថែមថា គោលបំណងចម្បងក្នុងការលើកកំពស់សុវត្ថិភាពក្នុងការធ្វើចំណាកស្រុក សុវត្ថិភាពនៅកន្លែងធ្វើការងារតាមរយៈការផ្តល់ព័ត៌មានគ្រប់ជ្រុងជ្រោយសំ

រាប់ធ្វើការសម្រេចចិត្តក្នុងការធ្វើចំណាកស្រុក និងនៅពេលដែលមានបញ្ហាកើតឡើង។ យុទ្ធនាការ នេះក៏មានគោលដៅជាច់ដោយឡែកមួយចំនួនដូចជា ៖-ពង្រឹងប្រពន្ធ័សុវត្ថិភាព ក្នុងការធ្វើចំណាកស្រុក -បង្ហាញនូវគន្លឹះសំខាន់ៗក្នុងការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងហានិភ័យដែលអាចកើតមាន -ផ្សព្វផ្សាយនៅបទពិសោធន៍របស់ពលករចំណាកស្រុក៕

## លោកជំទាវ ប៉ាង ដានី អភិបាលរងខេត្តកំពង់ចាម ផ្តល់អនុវសាសន៍ចំនួន៣ចំណុចដើម្បីពង្រឹងលើការងារប្រយុទ្ធ ប្រឆាំងអំពើ ជួញដូរមនុស្សឲ្យមានប្រសិទ្ធភាព

https://www.pdikampongcham.info/ ២៦ ខែតុលា ២០២០ **អត្ថបទ៖ ជឹម សារ៉ែន**

នាព្រឹក ថ្ងៃ ចន្ទ ១០កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស២៥៦៤ ត្រូវនិង ថ្ងៃទី ២៦ ខែតុលា ឆ្នាំ២០២០ លោកជំទាវ ប៉ាង ដានី អភិបាលរងខេត្ត និងជាអនុប្រធានលេខាធិការដ្ឋានខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តំណាងឯកឧត្តម អ៊ុនចាន់ដា បានអញ្ជើញជាអធិបតីក្នុងពិធីបើកវគ្គបណ្តុះបណ្តាល ដល់មន្ត្រីជាយន្តការគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅថ្នាក់ក្រុង ស្រុក ឃុំ សង្កាត់ ជាសមាជិកក្រុមទាំង៣មានក្រុងកំពង់ចាម ស្រុកកងមាស និងស្រុកស្រីសន្ធរ នៃ គ.ខ.ប.ជ ចំនួន១២០ នៅសាលប្រជុំសាលាខេត្តកំពង់ចាម។

មានមតិក្នុងពិធីបើកវគ្គបណ្តុះបណ្តាលលោកជំទាវ ប៉ាង ដានី អភិបាលរងខេត្តលោកជំទាវ ប៉ាង ដានី អភិបាលខេត្តកំពង់ចាម ផ្តល់អនុវសាសន៍ចំនួន៣ចំណុចដល់អង្គពិធីដូចជា៖

១-សមាជិកទាំងអស់ ដែលទទួលបានចំណេះដឹងបទពិសោធន៍ថ្មីៗ បន្ថែមទៀតពីវគ្គបណ្តុះបណ្តាលនេះ ដើម្បីបង្កើនការយល់ដឹងក្នុងការចូលរួមគ្រប់សកម្មភាពដើម្បីបង្ការទប់ស្កាត់ ឲ្យមានប្រសិទ្ធភាព។

២-ក្រោយពី ទទួលបានដំណឹងថាមានពលករ ចំណូលស្រុកមកហើយសូម ជួយតាមដានមើលក្រោយពីបងប្អូនពលករធ្វើចិត្តចត្តាឡីស័ក១៤ថ្ងៃ នៅតាមគេហដ្ឋាន តាមសួរមើលថា តើធ្វើការងារនៅក្រៅប្រទេស ដោយស្របច្បាប់ឬក៏មិនស្របច្បាប់ បើមិនស្របច្បាប់ យើងត្រូវរែករកមេខ្យល់។ នេះជាចំណុចមួយដែលយើងធ្វើមានប្រសិទ្ធភាពកន្លងមកនិងត្រូវយក់ចិត្តទុកដាក់។

៣-សូមបងប្អូននៅតែបន្តសហការជាមួយអាជ្ញាធរឬក៏ធ្វើរបាយការណ៍ឱ្យបានទាន់ពេវេលា ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឲ្យមានប្រសិទ្ធភាព។

គួរបញ្ជាក់ថា តាមរបាយការណ៍របស់សាលាខេត្តកំពង់ចាមគិតត្រឹមថ្ងៃទី ២៥ ខែតុលា ឆ្នាំ២០២០ ចំណូលស្រុកក្នុងខេត្តកំពង់ចាម មានចំនួន ៤៨០០នាក់។ ពលករចំណូលច្រើនជាងគេគឺស្រុក កំពង់សៀមដោយសារតែស្រុកនេះមានវិសាលភាពធំហើយមានចំនួនឃុំច្រើន។ ស្រុកស្រីសន្ធរ មានចំនួន ២៥០នាក់ ក្នុងចំណោម ៤៨០០នាក់ និង ស្រុកកងមាស មានចំនួន ៥៥៨នាក់។

## កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិភ្នំដី បានធ្វើការល្បាតតាមរបៀងស្លាបឆ្វេង និងស្លាបស្តាំ ដើម្បីទប់ស្កាត់ប្រជាពលរដ្ឋ កុំឲ្យធ្វើការឆ្លងដែនតាមរបៀង ចំនួន ០៧នាក់

https://www.facebook.com/GDIOfficial 26-10-2020

នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ០៧និង៣០នាទី កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិភ្នំដី បានធ្វើការល្បាតតាមរបៀងស្លាបឆ្វេង និងស្លាបស្តាំ ក្នុងរង្វង់ប្រតិបត្តិការណ៍របស់ប៉ុស្តិ៍ ដើម្បីទប់ស្កាត់ប្រជាពលរដ្ឋ កុំឲ្យធ្វើការឆ្លងដែនតាមរបៀង។ បន្ទាប់មកកម្លាំងប៉ុស្តិ៍ ក៏បានប្រទះឃើញប្រជាពលរដ្ឋខ្មែរ ចំនួន ០៧នាក់ ស្រី ០៣នាក់ ជាប្រជាពលរដ្ឋរស់នៅក្នុងមូលដ្ឋានស្រុកសំពៅលូន ខេត្តបាត់ដំបង ដែលខ្លះជាអ្នកស៊ីឈ្នួលលើកសំភារៈ និងខ្លះទៀតជាអាជីវករ បានធ្វើការឆ្លងដែនចេញទៅផ្សារ បានខៅឌីន (ផ្សារជាប់ព្រំដែន) ស្រុកខ្លង

ហាត ខេត្តស្រះកែវ ប្រទេសថៃ តាមរបៀងស្លាបឆ្វេងរបស់ប៉ុស្តិ៍។ ក្រោយមកកម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការអប់រំណែនាំ ដល់ប្រជាពលរដ្ឋទាំងអស់ខាងលើ ឲ្យបញ្ឈប់ការធ្វើសកម្មភាពបែបនេះទៀត និងបានអនុញ្ញាតឲ្យពួកគាត់ត្រលប់ទៅផ្ទះវិញរៀងៗខ្លួន៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១០២នាក់

https://www.facebook.com/GDIOfficial 26-10-2020

នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការនិងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១០២នាក់ ស្រី ៤៣នាក់៕

# ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០

## លោក ជំទាវ ជូ ប៊ុនអេង អញ្ជើញជាអធិបតីភាពក្នុងពិធីបើកវគ្គបណ្តុះបណ្តាលគោលការណ៍ណែនាំស្តីពី បែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្សដើម្បីផ្តល់សេវាសមស្រប នៅសាលាខេត្តបាត់ដំបង

https://www.battambang.gov.kh/ ថ្ងៃចន្ទ, 26 ខែតុលា, 2020ដោយ Sotheavy

នៅថ្ងៃចន្ទ ១០កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២០ លោកស្រី សុំ ចិន្តា អភិបាលរង នៃគណៈអភិបាលខេត្ត អញ្ជើញចូលរួមក្នុងវគ្គបណ្តុះបណ្តាលគោលការណ៍ណែនាំស្តីពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្របក្រោមវត្តមានលោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃនិងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ។ នៅក្នុងវគ្គបណ្តុះបណ្តាលនេះមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ លោកស្រីស្នងការរងនគរបាលខេត្ត មេបញ្ជាការរង កងរាជអាវុធហត្ថខេត្ត លោក លោកស្រី អភិបាលរងស្រុក អធិការរងនគរបាលខេត្ត សមាជិកក្រុមប្រឹក្សា ឃុំ គ.ក.ន.ក ឃុំ និងមន្ទីរពាក់ព័ន្ធមួយចំនួនទៀត។

លោកស្រី សុំ ចិន្តា អភិបាលរង នៃគណៈអភិបាលខេត្ត និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខេត្ត បានមានមតិស្វាគមន៍ និងអានរបាយការណ៍សង្ខេប របស់ គ.ខ .ប.ជ រយៈពេល ១០ខែកន្លងទៅនេះ ដោយបានបញ្ជាក់ផងដែរអំពីករណីគ្រោះទឹកជំនន់ថ្មីៗនេះដែលធ្វើឲ្យមានផលប៉ះពាល់ដល់ការខូចខាតផលដំណាំកសិកម្មរាប់សិបហិកតា និងជួបប្រទះជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋយើង។

លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្សបានអញ្ជើញឡើងសំណេះសំណាលក្នុងពិធីបើកវគ្គបណ្តុះបណ្តាល ដោយបានបញ្ជាក់ពីកិច្ចការជំនាញយើងតាំងពីថ្នាក់ជាតិដល់ថ្នាក់មូលដ្ឋានត្រូវនាំគ្នាអនុវត្តការងារនេះបន្តទៀត និងផ្តាំផ្ញើសិក្ខាកាមទាំងអស់ខិតខំយកចិត្តទុកស្រាប់គ្រូឧទ្ទេស ដើម្បីទទួលយកចំណេះដឹងសម្រាប់យកទៅអនុវត្តឲ្យបានល្អចំ

គោលដៅផងដែរ។ លោកជំទាវ ជូ ប៊ុនអេង បានបញ្ជាក់ផងដែរអំពីករណីប្រជាពលរដ្ឋយើងកំពុងរងគ្រោះដោយសារទឹកជំនន់ ហើយកំពុងប្រឈមនឹងការប៉ះពាល់ជីវភាពរស់នៅរបស់ពួកគាត់ និងបន្តការខ្វះខាតនេះនឹងអាចជួបការលំបាកអូសបន្លាយជាច្រើនខែខាងមុខ ហើយពាក់ព័ន្ធបញ្ហាប្រឈមក្នុងការឆ្លងជម្ងឺកូវីដ-១៩ផងដែរ ខណៈពេលពួកគាត់បានឆ្លងដែនទៅធ្វើការនៅក្រៅប្រទេស។ លោកជំទាវ បានបន្តថា រាល់បញ្ហាកើតមានឡើងរបស់ប្រជាពលរដ្ឋដែលរងគ្រោះទាំងនោះ គឺជាបន្ទុកទទួលខុសត្រូវរបស់រាជរដ្ឋាភិបាលកម្ពុជាយើងដែរ ដូច្នេះហើយទើបយើង បានបន្តបើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីថ្នាក់ក្រោមជាតិបានយល់ដឹង នឹងរួមគ្នាទប់ស្កាត់អំពីការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ដើម្បីកុំឲ្យប្រជាពលរដ្ឋទទួលរងគ្រោះដោយសារការជួញដូរនេះ។ ហើយមន្ត្រីជំនាញត្រូវកំណត់អត្តសញ្ញាណការជួញដូរមនុស្សនិងជនរងគ្រោះនិងមេខ្យល់ដែលឆ្លៀតឱកាសផងដែរ៕

## លេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត បានរៀបចំកិច្ចប្រជុំត្រួតពិនិត្យការងារ ប្រចាំខែតុលា ឆ្នាំ២០២០

https://www.facebook.com/deputygovernoryousophear/ 27-10-2020

នៅព្រឹកថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២០ លេខាធិការដ្ឋាននៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តសៀមរាប (គ.ខ.ប.ជ) បានរៀបចំកិច្ចប្រជុំប្រចាំខែតុលា ឆ្នាំ២០២០ ក្រោមកិច្ចដឹកនាំរបស់ លោកស្រី យូ សុភា អភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តសៀមរាប ព្រមទាំងមានការអញ្ជើញចូលរួមពីលោក លោកស្រី សមាជិក សមាជិកា លេខាធិការដ្ឋាន គ.ខ.ប.ជ ពីមន្ទីរអង្គភាពពាក់ព័ន្ធ ព្រមទាំងតំណាងអង្គការ ដៃគូពាក់ព័ន្ធសរុប៥៥នាក់ ស្រី ៣២នាក់។ អង្គប្រជុំបានពិនិត្យទៅលើកំណត់ហេតុ និងត្រួតពិនិត្យលើផែនការដែលអង្គប្រជុំបានដាក់ចេញកាលពីកិច្ចប្រជុំប្រចាំត្រីមាសទី៣ ឆ្នាំ២០២០ កន្លងទៅ និងបានពិភាក្សាលើបញ្ហាប្រឈមមួយចំនួន ដែលក្រុមការងារបានអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមគ្រប់រូបភាពដោយមានការចូលរួមសហការពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ នៅតាមមូលដ្ឋានភូមិ ឃុំ ដូចជាធ្វេីការផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ច្បាប់ពាក់ព័ន្ធនានា គោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព វេទិកាសាធារណៈ ច្បាប់ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ស្ប៉តអប់រំ ការផ្សាយតាមវិទ្យុ ទូរទស្សន៍ ជាដើម។ល។ បន្ថែមពីនេះ ក៏មានការស៊ើបអង្កេត និងបង្ក្រាបបទល្មើស ដើម្បីយកទៅផ្តន្ទាទោសតាមនីតិវិធីច្បាប់បានរាល់ករណីផងដែរ ពិសេសការស្រាវជ្រាវស្វែងរកចាប់និងឃាត់ខ្លួនមេខ្យល់ ។

នៅក្នុងកិច្ចប្រជុំនេះផងដែរ ក៏បានលើកយកបញ្ហាជាច្រើនមកពិភាក្សា ដើម្បីស្វែងរកដំណោះស្រាយរួមគ្នាសម្រាប់ការពារជនរងគ្រោះ និងងាយរងគ្រោះ ដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ ឬការរំលោភបំពានផ្សេងៗដែលពាក់ព័ន្ធទៅនឹងច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ កិច្ចប្រជុំបានធ្វើការពិភាក្សា និងទទួលបានលទ្ធបានដូចខាងក្រោម ៖

១.ពិនិត្យលើរបាយការណ៍ប្រចាំខែតុលា និងរបាយការណ៍រយៈពេល១០ខែ នៃសកម្មភាពរបស់លេខាធិការដ្ឋាន ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តសៀមរាប។

២.ពិនិត្យ និងពិភាក្សាលើប្រព័ន្ធបញ្ជូន និងទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្ស រវាងមន្ទីរអង្គភាពពាក់ព័ន្ធ និងអង្គការដៃគូជាតិ អន្តរជាតិក្នុ ងការបញ្ជូនជនរងគ្រោះទៅមន្ទីរសង្គមកិច្ច (មន្ទីរសង្គមកិច្ចជាអ្នកគ្រប់គ្រងទិន្នន័យរួម ហើយត្រូវធ្វើការបែងចែកអំពីប្រភេទនៃជនរងគ្រោះឱ្យបានត្រឹមត្រូវ) ។

៣.ការជំរុញឱ្យមន្ទីរសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត លើការគ្រប់គ្រងមណ្ឌលសុវត្ថិភាព សម្រាប់ជនរងគ្រោះ និងគ្រប់គ្រងប្រព័ន្ធនៃការធ្វើសមាហរណកម្មជនរងគ្រោះត្រឡប់មកគ្រួសារ ឬនៅសហគមន៍វិញ ។

៤.ការបើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីនគរបាល នៅតាមប៉ុស្តិ៍ឃុំ សង្កាត់នៅទូទាំងខេត្ត អំពីច្បាប់ស្តីពីអនីតិជន។

៥.ជំរុញលើការអនុវត្តការងារទៅតាមយន្តការ និងតាមនីតិវិធីរដ្ឋបាល ឬតាមលក្ខខ័ណ្ឌពិសេសណាមួយ ក្នុងន័យជំរុញការបម្រើការផ្តល់សេវាជួយជនរងគ្រោះឱ្យបានទាន់ពេលវេលា។

៦.ពិភាក្សាលើបញ្ហាប្រឈមនៃការបាត់បង់ការងារធ្វើនៅក្នុងខេត្តនិងបានជំរុញលើការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ។

៧.ជំរុញឱ្យមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត ពិនិត្យទៅលើស្ថានភាពរបស់ពលករដែលទើបត្រឡប់មកពីក្រៅប្រទេស អំពីការទទួលការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងការទទួលបានការងារធ្វើនៅក្នុងប្រទេសតាមរយៈការិយាល័យមជ្ឈមណ្ឌលការងារខេត្តសៀមរាប។

៨.ការិយាល័យមជ្ឈមណ្ឌលការងារខេត្តសៀមរាប បានធ្វើការផ្គូផ្គងការងារជូនបងប្អូនប្រជាពលរដ្ឋ ដែលជាពលករទេលបត្រឡប់មកពីក្រៅប្រទេស ឪពុករបស់កុមារដើរសុំទាន និងប្រជាពលរដ្ឋដែលបានបាត់បងការងារធ្វើក្នុងស្ថានភាពកូវីដ១៩ ដែលលេខាធិការដ្ឋាន គ.ខ.ប.ជ បានបញ្ជូនឈ្មោះទៅ ចំនួន ០៤នាក់ និងបានស្នើឱ្យពិនិត្យបន្ថែមនូវពលរដ្ឋចំនួន០១នាក់ ទៀត ដែលបានបំពេញទម្រង់ក្នុងការស្វែងរកការងារធ្វើកន្លងមក។

៩.ពិភាក្សាលើបញ្ហាអំពើហិង្សាក្នុងគ្រួសារ ដែលបានកើតឡើងតាមមូលដ្ឋាន ដែលជាមូលហេតុអាចធ្វើឱ្យប្រជាពលរដ្ឋធ្វើចំណាកស្រុក។

១០.បានពិភាក្សាលើបញ្ហាប្រឈមមួយចំនួនបន្ថែមទៀតពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

១១. អង្គការសកម្មភាពដើម្បីកុមារ (APLE) បានធ្វើការបង្ហាញអំពីបណ្តាញរាយការណ៍ពិសេសតាមប្រព័ន្ធអ៊ីនធឺណិត ពាក់ព័ន្ធនឹងការរំលោភបំពានផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ៕

## ក្រុមការងារលេខាធិការដ្ឋាន បានបន្តចុះបណ្តុះបណ្តាលស្តីពី ការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងកិច្ចបង្ការការពារការកេងប្រវ័ញ្ចផ្លូវភេទលើកុមារនៅតាមសហគន៍ នៅវិទ្យាល័យក្រឡាញ់

https://www.facebook.com/deputygovernoryousophear/ 21-10-2020

ថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០ ប្រធានបទសំខាន់ៗចំនួនបី៖ ១. កិច្ចបង្ការការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ២. វិធីសាស្រ្តនៃការទប់ស្កាត់អំពើជួញដូរមនុស្ស និង ៣. ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ត្រូវបានចែករំលែកដល់សិក្ខាកាមជាកុមារ យុវជន និងលោកគ្រូអ្នកគ្រូចំនួន៤៩នាក់នៅវិទ្យាល័យក្រឡាញ់ ស្រុកក្រឡាញ់ ដែលបានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី "ការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងការរំលោភបំពានផ្លូវភេទលើកុមារនៅតាមសហគមន៍"។ វគ្គបណ្តុះបណ្តាលនេះសហការរៀបចំឡើងដោយលេខាធិការដ្ឋានគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ) ខេត្តសៀមរាប មន្ទីរអប់រំ យុវជន និងកីឡាខេត្តសៀមរាប និងអង្គការសកម្មភាពដើម្បីកុមារ (APLE)។

## ការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងកិច្ចបង្ការការពារការកេងប្រវ័ញ្ចផ្លូវភេទលើកុមារនៅតាមសហគន៍នៅវិទ្យាល័យស្រែណូយ

https://www.facebook.com/deputygovernoryousophear/ 20-10-2020

ខេត្តសៀមរាប៖ នាថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២០ ប្រធានបទសំខាន់ៗចំនួនបី៖ ១. កិច្ចបង្ការការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ២. វិធីសាស្ត្រនៃការទប់ស្កាត់អំពើជួញដូរមនុស្ស និង ៣. ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ត្រូវបានចែករំលែកដល់សិក្ខាកាមជាកុមារ យុវជន និងលោកគ្រូអ្នកគ្រូចំនួន៦៤នាក់នៅវិទ្យាល័យស្រែណូយ ស្រុកវ៉ារិន ដែលបានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី "ការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងការរំលោភបំពានផ្លូវភេទលើកុមារនៅតាមសហគមន៍"។ វគ្គបណ្តុះបណ្តាលនេះសហការរៀបចំឡើងដោយលេខាធិការដ្ឋានគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ) ខេត្តសៀមរាប មន្ទីរអប់រំ យុវជន និងកីឡា ខេត្តសៀមរាប និងអង្គការសកម្មភាពដើម្បីកុមារ (APLE)។

## លោកគ្រូ អ្នកគ្រូ សិស្សានុសិស្សនៅអនុវិទ្យាល័យប្រាសាទធ្ងន់ ស្រុកអង្គរជុំ បានទទួលការបណ្តុះបណ្តាលស្តីពី ការទប់ស្កាត់អំពើជួញដូរមនុស្ស និងកិច្ចបង្ការការរំលោភបំពានផ្លូវភេទលើកុមារនៅតាមសហគមន៍

https://www.facebook.com/deputygovernoryousophear/ 19-10-2020

ខេត្តសៀមរាប៖ នាថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២០ ប្រធានបទសំខាន់ៗចំនួនបី៖ ១. កិច្ចបង្ការការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ២. វិធីសាស្ត្រនៃការទប់ស្កាត់អំពើជួញដូរមនុស្ស និង ៣. ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ត្រូវបានចែករំលែកដល់សិក្ខាកាមជាកុមារ យុវជន និងលោកគ្រូអ្នកគ្រូចំនួន៥៩ នាក់នអនុវិទ្យាល័យប្រាសាទធ្ងន់ស្រុកអង្គរជុំ ដែលបានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី "ការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងការរំលោភបំពានផ្លូវភេទលើកុមារនៅតាមសហគមន៍"។ វគ្គបណ្តុះបណ្តាលនេះសហការរៀបចំឡើងដោយលេខាធិការដ្ឋានគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ) ខេត្តសៀមរាប មន្ទីរអប់រំ យុវជន និងកីឡា ខេត្តសៀមរាប និងអង្គការសកម្មភាពដើម្បីកុមារ (APLE)។

## ការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងការរំលោភបំពានផ្លូវភេទលើកុមារនៅតាមសហគមន៍

https://www.facebook.com/deputygovernoryousophear/ 17-10-2020

ខេត្តសៀមរាប៖ នៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២០ កុមារនិងយុវជនចំនួន៦១នាក់ ស្រី៥០នាក់ នៅវិទ្យាល័យតេជោហ៊ុន សែន អង្គរធំ បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី "ការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងការរំលោភបំពានផ្លូវភេទលើកុមារនៅតាមសហគមន៍" ដែលសហការរៀបចំដោយលេខាធិការដ្ឋានគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ) ខេត្តសៀមរាប មន្ទីរអប់រំ យុវជន និងកីឡា ខេត្តសៀមរាប និងអង្គការសកម្មភាពដើម្បីកុមារ (APLE) ព្រមទាំងមានការឧបត្ថម្ភគាំទ្រពីអង្គការ ដែនដីមនុស្សហូរឡង់ដ៍ផងដែរ។

វគ្គបណ្តុះបណ្តាលរៀបចំឡើង ដើម្បីផ្តល់ចំណេះដឹងអំពីបញ្ហាអំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងកិច្ចបង្ការការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ និងនៅតាមសហគមន៍ដល់ក្រុមយុវជនតាមសាលារៀន។ ដើម្បីជំរុញឲ្យយុវជនយកទៅផ្សព្វផ្សាយបន្តទៅដល់មិត្តភ័ក្ត បងប្អូន និងប្រជាពលរដ្ឋនៅក្នុងសហគមន៍របស់ពួកគាត់ផងដែរ អោយបានទូលំទូលាយ។

## វគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅស្រុកស្រីស្នំ

https://www.facebook.com/deputygovernoryousophear/ 14-10-2020

ថ្ងៃពុធ ១២រោច ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២០ ក្រុមការងារលេខាធិការដ្ឋាន ដឹកនាំដោយលោក អ៊ុំម ចំរើន អនុប្រធានមន្ទីរការងារជាប្រធានក្រុមការងារកិច្ចការទេសន្តរប្រវេសន៍ និងជាតំណាងលោកជំទាវប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ និងមានការអញ្ជើញចូលរួមសម្របសម្រួលពីវាយគ្មិន ពីតំណាងមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត មន្ទីរសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត មន្ទីរកិច្ចការនារីខេត្ត និងអង្គការមូលនិធិអេ២១ ក្នុងវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពស្តីពី ការអនុវត្តតួនាទីភារកិច្ច គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការបង្ការ ទប់ស្កាត់ អំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងកិច្ចការពារកុមារពីការរំលោភបំពានផ្សេងៗ ដល់ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅថ្នាក់ស្រុក និងថ្នាក់ឃុំដែលមានសមាសភាពអញ្ជើញចញលរួមពីលោកស្រី អភិបាលរង ស្រុកទទួលបន្ទុក អធិការស្រុក កងរាជអាវុធហត្ថស្រុក មេឃុំ អ.ក.ន.ក នាយករដ្ឋបាលស្រុក ប្រធានស្រុកប្រតិបត្តិ/មណ្ឌលសុខភាពប្រធានការិ.ជុំវិញស្រុក នាយប៉ុស្តិ៍ មេភូមិ អនុភូមិ និងជំនួយការភូមិ សរុប ៤០នាក់ ស្រី១៣នាក់ នៅរដ្ឋបាលសាលាស្រុកស្រីស្នំ។ វគ្គបណ្តុះបណ្តាលនេះប្រព្រឹត្តទៅរយៈពេលពេញមួយថ្ងៃ ដោយមានកិច្ចសហការពីរដ្ឋបាលស្រុកស្រីស្នំ និងមានការគាំទ្រពីរដ្ឋបាលសាលាខេត្ត និងអង្គការមូលនិធិអេ២១ផងដែរ។ វគ្គបណ្តុះបណ្តាលនេះក្រុមការងារបានធ្វើបទបង្ហាញរួមមាន:

១.តួនាទីភារកិច្ច យន្តការនិងរចនាសម្ព័ន្ធនៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនិងការរៀបចំរបាយការណ៍

២. វិធីទាំង៧ក្នុងការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស

៣. ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព

៤. ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ

៥.រូបភាពនៃអំពើជួញដូរមនុស្សនិងការកេងប្រវ័ញ្ចលើកុមារ

៦.ការផ្តល់សេវាជូនជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងកិច្ចការពារកុមារ និងការផ្តល់សេវាដល់កុមាររងគ្រោះនៃអង្គការមូលនិធិអេ២១។

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរចំនួន ០១នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងករណីឆ្លងដែនខុសច្បាប់

https://www.facebook.com/GDIOfficial 27-10-2020

នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ១៦និង៣០នាទី ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរចំនួន ០១នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងករណីឆ្លងដែនខុសច្បាប់។ នគរបាលប៉ុស្តិ៍បានឲ្យដឹងថា ពលករខ្មែរនេះ មាន ឈ្មោះ ង៉ែត សុខណះ ភេទប្រុស អាយុ ៣២ឆ្នាំ រស់នៅភូមិចាំយាមឃុំប៉ាក់ខ្លងស្រុកមណ្ឌលសីម៉ា ខេត្តកោះកុង និងបានធ្វើការសាកសួរ អប់រំណែនាំ ដោយមានការចូលរួមត្រួតពិនិត្យសុខភាព ពីមន្ត្រីចត្តាឡីស័កប្រចាំមាត់ច្រក នូវវិធានការរបស់ក្រសួងសុខាភិបាលផងដែរ។ដោយឡែកខាងភាគីថៃ នៅតែបន្តបិទច្រកមិនឲ្យអ្នកដំណើរចេញ-ចូល ចំណែកទំនិញទទួលបានការអនុញ្ញាតនិងអ្នកបើកបរថយន្តចំនួន២នាក់ដែលទទួលបានការអនុញ្ញាត និងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានយ៉ាងត្រឹមត្រូវ៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៨៣នាក់

https://www.facebook.com/GDIOfficial 27-10-2020

នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្ដោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ដើម្បីបង្ការនិងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៨៣នាក់ ស្រី ៧៦នាក់ និងបានពលរដ្ឋខ្មែរចំនួន ០២នាក់ ពីភាគីថៃ ពាក់ព័ន្ធនឹងបទលួចចូលកាប់ឈើខុសច្បាប់ ក្នុងទឹកដីប្រទេសថៃ៕

## អាជ្ញាធរថៃចាប់បានពលករខ្មែរលួចឆ្លងដែនចូលប្រទេសថៃខុសច្បាប់តាមរយៈមេខ្យល់ចំនួន9នាក់

https://www.facebook.com/ ទឹកចិត្ត-ពលករ-ឆ្លងដែន 27-10-2020

អាជ្ញាធរថៃចាប់បានពលករខ្មែរលួចឆ្លងដែនចូលប្រទេសថៃខុសច្បាប់ តាមរយៈមេខ្យល់ចំនួន9នាក់។ ហេតុការនេះអាជ្ញាធរថៃចាប់បាននៅក្នុងឃុំតាបយ៉ា ស្រុកអារាញ់ ខេត្តស្រះកែវ ប្រទេសថៃ កាលពីថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០២០។ (អំពីខ្ញុំ ទឹកចិត្ត ពលករ ឆ្លងដែន)